**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ជីវភាពគ្រួសារ
# តាមរយៈការដាំបន្លែសុវត្ថិភាព

(ករណីសិក្សា៖ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល)

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **លាង លិហ៊ាង**

**ម៉េង ស៊ីវគីម**

ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ពហុ**


ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ លាង លិហ៊ាង និង ប៉េង ស៊ីវគីម ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ក្រុម $D_4A_1$ ឆ្នាំសិក្សា ២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណ

- លោកឪពុក លាង សុភាព និង អ្នកម្តាយ ម៉េង លីហួ
- លោកឪពុក ប៉េង ស្តុក និង អ្នកម្តាយ មាស យី

ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចរហូតធំក្តី ដោយមិនគិតខ្លាចពីការនឿយហត់ ព្រមទាំងអប់រំកូនឲ្យដើរតាមគន្លងធម៌។ លោកទាំងពីរតែងតែនៅក្បែរថែរក្សាការពារផ្តល់ដំបូន្មានល្អៗដើម្បីឲ្យកូនក្លាយជា កូនល្អ មិត្តល្អ និងពលរដ្ឋល្អក្នុងសង្គម និងបានផ្គត់ផ្គង់ឲ្យកូនបានសិក្សារៀនសូត្រមានចំណេះដឹង និងតែងតែលើកទឹកចិត្តកូនគ្រប់ពេលវេលាឲ្យកូនចេះតស៊ូ អត់ធ្មត់ រឹងមាំ ជំនះរាល់ឧបសគ្គទាំង ឡាយ ដើម្បីឲ្យទទួលបានភាពជោគជ័យ និងទៅដល់គោលដៅដែលជាក្តីស្រមៃរបស់កូន។

## សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ

- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រី ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធាន អនុប្រធាន លោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកគ្រប់លំដាប់ថ្នាក់នៃសាកលវិទ្យាល័យភូមិន្ទនីតិ សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំង កម្លាំងចិត្ត បង្ហាត់បង្រៀនយើងខ្ញុំតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់ និងបង្ករភាពងាយស្រួលការរៀនសូត្រ និងផ្តល់ចំណេះដឹងជំនាញ និងបទពិសោធ៍ល្អៗដល់យើងខ្ញុំឲ្យក្លាយជាពលរដ្ឋល្អដែលអាចចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។
- លោកសាស្ត្រាចារ្យ បណ្ឌិត ឈុន ពហុ ដែលបានណែនាំយើងខ្ញុំ ដោយបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ បង្ហាត់បង្ហាញ ពន្យល់ណែនាំ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់យើងខ្ញុំ ក្នុងការសរសេរសារណារហូតទទួលបាននូវភាពជោគជ័យ។
- លោកអំមេឃុំ នួន សឿន នៅឃុំស្វាយប្រទាល ដែលបានផ្តល់ទិន្នន័យក្នុងឃុំ និង លោក សេង ញ៉ិល ដែលជាប្រធានគ្រប់គ្រងក្រុមហ៊ុនមាសបៃតង ព្រមទាំងប្រជាកសិករដែលដាំដុះបន្លែសុវត្ថិភាពនៅឃុំស្វាយប្រទាលទាំងអស់ ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់បានចុះទៅកម្មសិក្សាដើម្បីចងក្រងសារណានេះ។ ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមពរលោកអ្នកគុណទាំងបួន ឯកឧត្តម លោកសាស្ត្រាចារ្យ និងអស់លោកអ្នកដែលបានរៀបរាប់ខាងលើនេះ ទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈនិងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល និងសិក្សាផ្នែកទ្រឹស្តីអស់រយៈពេលជិតបួនឆ្នាំ ស្របតាមទីផ្សារបច្ចុប្បន្នយើងខ្ញុំបានសិក្សាទាក់ទងនិងការធ្វើកសិកម្មដំណាំបន្លែ នៅឃុំស្វាយប្រទាល ក្នុងស្រុកស្អាង ខេត្ត កណ្តាល ក្រោមប្រធានបទ "ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែសុវត្ថិភាព" ។

គោលគំនិតចម្បងនៃប្រធានបទនេះគឺ សិក្សាស្វែងយល់អំពីឥទ្ធិពលនៃដំណាំបន្លែសុវត្ថិភាពទៅលើជីវភាពគ្រួសាររបស់ប្រជាកសិករ ស្ថានភាពទូទៅនៃការដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល ដែលសិក្សាអំពីលក្ខណៈបច្ចេកទេសក្នុងការដាំដុះបន្លែសុវត្ថិភាព សិក្សាពីបញ្ហាប្រឈម និងដំណោះស្រាយនានាដែលកើតមានឡើងជុំវិញការដាំបន្លែសុវត្ថិភាព និងសិក្សាពីជីវភាពប្រជាកសិករក្រោយពីការដាំបន្លែសុវត្ថិភាព ។ រួមជាមួយនិងការវិភាគពីប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែសុវត្ថិភាព សិក្សាពីសារៈសំខាន់របស់បន្លែសុវត្ថិភាព និងអនុសាសន៍ល្អៗដើម្បីជម្រុញផលិតភាពដំណាំបន្លែសុវត្ថិភាពរបស់ប្រជាជនដែលជាកសិករប្រកបរបរដាំដំណាំបន្លែសុវត្ថិភាពនេះ ។

ដើម្បីសម្រេចបានសារណានេះ ឲ្យកាន់តែមានខ្លឹមសារ និងអត្ថន័យល្អ យើងខ្ញុំបានចុះទៅសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើទស្សនៈនិងទ្រឹស្តីពាក់ព័ន្ធមួយចំនួន អំពីបច្ចេកទេសថ្មីៗបែបទំនើបក្នុងដំណើរការដាំដុះ និងគេហទំព័រមួយចំនួន និងឯកសារផ្សេងៗទៀត ។ ការសិក្សានេះ បានលើកឡើងពីបទពិសោធន៍ជាក់ស្តែង ក្នុងការដាំដុះ និងប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងការប្រកបរបរដាំដំណាំបន្លែសុវត្ថិភាពរបស់ប្រជាកសិករក្នុងឃុំស្វាយប្រទាល ។

នេះជាការរួមចំណែកដ៏តូចមួយ ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលចុះសិក្សាស្រាវជ្រាវដោយផ្ទាល់ដល់មូលដ្ឋានឃុំស្វាយប្រទាល និងស្ថាប័នពាក់ព័ន្ធនានា។ យើងខ្ញុំសង្ឃឹមថាសៀវភៅសារណាបទនេះ នឹងជួយជាគំនិតមួយក្នុងលើកស្ទួយផលិតកម្មកសិកម្មរបស់កម្ពុជា ជាពិសេសដំណាំបន្លែសុវត្ថិភាព ក្លាយជាផ្នែកមួយដែលផ្តល់ជាប្រយោជន៍ដល់ការសិក្សារបស់លោកអ្នកឲ្យបានរីកចម្រើន ។

អាស្រ័យដោយសារការសិក្សាស្រាវជ្រាវ និងចំណេះដឹងរបស់យើងខ្ញុំ នៅមានកម្រិត ទើបទាំងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធ ពុំទាន់មានភាពល្អឥតខ្ចោះពេញលេញនៅឡើយ ដូច្នេះ យើងខ្ញុំរីករាយ និងស្វាគមន៍ជានិច្ចចំពោះមតិរិះគន់ដើម្បីស្ថាបនាពីសំណាក់អ្នកអាន និងអ្នកសិក្សាទាំងឡាយ ដើម្បីឱ្យសៀវភៅមួយក្បាលនេះមានភាពល្អប្រសើរ និងអត្ថន័យពេញលេញ។

# មាតិកា


បញ្ជីអក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីក្រាប ........ vii


# សេចក្ដីផ្ដើម


១. លំនាំបញ្ហា ........ ១
២. ចំណោទបញ្ហា ........ ១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


# ជំពូកទី១
# រំលឹកទ្រឹស្តី


១.១. ទ្រឹស្តីកសិកម្ម ........ ៥
១.១.១. និយមន័យកសិកម្ម ........ ៥
១.១.២. ប្រវត្តិកសិកម្ម ........ ៥
១.១.៣. និយមន័យសេដ្ឋកិច្ចកសិកម្ម ........ ៦
១.១.៤. និយមន័យសហគមន៍កសិកម្ម ........ ៦
១.១.៥. និយមន័យកសិកម្មគ្រួសារ ........ ៧
១.១.៦. តួនាទីកសិកម្មចំពោះសេដ្ឋកិច្ច-សង្គម ........ ៧
១.១.៧. ការធ្វើកសិកម្មនៅកម្ពុជា ........ ៨
១.២. ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច ........ ៩
១.២.១. និយមន័យការអភិវឌ្ឍ ........ ៩
១.២.២. គោលបំណងនៃការអភិវឌ្ឍន៍ ........ ១០
១.៣. និយមន័យបន្លែ ........ ១០
១.៤. សារៈសំខាន់នៃការដាំដុះបន្លែ ........ ១០

១.៤.១.សារៈសំខាន់ផ្នែកម្ហូបអាហារ និងសុខភាព ........ ១១
១.៤.២. សារៈសំខាន់ចំពោះសេដ្ឋកិច្ច និងសង្គម ........ ១២
១.៥.កត្តាសំខាន់ៗទាក់ទងនិងការដាំដុះ........ ១២
១.៥.១. កត្តាអាកាសធាតុ........ ១៣
១.៥.១.១.កត្តាសីតុណ្ហភាព ........ ១៣
១.៥.១.២.កត្តាទឹកភ្លៀង ........ ១៣
១.៥.១.៣. សំណើមក្នុងបរិយាកាស........ ១៤
១.៥.១.៤. រយៈពេលយប់ និងថ្ងៃ ........ ១៤
១.៥.២.កត្តាទឹក........ ១៤
១.៥.៣. កត្តាដី........ ១៥
១.៥.៤. កត្តាជី ........ ១៦
១.៦. ស្ថានភាពទីផ្សារបន្លែនៅកម្ពុជា ........ ១៦
១.៦.១. និយមន័យទីផ្សារ ........ ១៦
១.៦.២. តម្រូវការ និងច្បាប់តម្រូវការ........ ១៧
១.៦.៣. ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់ ........ ១៧
១.៧. ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្មកសិកម្ម........ ១៨
១.៧.១. តម្រូវការទុនផលិតកម្ម និងចំណាយ........ ១៨
១.៧.២. ចំណូលពីការលក់បន្លែ ........ ១៩
១.៧.៣. ប្រាក់ចំណេញពីការដាំដុះបន្លែ........ ១៩
១.៧.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចមួយឯកតាទុនផលិតកម្ម........ ១៩
១.៧.៥. ប្រសិទ្ធភាពកម្លាំងពលកម្ម........ ២០
១.៧.៦.ប្រសិទ្ធភាពដីធ្លី ........ ២០
១.៨. ការវិភាគចំណុចស្រង់ដើម ........ ២០

## ជំពូកទី២

## ស្ថានភាពទូទៅនៃការដាំដុះបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល

២.១. ស្ថានភាពទូទៅនៃតំបន់សិក្សាស្រាវជ្រាវ........ ២២
២.១.១. ស្ថានភាពទូទៅស្រុកស្អាង ........ ២២

២.១.១.១. ទីតាំងភូមិសាស្ត្រស្រុកស្អាង ........ ២២
២.១.១.២. ស្ថានភាពសេដ្ឋកិច្ច ........ ២២
២.១.១.៣ ប្រភពទឹក ........ ២៣
២.១.២ ទីតាំងភូមិសាស្ត្រឃុំស្វាយប្រទាល ........ ២៣
២.១.៣. ស្ថានភាពទូទៅនៃឃុំស្វាយប្រទាល ........ ២៤
២.១.៤ ស្ថានភាពសេដ្ឋកិច្ច ........ ២៥
២.១.៤.១ ស្ថានភាពមុខរបរប្រជាជនក្នុងឃុំស្វាយប្រទាល ........ ២៥
២.១.៤.២ ស្ថានភាពលំនៅដ្ឋានប្រជាជនក្នុងឃុំស្វាយប្រទាល ........ ២៦
២.១.៤.៣ វិស័យគមនាគមន៍ ........ ២៦
២.១.៤.៤ ស្ថានភាពវិស័យកសិកម្មនៅឃុំស្វាយប្រទាល ........ ២៦
២.២. ស្ថានភាពផលិតកម្មបន្លែសុវត្ថិភាព ........ ២៧
២.២.១. បច្ចេកទេសដាំដុះ ........ ២៧
២.២.១.១. ការរៀបចំដី ........ ២៧
២.២.១.២. ការជ្រើសរើសពូជដំណាំ ........ ២៨
២.២.១.៣. ការដាំដុះ ........ ២៨
២.២.១.៤. ការថែទាំ ........ ២៨
២.២.២. រដូវកាលដាំដុះបន្លែសុវត្ថិភាព ........ ២៩
២.២.៣. ប្រភពទឹក ........ ៣០
២.២.៤. ការប្រមូលផល ........ ៣០
២.២.៥. ដើមទុន ........ ៣០
២.២.៦. ស្ថានភាពទីផ្សារបន្លែសុវត្ថិភាព ........ ៣១
២.២.៦.១.ទីផ្សារបន្លែសុវត្ថិភាព ........ ៣១
២.២.៦.២. បណ្តាញបែងចែកផលិតផលដំណាំបន្លែ ........ ៣១
២.២.៦.៣. បញ្ហាទីផ្សារបន្លែរបស់កសិករក្នុងឃុំស្វាយប្រទាល ........ ៣២
២.២.៦.៤. ដំណោះស្រាយបញ្ហាទីផ្សារ ........ ៣២
២.៣. ផែនការអនាគត ........ ៣៣

## ជំពូកទី៣
## ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

៣.១. ទិន្នន័យប្រជាសាស្ត្រ ..... ៣៥
៣.១.១. មេគ្រួសារ ..... ៣៥
៣.១.១.១. ភេទនៃមេគ្រួសារ ..... ៣៥
៣.១.១.២. ក្រុមអាយុនៃមេគ្រួសារ ..... ៣៥
៣.១.២. ចំនួនសមាជិកគ្រួសារ ..... ៣៧
៣.១.៣. ចំនួនកម្លាំងពលកម្មក្នុងគ្រួសារ ..... ៣៨
៣.២. ប្រភេទបន្លែ ..... ៣៩
៣.៣. រយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព ..... ៤០
៣.៤. ផ្ទៃដីដាំដុះ ..... ៤១
៣.៤.១. ភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ ..... ៤២
៣.៤.២. កម្មសិទ្ធិផ្ទៃដី ..... ៤២
៣.៥. ស្ថិតិដំណើរការផលិតកម្ម ..... ៤៣
៣.៥.១. ប្រភពដើមទុន ..... ៤៣
៣.៥.២. ប្រភពនៃបច្ចេកទេសដាំដុះ ..... ៤៣
៣.៥.៣. គ្រាប់ពូជដាំដុះ ..... ៤៤
៣.៥.៤. ប្រភពទឹកស្រោចស្រព ..... ៤៤
៣.៥.៥. បរិមាណទឹកសម្រាប់ការដាំដុះ ..... ៤៤
៣.៥.៦. ការប្រើប្រាស់ដី ..... ៤៥
៣.៥.៧. បញ្ហាប្រឈម ..... ៤៥
៣.៥.៨. ដំណោះស្រាយ ..... ៤៦
៣.៥.៩. កត្តាដែលធ្វើឱ្យទិន្នផលមានការកើនឡើង ..... ៤៦
៣.៥.១០. រយៈពេលដាំដុះ ..... ៤៧
៣.៥.១១. ការលក់ចេញនូវទិន្នផលដែលទទួលបាន ..... ៤៧
៣.៦. ការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែសុវត្ថិភាព ..... ៤៧
៣.៦.១. ចំណាយសរុបជាមធ្យមទៅលើការដាំដុះបន្លែសុវត្ថិភាព ..... ៤៧

៣.៦.២. ចំណូលជាមធ្យមទៅពីការដាំបន្លែបន្លែសុវត្ថិភាព ........ ៤៨
៣.៦.៣. ប្រាក់ចំណេញ ឬខាតជាមធ្យមក្នុងការដាំដុះបន្លែសុវត្ថិភាព ........ ៤៨
៣.៦.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការដាំដុះបន្លែសុវត្ថិភាព ........ ៤៩
៣.៦.៤.១.ប្រសិទ្ធភាពក្នុងមួយឯកតាទុនផលិតកម្ម ........ ៤៩
៣.៦.៤.២. ប្រសិទ្ធភាពកម្លាំងពលកម្ម ........ ៤៩
៣.៦.៤.៣. ប្រសិទ្ធភាពដីធ្លី ........ ៥០
៣.៦.៥. ការវិភាគចំណុចស្រង់ដើម ........ ៥០
៣.៧. មូលហេតុនៃការដាំដុះបន្លែសុវត្ថិភាព ........ ៥១
៣.៨. ការប្រៀបធៀបទិន្នផល និងជីវភាពកសិករក្រោយពីការដាំបន្លែសុវត្ថិភាព ........ ៥១
៣.៩. ការវិភាគ SWOT នៃដំណាំបន្លែសុវត្ថិភាព ........ ៥២

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........ ៥៥
២. អនុសាសន៍ ........ ៥៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| ពាក្យអក្សរកាត់ | | ការសម្រាយ |
|---|---|---|
| % | : | ភាគរយ |
| ម² | : | ម៉ែត្រការេ |
| ម.ម | : | មីលីម៉ែត្រ |
| គ.ក | : | គីឡូក្រាម |
| ហ.ត | : | ហិចតា |
| P | : | Price (ថ្លៃ) |
| Q | : | Quantity(បរិមាណ) |
| TC | : | Total Cost(ចំណាយសរុប) |
| TR | : | Total Revenue(ចំណូលសរុប) |
| SWOT | : | Strength Weakness Opportunity Treats |

# បញ្ជីតារាង

តារាងទី២.១៖ ការបង្ហាញអំពីចំនួនភូមិ និងផ្ទៃដីគិតជា ហ.ត ..........២៣
តារាងទី២.២. ការបង្ហាញអំពីស្ថិតិប្រជាពលរដ្ឋក្នុងឃុំ ប្រចាំឆ្នាំ២០១៩ ..........២៤
តារាងទី៣.១៖ ការបង្ហាញអំពីភេទរបស់មេគ្រួសារដែលជាកសិករ..........៣៤
តារាងទី៣.២៖ ការបង្ហាញអំពីក្រុមអាយុរបស់មេគ្រួសារដែលជាកសិករ ..........៣៥
តារាងទី៣.៣៖ ការបង្ហាញអំពីចំនួនសមាជិកគ្រួសាររបស់កសិករដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល. ៣៧
តារាងទី៣.៤៖ ការបង្ហាញអំពីចំនួនពលកម្មរបស់គ្រួសារនីមួយៗក្នុងការដាំបន្លែសុវត្ថិភាព .......... ៣៧
តារាងទី៣.៥៖ ការបង្ហាញអំពីរយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព..........៣៩
តារាងទី៣.៦៖ ការបង្ហាញអំពីផ្ទៃដីក្នុងការដាំដុះបន្លែសុវត្ថិភាព.......... ៤០
តារាងទី៣.៧៖ ការបង្ហាញអំពីភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ .......... ៤១
តារាងទី៣.៨៖ ការបង្ហាញអំពីកម្មសិទ្ធិផ្ទៃដីដាំដុះ .......... ៤១
តារាងទី៣.៩៖ ការបង្ហាញអំពីប្រភពដើមទុន ..........៤២
តារាងទី៣.១០៖ ការបង្ហាញអំពីប្រភពនៃជំនាញបច្ចេកទេសដាំដុះ..........៤២
តារាងទី៣.១១៖ ការបង្ហាញអំពីប្រភពគ្រាប់ពូជ..........៤៣
តារាងទី៣.១២៖ ការបង្ហាញអំពីប្រភពទឹកស្រោចស្រព ..........៤៣
តារាងទី៣.១៣៖ ការបង្ហាញអំពីបរិមាណទឹកសម្រាប់ប្រើប្រាស់ ..........៤៣
តារាងទី៣.១៤៖ ការបង្ហាញអំពីប្រភេទជីដែលប្រើប្រាស់ក្នុងផលិតកម្មបន្លែសុវត្ថិភាព.......... ៤៤
តារាងទី៣.១៥៖ ការបង្ហាញអំពីបញ្ហាប្រឈមក្នុងការដាំដុះបន្លែសុវត្ថិភាព .......... ៤៤
តារាងទី៣.១៦៖ ការបង្ហាញអំពីកត្តាដែលធ្វើឱ្យទិន្នផលមានការកើនឡើង.......... ៤៥
តារាងទី៣.១៧៖ ការបង្ហាញអំពីចំណាយសរុបជាមធ្យមរបស់កសិករទៅលើការដាំបន្លែសុវត្ថិភាព.......... ៤៦
តារាងទី៣.១៨៖ ការបង្ហាញអំពីចំណូលជាមធ្យមក្នុង១វដ្តផលិតកម្មដំណាំបន្លែសុវត្ថិភាពរបស់កសិករ ....៤៧
តារាងទី៣.១៩៖ ការបង្ហាញអំពីចំណេញសរុបជាមធ្យមគិតក្នុង១វដ្តផលិតកម្មរបស់កសិករដាំបន្លែសុវត្ថិភាព ..........៤៧
តារាងទី៣.២០៖ ការបង្ហាញអំពីជីវភាពគ្រួសាររបស់កសិករ .......... ៥០

# បញ្ជីក្រាហ្វិក

ក្រាបទី៣.១៖ ការបង្ហាញអំពីប្រភេទបន្លែសុវត្ថិភាពដែលកសិករដាំដុះ..........៣៩

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

កម្ពុជា ជាប្រទេសមួយដែលពឹងផ្អែកទៅលើវិស័យកសិកម្មជាសំខាន់ ព្រោះប្រជាជនប្រមាណ ៨០% ទៅ ៨៥%ជាកសិករ ហើយវិស័យកសិកម្មផ្តល់ចំណូល៥០%នៃចំណូលជាតិសរុប។ ផលិតផលមានដំណាំរួមផ្សំ ៦៣% ការចិញ្ចឹមសត្វ ២៤% ការនេសាទ ១០% និងព្រៃឈើ ៣%។ ដូច្នេះបញ្ជាក់ឱ្យឃើញថា ប្រជាជនកម្ពុជាមានកម្រិតជីវភាពទាបនៅឡើយ។

ប្រជាជនកម្ពុជាយើងភាគច្រើនរស់នៅតាមទីជនបទ ហើយប្រកបរបរកសិកម្ម ដែលយើងឃើញថាភាគច្រើនពួកគាត់ប្រកបរបរដាំដំណាំស្រូវ ក្រៅពីនេះមានការដាំបន្លែ ចិញ្ចឹមសត្វ និងនេសាទ។

ការដាំបន្លែជាមុខរបរដ៏សំខាន់មួយបន្ទាប់ពីដំណាំស្រូវ ដែលកសិករមួយចំនួនក្នុងក្នុងបណ្តាខេត្តនៃប្រទេសកម្ពុជាយើងកំពុងតែពេញនិយមធ្វើការដាំដុះ ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ។ ប្រាក់ចំណូលនៃការដាំបន្លែទាំងនោះ បានរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរវិជ្ជមានដល់ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសកសិករនៅតាមសហគមន៍ដំណាំ។

កសិករកម្ពុជា បានខិតខំរិះរកគ្រប់មធ្យោបាយដោយប្រើបច្ចេកទេសកសិកម្មបែបប្រពៃណីរួមផ្សំនិងបច្ចេកទេសកសិកម្មបែបទំនើប ក្នុងទិសដៅបង្កើនទិន្នផលនិងផ្គត់ផ្គង់សេចក្តីត្រូវការរបស់ប្រជាជនក្នុងស្រុកក៏ដូចជាការនាំចេញទៅក្រៅប្រទេសផងដែរ។ ដើម្បីដើរឱ្យទាន់តម្រូវការទីផ្សារ ប្រជាកសិករបានខិតខំប្រឹងប្រែងដាំដុះនូវដំណាំជាច្រើនប្រភេទដូចជា ស្រូវ ពោត ដំឡូង ព្រមទាំងបន្លែគ្រប់ប្រភេទផងដែរ។ យើងដឹងហើយថា ដំណាំបន្លែគឺជាប្រភពម្ហូបអាហារមួយយ៉ាងសំខាន់ ដែលប្រជាជននិយមដាំដុះទៅតាមតំបន់រៀងៗខ្លួនទូទាំងប្រទេស។ ពីមុនដំណាំបន្លែគ្រាន់តែដាំជាលក្ខណៈគ្រួសារសម្រាប់ផ្គត់ផ្គង់តម្រូវការផ្ទាល់ខ្លួនប៉ុណ្ណោះ ប៉ុន្តែដោយសារបច្ចុប្បន្នមានតម្រូវការច្រើននៅលើទីផ្សារទើបធ្វើឱ្យកសិករវិវត្តន៍ខ្លួនពីកសិកម្មខ្នាតតូចទៅខ្នាតធំ ដើម្បីទទួលបានប្រាក់ចំណូល។

## ២. ចំណោទបញ្ហា

សព្វថ្ងៃនេះ ដំណាំបន្លែគឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់បំពេញតម្រូវការម្ហូបអាហាររបស់ប្រជាជនទូទៅ និងជាផ្នែកដែលជួយជម្រុញឱ្យជីវភាពគ្រួសារមានការរីកចម្រើន។ ក្នុងនោះដែរ ការដាំបន្លែសុវត្ថិភាពរបស់សហគមន៍មួយដែលស្ថិតនៅក្នុងឃុំស្វាយប្រទាល ស្រុងស្អាង ខេត្តកណ្តាល ត្រូវបានលើកយកមកសិក្សា តើការដាំដុះបន្លែសុវត្ថិភាពបានជួយលើកកម្ពស់ជីវភាពគ្រួសាររបស់កសិករដល់កម្រិតណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវសម្រេចទៅយ៉ាងរលូន ការកំណត់នូវគោលបំណងឱ្យបានច្បាស់លាស់គឺពិតជាមានសារៈសំខាន់ណាស់។ គោលបំណងទាំងនោះរួមមាន៖

- ស្វែងយល់អំពីស្ថានភាពនៃការដាំដុះបន្លែសុវត្ថិភាពរបស់សហគមន៍កសិករក្នុងឃុំស្វាយប្រទាល
- សិក្សាពីបច្ចេកទេសដាំដុះបន្លែសុវត្ថិភាព
- សិក្សាពីសារៈសំខាន់នៃការដាំបន្លែសុវត្ថិភាព
- សិក្សាពីបញ្ហាប្រឈមនិងដំណោះស្រាយនានា របស់កសិករក្នុងការដាំន្លែសុវត្ថិភាព
- វិភាគអំពីប្រសិទ្ធភាពសេដ្ឋកិច្ចដៃការដាំបន្លែសុវត្ថិភាព
- ការផ្តល់អនុសាសន៍ក្នុងការជម្រុញនូវផលិតភាពដំណាំបន្លែសុវត្ថិភាព។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សានេះ ផ្តោតសំខាន់ទៅលើដំណាំបន្លែសំខាន់ចំនួន៤ប្រភេទដូចជា៖ ស្ពៃចង្កឹះ ស្ពៃក្រញាញ់ ស្ពៃខ្មៅ និងស្ពៃតឿ ដែលជាដំណាំឈានមុខរបស់ប្រជាជន ដែលស្ថិតនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

- ទទួលបានចំណេះដឹង និងបទពិសោធន៍ដើម្បីស្រាវជ្រាវចងក្រងជាឯកសារ
- ទទួលបានបទពិសោធន៍ដើម្បីបង្កើនទំនាក់ទំនងល្អក្នុងសង្គម
- ស្វែងយល់អំពីការប្រកបមុខរបរ និងជីវភាពរស់នៅរបស់ប្រជាកសិករដែលប្រកបរបរដាំបន្លែសុវត្ថិភាពនៅក្នុងឃុំស្វាយប្រទាល
- ជាឯកសារដើម្បីជំនួយដល់ការសិក្សាស្វែងយល់ និងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវបន្ត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវមានប្រសិទ្ធភាព និងទទួលបានលទ្ធផលប្រសើរលុះត្រាតែយើងដឹងពីចំនួនសំណាក ដែលមានភាពច្បាស់លាស់យកមកសិក្សាស្រាវជ្រាវ។ យើងបានដឹងហើយថាឃុំស្វាយប្រទាលប្រជាជនតាមភូមិនីមួយៗ ស្ទើរតែ ៧០ភាគរយ ប្រកបរបរដាំបន្លែដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ដូច្នេះទើបឃុំនេះត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ។

វិធីសាស្ត្រដែលត្រូវយកមកសិក្សាដើម្បីជ្រើសរើសសំណាកដើម្បីយកមកសិក្សាស្រាវជ្រាវ គឺប្រើតាមរូបមន្ត Yamane (1967) ៖

$$n = \frac{N}{1 + N(e^2)}$$

N: ចំនួនគ្រួសារសរុបក្នុងឃុំទាំងមូលស្មើនឹង ៣,៦៣៩ នាក់

n: ចំនួនសំណាកក្នុងឃុំសរុបដែលត្រូវធ្វើការសម្ភាស

e: កម្រិតលម្អៀងសន្មតយក ២២%

យើងបាន $$n = \frac{៣,៦៣៩}{១+៣,៦៣៩(0.២២^{២})} = ២0\%$$

ដូចនេះ ចំនួនសំណាកសរុបដែលត្រូវយកមកសម្ភាសមានចំនួន ២០ គ្រួសារ។

ប្រភពទិន្នន័យដែលត្រូវការចំបាច់សម្រាប់ការស្រាវជ្រាវ រួមមានទិន្នន័យដែលមានស្រាប់ និងទិន្នន័យដែលទទួលបានមកពីការអង្កេតសម្ភាសជាមួយប្រជាកសិករផ្ទាល់ តាមរយៈការប្រើប្រាស់កម្រងសំណួរ។

ទិន្នន័យដែលមានស្រាប់ ជាទិន្នន័យដែលទទួលបានមកពីឯកសារ និងរបាយការណ៍នានា ដែលមានភាពច្បាស់លាស់ និងពិតប្រាកដ ដែលរួមមាន៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្មខេត្តកណ្តាល
- របាយការណ៍ស្តីអំពីស្ថានភាពភូមិ-ឃុំដែលត្រូវចុះទៅស្រាវជ្រាវផ្ទាល់។

ចំណែកឯទិន្នន័យចម្បងក្នុងការស្រាវជ្រាវ គឺយើងទទួលបានមកពីការចុះអង្កេតផ្ទាល់ ដោយសម្ភាសជាមួយប្រជាកសិករផ្ទាល់ ដោយប្រើប្រាស់កម្រងសំណួរដើម្បីសួរ ដែលត្រូវបានត្រៀមរួចជាស្រេច។

រាល់ទិន្នន័យដែលប្រមូលបានតាមរយៈឯកសារឬរបាយការណ៍ពាក់ព័ន្ធនានា ការដូចជាការសម្ភាសន៍ផ្ទាល់ជាមួយប្រជាកសិករ ត្រូវបានយកមកវិភាគក្នុង SPSS ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការចងក្រង និងរៀបចំសារណាបទនេះ ធ្វើឡើងដោយចែកជាបីជំពូកដូចខាងក្រោម៖

- **ជំពូកទី១ រំលឹកទ្រឹស្តី៖** សិក្សាជុំវិញទៅលើទ្រឹស្តីកសិកម្មនានា ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច ទ្រឹស្តីនិងកត្តាពាក់ព័ន្ធសំខាន់ៗនានានៃដំណាំបន្លែនៅកម្ពុជា និងទ្រឹស្តីពាក់ព័ន្ធនឹងការវិភាគសេដ្ឋកិច្ច។
- **ជំពូកទី២ ស្ថានភាពទូទៅនៃការដាំដុះបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល៖** សិក្សាអំពីតំបន់ភូមិសាស្ត្រនៃតបន់ស្រាវជ្រាវ ព្រមទាំងស្ថានភាពផលិតកម្ម និងដំណើរការដាំដុះដំណាំបន្លែសុវត្ថិភាពរបស់ប្រជាជន។
- **ជំពូកទី៣ ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ៖** សិក្សាស្រាវទៅលើទិន្នន័យប្រជាសាស្ត្រ ការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃការលើកស្ទួយជីវភាពគ្រួសារតាម រយៈការដាំបន្លែសុវត្ថិភាពនៅតំបន់នោះ និងស្វែងយល់ពីចំណូល ចំណាយជាមធ្យមពីការដាំដុះបន្លែក្នុងមួយវដ្តផលិតកម្ម ព្រមទាំងធ្វើការវិភាគ SWOT នៃការដាំបន្លែសុវត្ថិភាពនោះផងដែរ។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ការសន្និដ្ឋានជារួមទៅលើការសិក្សាស្រាវជ្រាវ និងផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីកែលម្អ និងអភិវឌ្ឍការដាំបន្លែក្នុងឃុំស្វាយប្រទាលឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ដើម្បីលើកកម្ពស់ជីវភាពគ្រួសារប្រជាកសិករឱ្យកាន់តែប្រសើរឡើង។

# ជំពូកទី១
# រំលឹកទ្រឹស្ដី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ទ្រឹស្តីកសិកម្ម

### ១.១.១. និយមន័យកសិកម្ម

កសិកម្ម ត្រូវបានគេឱ្យនិយមន័យជាច្រើនផ្សេងៗគ្នា ទៅតាមគំនិតរៀងៗខ្លួន របស់បុគ្គលជាច្រើនមកពីតំបន់ផ្សេងៗគ្នា ហើយនិយមន័យទាំងនោះខ្លះក៏ស្រដៀងគ្នា ឯខ្លះក៏ខុសគ្នាផងដែរ។ យ៉ាងណាមិញ តាមរយៈការសំយោគនូវគំនិតទាំងនោះ យើងឃើញថា និយមន័យកសិកម្មត្រូវបានឃើញគេនិយមកំណត់ដូចខាងក្រោម៖

- កសិកម្ម គឺជាវិទ្យាសាស្ត្រ ឬសិល្បៈនៃការអនុវត្តន៍ការដាំដុះដើម្បីផលិតដំណាំ និងចិញ្ចឹមសត្វ ក៏ដូចជាការនេសាទ និងការលក់ចេញនៃផលិតផលដែលសម្រេចបានទៅកាន់ទីផ្សារ ដើម្បីទទួលបាននូវប្រាក់ចំណេញ។ ន័យនេះចង់បង្ហាញថា មនុស្សធ្វើកសិកម្មតាមរូបភាពផ្សេងៗពីគ្នា និងបច្ចេកទេសផ្សេងៗគ្នា ខ្លះដាំដំណាំ ខ្លះចិញ្ចឹមសត្វ ឯខ្លះទៀតប្រកបរបរនេសាទ ដើម្បីផ្គត់ផ្គង់តម្រូវការរបស់មនុស្សព្រមទាំងស្វែងរកប្រាក់ចំណេញផងដែរ[១]។
- កសិកម្មគឺជាការអនុវត្តជាប្រព័ន្ធនៃការប្រើប្រាស់ដីដើម្បីដាំដំណាំផ្លែឈើ បន្លែនិង ការចិញ្ចឹមនិងការគ្រប់គ្រងសត្វពាហនៈ។ ពាក្យកសិកម្មត្រូវបានមកពីឡាតាំង Agriculture (Agri + Culture) ដែល Agri មានន័យថាដី និង Culture មានន័យថាវប្បធម៌។ ប្រមាណជា ៥០% នៃចំនួនប្រជាជនពិភពលោកនិង ៧៥% នៃប្រជាជនឥណ្ឌាបានចូលរួមក្នុងសកម្មភាពកសិកម្ម។ ព្រៃឈើនិងនេសាទក៏ស្ថិតនៅក្រោមការអនុវត្តកសិកម្មដែរ។ កសិកម្មបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជនដ៏ធំធេងដូចជាម្ហូបអាហារ ទីជម្រក និងសម្លៀកបំពាក់[២]។

### ១.១.២. ប្រវត្តិកសិកម្ម

ប្រវត្តិកសិកម្មកើតមានតាំងពីយូរលង់ណាស់មកហើយ ហើយក៏ត្រូវបានគេបកស្រាយដូចខាងក្រោមនេះ៖

ប្រវត្តិនៃការបង្កើតកសិកម្ម គឺមានការជាប់ទាក់ទង់និងការផ្សាំងនៃចម្ការ និងសត្វដែលត្រូវបានអភិវឌ្ឍជាង ១២,០០០ ឆ្នាំមកហើយ តែយ៉ាងណាក៏ដោយមនុស្សនៅតែបានចាប់ផ្តើមមានការផ្លាស់ប្តូរឱ្យរុក្ខជាតិនិងសត្វមានការទំនាក់ទំនងគ្នានិងដើម្បីបង្កើតនូវអត្ថប្រយោជន៍ ទៅតាមការបង្កើតដីស្រែតាមរយៈការកាប់ឆ្ការព្រៃដើម្បីឲ្យមានភាពរាបស្មើសម្រាប់ដាំដុះ។ការអភិវឌ្ឍនៃដីស្រែកសិកម្មមុនគេនោះបានកើតមានឡើងនៅទិស

[១] គេហទំព័រ Wikipedia, និយកសិកម្ម(គ្មានកាលបរិច្ឆេទ)

[២] វចនានុក្រម Merriam-Webster, និយមន័យកសិកម្ម (គ្មានការបរិច្ឆេទ)

ខាងជើង និងទិសខាងត្បូងនៃប្រទេសចិនទ្វីបអាហ្វ្រិក ហើយមានពីរបីជាតិសាសន៍ទៀតនៅប្រទេសអាមេរិច។ មនុស្សទាំងនោះរស់នៅជាកុលសម្ព័ន្ធ ហើយពួកគេតែងតែផ្លាស់ទីលំនៅពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីស្វែងរកទីតាំងថ្មីដើម្បី ប្រកបរបរដាំដុះ ចិញ្ចឹមជីវិត ព្រោះពួកគេគិតថាកន្លែងចាស់របស់ពួកគេមិនអាចប្រកបរបរទៅទៀតបាន។ ទម្លាប់នៃការផ្លាស់ប្តូរទីលំនៅរបស់ពួកគេបានធ្វើឱ្យ មនុស្សកាន់តែយល់ដឹងពីរបៀបធ្វើកសិកម្ម ហើយផ្ទៃដីកសិកម្មកាន់តែរីកធំឡើងពាសពេញពិភព លោក ។ នៅពេលដែលពួកគេយល់ដឹងច្រើនពីកសិកម្ម ពួកគេក៏លែងធ្វើការផ្លាស់ប្តូរទៅលំនៅតទៅទៀត ហើយពួកគេក៏មានគំនិតថ្មីក្នុងការធ្វើឱ្យគេអាចដាំដុះបានគ្រប់រដូវកាល ហើយមិនភ័យខ្លាចក្នុងការពិបាកផ្លាស់ទីលំនៅដូចមុន។ ពួកគេចេះបង្កើតជីដោយប្រើប្រាស់កាកសំណល់ពីសត្វនិងរុក្ខជាតិ ចេះបង្កើតប្រព័ន្ធទឹកដើម្បីផ្គត់ផ្គង់ដំណាំរបស់ពួកគេ និងរបៀបទប់ទល់ការគំរាមកំហែងនានា រហូតមកដល់បច្ចុប្បន្ន[៣]។

### ១.១.៣. និយមន័យសេដ្ឋកិច្ចកសិកម្ម

សេដ្ឋកិច្ចកសិកម្មមកពីពាក្យ៖ សេដ្ឋកិច្ច + កសិកម្ម

- សេដ្ឋកិច្ច៖ ជាការសិក្សាអំពីយុទ្ធសាស្ត្រ របៀបប្រើប្រាស់ធនធាន ដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្ស។
- កសិកម្ម៖ ៖ គឺជាសិល្បៈនៃការដាំដុះ ការចិញ្ចឹមសត្វ ការប្រមាញ់ និងនេសាទ ដើម្បីផ្គត់ផ្គង់គ្រួសារ និងលក់ចេញទៅកាន់ទីផ្សារ ដើម្បីស្វែងរកប្រាក់ចំណេញ។

សរុបមក សេដ្ឋកិច្ចកសិកម្ម គឺជាវិទ្យាសាស្ត្រដែលសិក្សាទៅលើការប្រើប្រាស់ និងទាញយកធនធានធម្មជាតិមកប្រើប្រាស់ ដូចជា ព្រៃឈើ ទឹក និងដី កម្លាំងពលកម្មតាមរយៈការដាំដុះ ចិញ្ចឹមសត្វ បរបាញ់ និងនេសាទ ក្នុងគោលបំណងបំពេញតម្រូវការឥតព្រំដែនរបស់មនុស្ស។

សេដ្ឋកិច្ចកសិកម្មគឺជាវិស័យសេដ្ឋកិច្ចដែលត្រូវបានអនុវត្តទាក់ទងនឹងទ្រឹស្តីសេដ្ឋកិច្ចក្នុងការបង្កើនផលិតកម្មកសិកម្ម និងផ្គត់ផ្គង់ផ្នែកម្ហូបអាហារ។ សេដ្ឋកិច្ចកសិកម្មមានឥទ្ធិពលលើគោលនយោបាយស្បៀងអាហារគោលនយោបាយកសិកម្ម និងគោលនយោបាយបរិស្ថាន។[៤]

### ១.១.៤. និយមន័យសហគមន៍កសិកម្ម

សហគមន៍កសិកម្មមកពីពាក្យថា៖ សហគមន៍+កសិកម្ម

- សហគមន៍៖ គឺជា បណ្តុំនៃគ្រួសារ ចាប់ពី២គ្រួសាឡើងទៅដែលរស់នៅប្រមូលផ្តុំនៅទីកន្លែងជាក់លាក់មួយ ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងជីវិតប្រចាំថ្ងៃ។ គេ អាចឲ្យនិយមន័យសហគមន៍ថា

[៣] បណ្ឌិត ឈុន ពហុ, សេដ្ឋកិច្ចកសិកម្ម, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

[៤] បណ្ឌិត ឈុន ពហុ, សេដ្ឋកិច្ចកសិកម្ម, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

គឺជាដំណើរការរួមគ្នា ឬការរស់នៅផ្តុំគ្នា ការប្រជុំភូមិតំបន់ អ្នកស្រុកដែលរស់នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា និងធ្វើការងារអ្វីមួយរួមគ្នាជាប្រយោជន៍រួម ហើយបង្កើតឲ្យមានសហគមន៍។

- កសិកម្ម៖ គឺជាសិល្បៈនៃការដាំដុះ ការចិញ្ចឹមសត្វ ការប្រមាញ់ និងនេសាទ ដើម្បីផ្គត់ផ្គង់គ្រួសារ និងលក់ចេញទៅកាន់ទីផ្សារ ដើម្បីស្វែងរកប្រាក់ចំណេញ។

សរុបមកសហគមន៍កសិកម្ម ជាផ្នែកមួយនៃដំណើរការអភិវឌ្ឍវិស័យកសិកម្ម ដែលប្រមូលផ្តុំក្រុមគ្រួសារកសិករជាច្រើនជាក្រុមមួយ សម្រេចចិត្តរួមគ្នា និងយល់យោគគ្នា ក្នុងការប្រកបរបរកសិកម្មអ្វីមួយ ដូចជាការដាំបន្លែ ស្រូវ ផ្លែឈើ ។ល។ ការបង្កើតជាសហគមន៍កសិកម្ម ពិតជាមានអត្ថប្រយោជន៍ ព្រោះអាចឲ្យកសិករទាំងឡាយ បានចែករំលែក បទពិសោធន៍ និងបច្ចេកទេសគ្នាទៅវិញទៅមក អាចឲ្យកសិករកាន់តែយល់ចិត្តគ្នា ក្នុងគោលដៅប្រកបរបរកសិកម្មទទួលបានជោគជ័យ។[៥]

### ១.១.៥. និយមន័យកសិកម្មគ្រួសារ

កសិកម្មគ្រួសារ មកពីពាក្យថា៖ កសិកម្ម+គ្រួសារ

- កសិកម្ម៖ គឺជាសិល្បៈនៃការដាំដុះ ការចិញ្ចឹមសត្វ ការប្រមាញ់ និងនេសាទ ដើម្បីផ្គត់ផ្គង់គ្រួសារ និងលក់ចេញទៅកាន់ទីផ្សារ ដើម្បីស្វែងរកប្រាក់ចំណេញ។
- គ្រួសារ៖ គឺជាក្រុមមនុស្សដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងសម្រេចមតិរួមគ្នាក្នុងការធ្វើអ្វីមួយ។

សរុបមក កសិកម្មគ្រួសារគឺជា ការប្រកបរបរដាំដុះ ចិញ្ចឹមសត្វ និងនេសាទ ជាលក្ខណៈឯកជនដោយប្រើកម្លាំងពលកម្មរបស់សមាជិកគ្រួសារ ក្នុងគោលបំណងផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន និងស្វែងរកប្រាក់ចំណេញផងដែរ ។

ការធ្វើកសិកម្មគ្រួសារមាន២ ប្រភេទគឺ៖

- មិនស្វែងរកប្រាក់ចំណេញ៖ គឺជាការដាំដុះ ស្រូវ បន្លែបង្ការ ផ្លែឈើ ចិញ្ចឹមសត្វ រឺនេសាទ ដើម្បីផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃ។
- ស្វែងរកប្រាក់ចំណេញ៖ គឺជាការដាំដុះ ស្រូវ បន្លែបង្ការ ផ្លែឈើ ចិញ្ចឹមសត្វ រឺនេសាទ ជាលក្ខណៈកសិដ្ឋាន មានជួលកម្លាំងពលកម្ម ជួលបច្ចេកទេស ដើម្បីបានផលលក់ទៅកាន់ទីផ្សារ និងទទួលបានប្រាក់ចំណេញ។[៦]

### ១.១.៦. តួនាទីកសិកម្មចំពោះសេដ្ឋកិច្ច-សង្គម[៧]

ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កសិកម្មបានដើរតួនាទីយ៉ាងសំខាន់ដូចជា៖

---

[៥] វេបសាយ Wikipedia, និយមន័យសហគមន៍កសិកម្ម, គ្មានការបរិច្ឆេទ

[៦] វេបសាយ Wikipedia, និយមន័យកសិកម្មគ្រួសារ, គ្មានការបរិច្ឆេទ

[៧] បណ្ឌិត ឈុន ពហុ, សេដ្ឋកិច្ចកសិកម្ម, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

- ការផលិតស្បៀងអាហារ៖ សម្រាប់ជាស្បៀងអាហារដល់មនុស្ស-សត្វ។ បើសិនកសិកម្មមានការរីកចម្រើន នោះស្បៀងអាហារក៏មានច្រើនដែរ ធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពល្អប្រសើរ និងមានសុខភាពមាំមួន អាចចូលរួមក្នុងការងារផលិតកម្មសង្គមបានប្រសើរ។
- ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្ម៖ បើកសិកម្មរីកចម្រើន នោះនឹងធ្វើឱ្យឧស្សាហកម្មកែច្នៃ ដែលប្រើប្រាស់វត្ថុធាតុដើមពីកសិកម្ម ក៏មានការរីកចម្រើនដូចគ្នាដែរ។
- ជម្រុញដល់កសិកម្មផលិតគ្រឿងយន្តកសិកម្ម៖ កសិកម្មរីកចម្រើន ក៏តម្រូវផងដែរដល់ការផលិតគ្រឿងយន្តកសិកម្មគ្រប់ប្រភេទ ក៏ដូចជាជី និងថ្នាំសម្រាប់កសិកម្មគ្រប់ប្រភេទ។
- បម្រើឱ្យវិស័យសេវាកម្ម(ជួញដូរ)៖ បើកសិកម្មរីកចម្រើន ក៏បានជួយជម្រុញផងដែរ ដល់ការលូតលាស់ វិស័យសេវាកម្ម ដែលប្រើប្រាស់ផលិតផលកសិកម្មជាគោល ឬជាមធ្យោបាយជួញដូរ។
- នាំមកនូវចំណូលរូបិយប័ណ្ណ៖ កសិកម្មរីកចម្រើន អាចធ្វើឱ្យប្រទេសជាតិទទួលបាននូវរបិយប័ណ្ណបរទេសជាច្រើន តាមរយៈការនាំចេញផលិតផលកសិកម្ម។
- បង្កើតកន្លែងការងារបានច្រើន៖ វិស័យកសិកម្មជាវិស័យដែលអាចបង្កើតកន្លែងការងារយ៉ាងច្រើនសន្ធឹកសន្ធាប់ជូនដល់ប្រជាពលរដ្ឋ ហើយជាប្រភេទការងារជាលក្ខណៈចម្រុះ និងមានជំនាញផ្សេងៗគ្នា ឬក៏គ្មានកម្រិតជំនាញក៏អាចធ្វើការបានផងដែរ។
- ជួយកាត់បន្ថយការចំណាកស្រុក៖កាលណាដែលកសិកម្មមានការរីកចម្រើន នុះនឹងធ្វើឱ្យមានការងារក្នុងស្រុកច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋអាចមានកន្លែងការងារយ៉ាងជាក់លាក់និងគ្មានបំណងចំណាកស្រុកទៅធ្វើការក្រៅប្រទេស ធ្វើឱ្យប្រជាពលរដ្ឋអាចរស់នៅចួបជុំគ្រួសារ យ៉ាងសប្បាយរីករាយ។

### ១.១.៧. ការធ្វើកសិកម្មនៅកម្ពុជា[៨]

ប្រជាជនកម្ពុជាយើងភាគច្រើនរស់នៅតាមជនបទ ហើយប្រកបរបរកសិកម្មដើម្បីចញ្ចឹមជីវិត។ ទោះបីប្រទេសកម្ពុជាមានផ្ទៃដីសម្រាប់ដំណាំស្រូវពី ៨៥% ទៅ ៩០%ក៏ដោយ ក៏គ្រួសារមួយចំនួនផលិតស្រូវពុំបានគ្រប់គ្រាន់តាមតម្រូវការឡើយ។

តាមការស្រាវជ្រាវបានឲ្យដឹងថា ចំនួនគ្រួសារដែលប្រកបរបរកសិកម្មមានប្រមាណពី ១.២លាន ទៅ ១.៣លានគ្រួសារនៅទូទាំងប្រទេស។ គេអាចចែកប្រភេទកសិករទាំងនោះជាប្រភេទធំៗដូចតទៅ ៖

- កសិករផលិតស្រូវ ឬ អ្នកស្រែ ៖ មានចំនួនច្រើនជាងគេក្នុងប្រទេស និងនិយមធ្វើស្រូវវស្សា (រដូវភ្លៀង) លើផ្ទៃដីទំនាប។ កសិករទាំងនោះអាចរកប្រាក់ដើម្បីបង្គ្រប់ចំណូលរបស់ពួកគេដោយការងារផ្សេងៗទៀត (ចិញ្ចឹមសត្វ និង ឡើងត្នោត)ឯកសិករមួយចំនួនទៀត ធ្វើស្រូវប្រដេញទឹក និងស្រូវប្រាំង នៅចុង

[៨] គេហទំព័រ Wikipedia, កសិកម្មនៅកម្ពុជា (គ្មានការបរិច្ឆេទ)

រដូវវស្សា ពេលទឹកស្រកតាមដងទន្លេ មាត់បឹង និងព្រែកនានា។ កសិករទាំងនោះអាចរកប្រាក់បំពេញតម្រូវការរបស់ពួកគេបានដោយស្វែងរកការងារធ្វើតាមរដូវ នៅទីប្រជុំជន ទីក្រុង ការងារកាប់អុស និងធ្វើធ្យូង។

- កសិករនៅតំបន់ដីខ្ពស់ ៖ គេដាំដំណាំ អចិន្ត្រៃយ៍ ឬ តាមរដូវ ដូចជា៖ ពោត ដំឡូង សណ្តែក ល្ង... ។ល។ កសិករខ្លះទៀត ចិញ្ចឹមសត្វ និង ធ្វើស្រូវប្រដេញទឹក។
- កសិករធ្វើចំការ ៖ ពួកគេដាំដំណាំផ្សេងៗនៅតាមបណ្តោយមាត់ទន្លេ ស្ទឹង និងដីទួលនានា ដូចជា ថ្នាំជក់ បន្លែ ផ្កា...។ល។ កសិករទាំងនេះមានការងារបន្ទាប់បន្សំរបស់ពួកគេគឺ ចិញ្ចឹមសត្វ ដាំឈើហូបផ្លែ និងនេសាទ។
- កសិករក្នុងបណ្តាខេត្តភូមិភាគឦសាន (រតនៈគីរី មណ្ឌលគីរី)និងតំបន់ព្រៃភ្នំនានា ច្រើនធ្វើដំណាំព្រៃដុត មាន ស្រូវ ពោត ដំឡូង និងរុក្ខជាតិផ្តល់មើមជាដើម។ ក្រៅពីនេះពួកគេស្វែងរកអនុផលព្រៃឈើ និង បរបាញ់សត្វ។

ក្នុងវិស័យកសិកម្មកម្ពុជា ស្ត្រីបានដើរតួនាទីសំខាន់ណាស់បន្ថែមលើការងារផ្ទះសំបែង (ដាំបាយ បុកកិនស្រូវ ដងទឹក រកអុស និងថែទាំកូនចៅ)។ ស្ត្រី ត្រូវដាំដំណាំ ប្រមូលផល មើលថែទាំសត្វពាហនៈ និងត្រូវទៅលក់ផលិតផលនៅឯទីផ្សារទៀតផង។

កម្ពុជាមានផ្ទៃដីដាំដុះអចិន្ត្រៃយ៍ទំហំ ៣.៨លានហិចតា ដែលក្នុងនោះ ១.៥លានហិចតាជាតំបន់ដាំដំណាំអចិន្ត្រៃយ៍ ព្រមទាំងមានផ្ទៃដី ១២លានហិចតាជាតំបន់ព្រៃឈើ។

វិស័យកសិកម្មនៅកម្ពុជា ភាគច្រើនគ្របដណ្តប់ដោយកសិករខ្នាតតូច ការធ្វើកសិកម្មនៅលើផ្ទៃដីកសិដ្ឋានធំនៅពុំទាន់មានច្រើននៅឡើយទេ។ កសិករភាគច្រើនជាម្ចាស់លើដីស្រែរបស់ពួកគេផ្ទាល់ ខណៈដែលកសិករពុំមានដីធ្លីមានតែប្រមាណ ១៣% ទៅ១៥% នៃគ្រួសារកសិករសរុប។

## ១.២. ទ្រឹស្តីនៃការអភិវឌ្ឍសេដ្ឋកិច្ច

### ១.២.១. និយមន័យការអភិវឌ្ឍ

ពាក្យ ថា ការអភិវឌ្ឍ ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ទាំងផ្នែកនយោបាយ ផ្នែកសង្គម ផ្នែកនីតិសាស្ត្រ ផ្នែកវប្បធម៌ ផ្នែកសិល្បៈ ផ្នែកបរិស្ថាន ផ្នែកបច្ចេកវិទ្យា ជាពិសេសគឺផ្នែកសេដ្ឋកិច្ច។
និយមន័យសេដ្ឋកិច្ច ត្រូវបានគេបកស្រាយអត្ថន័យជាច្រើនផ្សេងៗគ្នា ដោយអ្នកប្រាជ្ញជាច្រើន ដូចខាងក្រោម៖

លោក WALT W. ROSTOW បានបកស្រាយថា ការអភិវឌ្ឍគឺជាការផ្លាស់ប្តូរជីវិតពីការរស់នៅបែបប្រពៃណី ទៅកាន់ជីវិតរស់នៅបែបទំនើប។ លោកបានយកចិត្តទុកដាក់លើការអភិវឌ្ឍជាតិតាមបែបជាជំហាន

ដែលលោកបានកំណត់ថារាល់ដំណាក់កាលនៃការអភិវឌ្ឍនៃជាតិនីមួយៗត្រូវឆ្លងកាត់តាមដំណាក់កាលទាំងនេះ រួមមាន៖

- សង្គមបែបបុរាណ
- សង្គមត្រៀមលក្ខណៈឈានឡើង
- ដំណាក់កាលស្ទុះឡើង
- ដំណាក់កាលឈានទៅរកការអភិវឌ្ឍ
- ដំណាក់កាលអភិវឌ្ឍន៍។[៩]

លោក HARROD DOMAR បានលើកឡើងថាការអភិវឌ្ឍគឺជាការបង្កើននូវកម្រិតសន្សំ កាលណាដែលកម្រិតសន្សំកើនឡើង នោះសេដ្ឋកិច្ចនឹងមានការអភិវឌ្ឍ។ លោកបានឱ្យតម្លៃលើការសន្សំដែលជាមូលធនក្នុការវិនិយោគសម្រាប់ជាកម្ចីដល់ក្រុមហ៊ុនសហគ្រាស ហើយលោកក៏បាននិយាយថា អត្រាកំណើនសេដ្ឋកិច្ចត្រូវផ្អែកលើ៖

- កម្រិតនៃការសន្សំ និងអត្រានៃការសន្សំ
- ផលិតភាពនៃការវិនិយោគ។[១០]

### ១.២.២. គោលបំណងនៃការអភិវឌ្ឍន៍

គោលបំណងនៃការអភិវឌ្ឍគឺជាការធ្វើឱ្យប្រសើរឡើងនូវគុណភាពរស់នៅរបស់មនុស្ស ដែលបង្ហាញដោយគោលបំណងបីយ៉ាងគឺ៖

- ធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅ និងគុណភាពរស់នៅរបស់មនុស្ស
- ធ្វើឱ្យមនុស្សមានការអប់រំ មានចំណេះដឹង នោះនឹងនាំឱ្យមនុស្សមានការងារល្អធ្វើ ទទួលបានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ
- ធ្វើឱ្យសេដ្ឋកិច្ចប្រទេសមានការរីកចម្រើន មានសក្តានុពលធនធានមនុស្ស ក្នុងការប្រកួតប្រជែងលើឆាកអន្តរជាតិ។

## ១.៣. និយមន័យបន្លែ

បន្លែ គឺជាផ្នែកមួយនៃដំណាំរុក្ខជាតិ ដែលត្រូវបានប្រើប្រាស់ដោយមនុស្សគ្រប់គ្នាសម្រាប់ធ្វើជាម្ហូបអាហារប្រចាំថ្ងៃដើម្បីចញ្ចឹមជីវិត។

## ១.៤. សារៈសំខាន់នៃការដាំដុះបន្លែ

ការដាំដុះបន្លែមានសារៈសំខាន់ដូចខាងក្រោម៖

[៩] WALT Whitman ROSTOW, Theory of Economic Growth, 1990

[១០] HARROD-DOMAR, Economic Growth, 1985

- មានសារៈសំខាន់ចំពោះម្ហូបអាហារ ព្រោះបន្លែផ្ទុកនូវសារធាតុចិញ្ចឹមជាច្រើន
- ការដាំបន្លែជួយលើកកម្ពស់ជីវភាពគ្រួសារប្រជាកសិករ
- ការដាំបន្លែជួយឱ្យប្រជាជនទទួលបានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ
- ការដាំបន្លែបានជួយបង្កើតការងារដល់ប្រជាជន ដែលបណ្តាលឱ្យមានតំហាយនៃការធ្វើចំណាកស្រុក
- ការដាំបន្លែបានធ្វើឱ្យការប្រើប្រាស់ដីក៏ដូចជាកម្លាំងពលកម្មអស់ពីប្រសិទ្ធភាព។

### ១.៤.១.សារៈសំខាន់ផ្នែកម្ហូបអាហារ និងសុខភាព

បន្លែជាម្ហូបអាហារមួយដែលមានសារសំខាន់សម្រាប់មនុស្ស ពីព្រោះបន្លែពណ៌បៃតងមានផ្ទុកនូវសារធាតុដែក និងជីវជាតិដែលជាសារធាតុចិញ្ចឹមជាច្រើមដែលមនុស្សត្រូវការ ដើម្បីធ្វើឲ្យភាពធន់របស់រាងកាយតស៊ូក្នុងការធ្វើសកម្មភាពនានា។ ម្យ៉ាងទៀតសម្រាប់អ្នកដែលមានជាតិដែកគ្រប់គ្រាន់ ពួកគេមិនងាយនឹងអស់កម្លាំងលឿនពេក និងខ្សោយ នៅពេលកំពុងបំពេញការងារទេ។ ដូច្នេះអ្នកត្រូវតែទទួលទានបន្លែឲ្យបានច្រើន។ បន្លែជាច្រើនប្រភេទមាន ឬក៏ផ្ទុកនូវសារជាតិដែក ជាពិសេសបន្លែដែលមានពណ៌បៃតង។ សារជាតិដែកដែលផ្តល់នៅក្នុងបន្លែពណ៌បៃតងមានគុណប្រយោជន៍យ៉ាងច្រើនសម្រាប់មនុស្ស។ ដោយសារតែជាតិដែកអាចជួសជុលជាតិក្រហមនៃឈាម (hemoglobin) ឬក៏ជំងឺរយៈពេលខ្លីបាន។[១១]

ជីវជាតិសំខាន់នៅក្នុងបន្លែដែលមានសារៈប្រយោជន៍សម្រាប់ទ្រទ្រង់សុខភាពមនុស្សមាន៖[១២]

- បន្លែពណ៌បៃតងមានផ្ទុកនូវសារធាតុ hytochemicals ដែលរួមមាន carotenoids, indoles និង saponins ដែលមានផ្ទុកនូវសារធាតុប្រឆាំងនឹងជំងឺមហារីក។ បន្លែដែលមានស្លឹកពណ៌បៃតងដូចជាស្ពៃចង្កឹះ និងខាត់ណាក៏ជាប្រភពផ្តល់នូវ folate ដ៏ល្អបំផុតដែរ។
- Lutein ធ្វើការជាមួយ zeaxanthin (សារធាតុគីមីពីថម្មជាតិដែលរកឃើញនៅក្នុងពោត ម្រេចក្រហម ក្រូច និងទំពាំងបាយជូរ) ដើម្បីរក្សាភ្នែកឱ្យមានសុខភាពល្អ (កាត់បន្ថយហានិភ័យពីជំងឺភ្នែកឡើងបាយ និងការចុះខ្សោយនៃគ្រាប់ភ្នែក។
- សារធាតុ Indoles (សារធាតុគីមីដែលកើតឡើងពីធម្មជាតិ) ដែលមាននៅក្នុងខាត់ណា ស្ពៃក្តោប និងបន្លែបៃតងផ្សេងៗទៀតប្រហែលជាអាចជួយប្រឆាំងនឹងប្រភេទនៃជំងឺមហារីកមួយចំនួន។
- សារធាតុ Isothiocyanates ដែលជម្រុញអង់ស៊ីមនៅក្នុងថ្លើមជួយដល់រាងកាយនៅក្នុងការលុបបំបាត់សមាសភាពដែលអាចបង្កជាជំងឺមហារីក

[១១] ឆាយ សុផល, ព័តមានសុខភាព, (២៥ ឧសភា ២០១១)

[១២] គេហទំព័រ អេអាយអេ, សុខភាព, (ឆ្នាំ២០១៩)

- ស្ពៃចង្កឹះ និងខាត់ណាជាប្រភពផ្តល់នូវ folate ដ៏ល្អបំផុត ជាប្រភេទវីតាមីនបេមួយប្រភេទដែលជួយកាត់បន្ថយគ្រោះថ្នាក់ពិការភាពពីកំណើត ហើយវាក៏សម្បូរទៅដោយវីតាមីនកា(ពិសេសនៅក្នុងការកកើតនូវការកកស្ទះសរសៃឈាម) ប៉ូតាស្យូម សារធាតុ carotenoids ខ្លះៗនិងអាស៊ីតខ្លាញ់អូមេហ្គា៣។

### ១.៤.២. សារៈសំខាន់ចំពោះសេដ្ឋកិច្ច និងសង្គម

ក្រៅអំពីអត្ថប្រយោជន៍ចំពោះសុខភាព និងម្ហូបអាហារ បន្លែបានដើរតួនាទីយ៉ាងសំខាន់ចំពោះវិស័យសេដ្ឋកិច្ច។ ក្រៅអំពីការដាំដុះសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ បន្លែដែរនៅសល់គឺអាចលក់ចេញទៅកាន់ទីផ្សារ និងទទួលបានចំណូលតិចឬច្រើនទៅតាមបរិមាណបន្លែដែលលក់ចេញ។ ប៉ុន្តែលើសពីបន្លែដែលនៅសេសសល់ ប្រជាជនកម្ពុជាភាគច្រើនចាប់យកការដាំដុះក្នុងលក្ខណៈជាមុខរបរតែម្តង ពិសេសកសិករដែលនៅខេត្តតាមជាយក្រុង និងជាប់មាត់ទន្លេដូចជា កសិករនៅស្រុកកៀនស្វាយ ស្រុកស្អាង ស្រុកល្វាឯម ខេត្តកណ្តាលជាដើម។ ពួកគេសុទ្ធតែជាអ្នកមានបទពិសោធន៍ក្នុងការដាំបន្លែជាយូរឆ្នាំ ហើយប្រសិនបើមានមធ្យោបាយក្នុងដំណើរការផលិតកម្មគ្រប់គ្រាន់ នោះពួកគាត់នឹងប្រាកដជាទទួលបានចំណូលច្រើន ដែលអាចធ្វើឱ្យជីវភាពរបស់គាត់បានធូរធា។ និយាយជារួម ផលិតកម្មបន្លែអាចរកប្រាក់ចំណូលបានច្រើនគួរសម បើធៀបទៅនឹងដំណាំដទៃទៀតដូចជា ស្រូវ ផ្លែឈើ ដំឡូងជាដើម។

មួយវិញទៀត ការដាំបន្លែជារង្វង់គ្រួសារបានចូលរួមចំណែកក្នុងការកាត់បន្ថយចំណាយប្រចាំថ្ងៃគួរសមដែរក្នុងការទិញបន្លែពីទីផ្សារ និងអាចទទួលបាននូវបន្លែដែរស្រស់និងធម្មជាតិទៀតផង។

នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួន គេដាំបន្លែជាលក្ខណៈកសិដ្ឋាន ដែលមានផ្ទៃដីធំរាប់សិបហិចតា ដែលប្រើបច្ចេកទេសនិងគ្រឿងចក្រទំនើបៗ ដូចជាការប្រើប្រាស់មធ្យោបាយបែបបច្ចុប្បន្ននិងប្រពៃណីរួមបញ្ចូលគ្នា ការប្រើប្រាស់ផលិតផលកសិកម្មក្នុងរោងចក្រឧស្សាហកម្ម ការវេចខ្ចប់ ការដឹកជញ្ជូនតាមនាវា និង រថភ្លើងពីតំបន់មួយទៅតំបន់មួយ ពីប្រទេសមួយទៅប្រទេសមួយបានយ៉ាងឆាប់រហ័ស។

កាលណាប្រជាជនមានប្រាក់ចំណូលគ្រប់គ្រាន់ នោះគុណភាពនៃជីវិតក៏ប្រសើរឡើងផងដែរ ជាកត្តានាំឱ្យមានស្ថេរភាពសង្គម និងសេដ្ឋកិច្ចជាតិមានការរីចម្រើន។

## ១.៥.កត្តាសំខាន់ៗទាក់ទងនិងការដាំដុះ[១៣]

កត្តាសំខាន់ៗទាក់ទងនិងការដាំដុះបន្លែដើម្បីអោយទទួលបានប្រសិទ្ធភាពខ្ពស់គឺ កត្តាអាកាសធាតុ កត្តាទឹក កត្តាដី និងកត្តាជី។

[១៣] បណ្ឌិត ប្រិន រ៉ូវែល និង តាក់អេងឡាយ, ឆ្នាំ ១៩៩២,ដំណាំបន្លែនៅកម្ពុជា

### ១.៥.១. កត្តាអាកាសធាតុ

ប្រភេទឬពូជដំណាំនីមួយៗគឺត្រូវការលក្ខខណ្ឌបរិយាកាសនិងអាកាសធាតុផ្សេងៗគ្នា។ ធាតុអាកាសជាកត្តាយ៉ាងសំខាន់ក្នុងចំណោមកត្តាដទៃទៀត ដែលឥទ្ធិពលក្នុងដាំដុះបន្លែ។ហេតុដូចនេះហើយទើបត្រូវសិក្សាស្វែងយល់អោយច្បាស់ពីប្រភេទឬពូជដំណាំមុននិងសម្រេចចិត្តដាំឬផលិត។

#### ១.៥.១.១.កត្តាសីតុណ្ហភាព

សីតុណ្ហភាពមានឥទ្ធិពលខ្លាំងក្នុងការបណ្តុះគ្រាប់ពូជ និងការលូតលាស់របស់ដំណាំ។ សីតុណ្ហភាពក្តៅឬត្រជាក់ខ្លាំងពេកមិនអំណោយផលដល់លូតលាស់ដល់ដំណាំឡើយ ដើម្បី អោយដំណាំលូតលាស់បានល្អត្រូវជ្រើសរើសដំណាំអោយសមស្របទៅនិងសីតុណ្ហភាព។កត្តាសីតុណ្ហភាព អាចធ្វើអោយគ្រាប់ពូជដុះលឿនឬយឺត ខ្លាំងឬខ្សោយ ឬមិនដុះតែម្តង។

នៅប្រទេសកម្ពុជានាចុងរដូវប្រាំង មានសីតុណ្ហភាពក្តៅខ្លាំង ហើយមានរយៈពេលវែងដែលធ្វើអោយដំណាំមានការលូតលាស់យឺត និងមិនសូវល្អដូចធម្មតា ទាមទារអោយមានការស្រោចទឹកច្រើន។

សីតុណ្ហភាពក្តៅខ្លាំងរាំងស្ទះដល់ដល់ការស្រូបយកជីវជាតិនិងសារធាតុចិញ្ចឹមដើម្បី អោយបំប៉ន់ដើម ស្លឹក ឬស មើម និងផ្នែកផ្សេងៗទៀត។ អាកាសធាតុក្តៅធ្វើអោយប៉ះពាល់ដល់ស្លឹក អាចស្វិតស្រពោន។

សីតុណ្ហភាពមធ្យមប្រចាំឆ្នាំគឺ ២៧ អង្សារសេ ឯពេលវេលាសមស្របល្អក្នុងការដាំបន្លែនៅប្រទេសកម្ពុជាគឺ ចាប់ពីខែ វិច្ឆិកាដល់ខែមករា ពិសេសអំណោយផលដល់បន្លែយកមើម និងពពួកស្ពៃដែលទាមទារសីតុណ្ហភាពត្រជាក់ ពន្លឺគ្រាប់គ្រាន់ គ្មានពពក អាចធ្វើរស្មីសំយោគបានល្អព្រមទាំងសមស្របសម្រាប់ការលូតលាស់ល្អ។

#### ១.៥.១.២.កត្តាទឹកភ្លៀង

ទឹកភ្លៀង ជាកត្តាមួយយ៉ាងសំខាន់សម្រាប់ដំណាំបន្លែទូទៅ ចំនួនទឹកភ្លៀងដែលធ្លាក់ក្នុងមួយឆ្នាំៗជួយជំរុញអោយដំណាំលូតលាស់បានល្អនិងជួយកាត់បន្ថយការចំណាយលើការស្រោចស្រប់ ពិសេសការធ្លាក់រាយទឹកភ្លៀងធ្វើអោយដំណាំទទួលបានរបាយទឹកស្មើៗគ្នា។នៅប្រទេសកម្ពុជាយើង ទឹកភ្លៀងធ្លាក់រាយមិនស្មើគ្នានិងទៀងទាត់នោះទេ គឺយើងមាន ៦ខែជារដូវវស្សា និង៦ខែជារដូវប្រាំង រដូវប្រាំងដែលខ្សត់ទឹកភ្លៀង។ប៉ុន្តែនៅរដូវវស្សាជួនកាលក៏មានជួបប្រទះនិងភាពរាំងស្ងួត ដែលបណ្តាលអោយខូចខាតដល់ផលដំណាំផងដែរ។ ការដាំដុះបន្លែមួយចំនួនពឹងផ្អែកលើទឹកភ្លៀង ប៉ុន្តែនៅរដូវវស្សាពេលខ្លះក៏ធ្វើអោយប៉ះពាល់ដល់ដំណាំខ្លះដែរដូចជា៖

- ស្មៅឆាប់ដុះ
- បន្លែឈ្លក់ទឹកពេលភ្លៀងជោគជាំ
- ដីឆាប់ហាប់

- បាត់បង់ជីតាមរយៈការហូរទៅតាមទឹក
- មានជម្ងឺផ្សិត
- ការប្រើប្រាស់ថ្នាំពេលខ្លះគ្មានប្រសិទ្ធភាព
- កើតមានសត្វល្អិតនិងដង្កូវ

ប៉ុន្តែនៅរដូវប្រាំង ការដាំដុះទាមទារធ្វើអោយបានពីដើមរដូវ និងទាមទារការពារការស្រោចទឹកច្រើន ឬធ្វើការស្រោចនិងបញ្ចូលទឹកជំនួសទឹកភ្លៀង។ នៅចុងរដូវវស្សា ភ្លៀងច្រើនធ្លាក់ខ្លាំងហួស ឯចុងរដូវប្រាំងច្រើនខ្វះទឹក សីតុណ្ហភាពក៏ក្តៅខ្លាំង ការដាំដុះក៏ពុំសូវផ្តល់ផលល្អឡើយ។

ទឹកភ្លៀងខ្លាំងធ្វើអោយដីបាក់ រួចក្រោយមកពេលរាំងស្ងួតធ្វើអោយដីហាប់ណែន អាចបណ្តាលអោយគ្រាន់ពូជមិនដុះ ឯដំណាំខ្លះគ្រាន់តែលូតពន្លកមកក៏ស្លាប់ទៅវិញ។ ម្យ៉ាងវិញទៀត កាលណាភ្លៀងច្រើនធ្វើឱ្យលិចដល់រងដំណាំដែលបណ្តាលឱ្យកសិករមិនអាចដាំដុះបាន។

### ១.៥.១.៣. សំណើមក្នុងបរិយាកាស

សំណើមក្នុងបរិយាកាសក៏មានតួនាទីសំខាន់ដល់ការដាំដុះបន្លែផងដែរ។ សំណើមក្នុងបរិយាកាសមានកម្រិតខ្ពស់នៅពេលមានភ្លៀងច្រើន។រីឯនៅរដូវប្រាំង សំណើមក្នុងបរិយាកាសមានកម្រិតទាប។ ការមើលថៃនិងស្រោចទឹកដល់បន្លែ ក៏អាស្រ័យលើសំណើមក្នុងបរិយាកាសផងដែរ។ កាលណាខ្យល់ក្នុងបរិយាកាសសើមរុក្ខជាតិបន្ថយនូវបំភាយចំហាយទឹក ការត្រូវការទឹករបស់រុក្ខជាតិក៏ថយចុះ នៅចន្លោះខែវិច្ឆិកា ដល់ខែមករាសីតុណ្ហភាពថយចុះ សំណើមក្នុងបរិយាកាសក៏ថយចុះទាបដែរ ជម្ងឺនិងសត្វល្អិតចង្រៃក៏មិនសូវកើតមានដែរ។ នៅចុងរដូវវស្សាមានភ្លៀងខ្លាំងធ្វើអោយសត្វល្អិតចង្រៃមួយចំនួនធំងាប់ ជាហេតុដែលមានការកកើតសត្វល្អិតតិចតួចនៅដើមរដូវប្រាំងមិនសូវមានសភាពខ្លាំងខ្លា។

### ១.៥.១.៤. រយៈពេលយប់ និងថ្ងៃ

រយៈពេលយប់និងថ្ងៃក៏មានឥទ្ធិពលទៅលើការដាំដុះបន្លែផងដែរ។ ប្រភេទដំណាំបន្លែខ្លះត្រូវការរយៈពេលយប់ច្រើនជាថ្ងៃ ឯប្រភេទខ្លះទៀតត្រូវការរយៈពេលថ្ងៃច្រើនជាងយប់ ដើម្បីការលូតលាស់ផ្តល់ផ្លែផ្កា ។តែក៏មានដំណាំប្រភេទខ្លះមិនប្រកាន់រដូវកាលនោះទេ គឺអាចលូតលាស់និងផ្តល់ទិន្នផលបានគ្រប់រដូវកាល។

### ១.៥.២.កត្តាទឹក

នៅប្រទេសកម្ពុជាយើង ដំណាំបន្លែភាគច្រើនដាំនៅតាមដងទន្លេ លើដីសម្បូរជីជាតិ ឬនៅលើដីកោះ។ ចាប់ពីខែសីហា ដល់តុលា ផ្ទៃដីភាគច្រើនត្រូវលិចទឹក ផ្ទៃដីប្រមាណ៦០%ទៅ៧០% ត្រូវបានខកខានដាំដំណាំ។ មានតំបន់ខ្លះត្រូវលិចទឹករយៈពេលចន្លោះពី ២ទៅ៤ខែ ទៅតាមកម្ពស់ដីនិងកម្រិតទឹកខ្ពស់ឬទាប និងមានការផ្លាស់ប្តូរទៅតាមឆ្នាំនីមួយៗ។ ការទទួលបានដីល្បាប់ដែលមានជីវជាតិក៏ប្រែប្រួលទៅតាមនិងដែរ។ជាទូទៅបន្លែមួយចំនួនធំដាំបណ្តោញទឹកនៅខែទឹកស្រក គឺចាប់ខែ ចុងខែតុលាឬនៅដើមខែវិច្ឆិកា។ ដើម្បី

ចំណោញពេលវេលាប្រជាកសិករមួយចំនួនបានអនុវត្តការសាបកូនបន្លែនៅលើដីខ្ពស់ រួចហើយយកទៅសាបលើដី បន្ទាប់ពីទឹកចាប់ផ្តើមស្រក ការធ្វើបែបនេះគឺចំណោញពេលវេលា។

ចំពោះដំណាំបន្លែមួយចំនួនដែលត្រូវការទឹកគ្រប់គ្រាន់ និងត្រូវការទឹកជាប្រចាំ គឺត្រូវដាំនៅជាប់ប្រភពទឹកដូចជា នៅក្បែរមាត់ទន្លេ បឹងបួរ ត្រពាំង ស្រះ ឬត្រូវការជីកអណ្តូងដើម្បីងាយស្រួលស្រោចស្រព។

ចំពោះដំណាំបន្លែមួយចំនួនដែលមិនសូវត្រូវការទឹកស្រោចជាប្រចាំ អាចដាំដោយមិនចាំបាច់ស្រោចទឹក ប៉ុន្តែត្រូវដាំនៅលើប្រភេទដីដែលរក្សាទឹកបានយូរអាចឲ្យរុក្ខជាតិរស់បាន។

ជារួមទឹកគឺជាប្រភពយ៉ាងសំខាន់ដែលដំណាំបន្លែត្រូវការជាចាំបាច់ដើម្បីលូតលាស់ រស់រានមានជីវិត ផ្តល់ផលជាផ្លែផ្កា ប៉ុន្តែបរិមាណទឹកច្រើនលើសលុបពេកក៏ជាបញ្ហាដល់ដំណាំវិញដែរ។ កាលណាដែលមានភ្លៀងធ្លាក់ច្រើនពេកធ្វើឱ្យពិបាកក្នុងការរំដោះទឹកចេញ ដែលជាហេតុនាំឱ្យប៉ះពាល់ដល់ដំណាំដូចជាការលិចលង់ជាដើម។

**១.៥.៣. ភក្តាដី**[១៤]

ដីសំដៅផ្នែកខាងលើដែលឫសបន្លែចាក់ចូល និងស្រូបយកជីវជាតិ។លក្ខណៈទ្រង់ទ្រាយទំហំម៉ូលេ-គុល និងសមាសភាពគីមីរបស់ដីដែលមានសារៈសំខាន់ណាស់ក្នុងការជ្រើសរើសប្រភេទដំណាំមកដាំដុះ។

គេចែកដីជា៣ប្រភេទ គឺដីខ្សាច់ ដីឥដ្ឋ និងដីល្បាយ (ឬដីកណ្តៀង)

- គ្រាប់ដីដែលមានអង្កត់ផ្ចិត ពី ០.០៥ ម.ម ទៅ ២ ម.ម ហៅថាដីខ្សាច់
- គ្រាប់ដីដែលមានអង្កត់ផ្ចិតតូចជាង ០.០០២ ម.ម ហៅថាដីឥដ្ឋ
- គ្រាប់ដីដែលមានអង្កត់ផ្ចិត ពី ០.០០២ ម.ម ទៅ ០.០៥ ម.ម ហៅថាល្បាយ ឬដីកណ្តៀង

ដំណាំបន្លែទាមទារដីមានជីវជាតិច្រើន និងជាប្រភេទដីដែលមិនជូរពេក ឬអាល់កាឡាំងខ្លាំងពេកគឺជាទូទៅ pH ពី ៦.៥ ទៅ ៧.៥ ។ យោងទៅលើ pH គេកំណត់ប្រភេទដីដូចខាងក្រោម

- pH ៤ ទៅ ៥ ដីជូរខ្លាំង
- pH ៥ ទៅ ៦ ដីជូរបន្តិច
- pH ៧ ដីណឺត
- pH ៧.៥ ទៅ ៨ ដីអាល់កាឡាំបន្តិច
- pH លើសពី៨ ដីអាល់កាឡាំខ្លាំង (មានជាតិកំបោរច្រើន)

ជាទូទៅដីនៅតាមមាត់ទន្លេមាន pH =៦.៥ ទៅ ៧.៥ ចំពោះបាតបឹង pH ភាគច្រើនទាបគឺអាចធ្លាក់ដល់ pH =៤ ទៅ ៥ ។ pH ពី ៥.៥ ទៅ ៦ អាចឲ្យត្រាវ ម្ទេស ស្ពៃ ប៉េងបោះ និងត្រសក់លូតលាស់បាន។

[១៤] ការអប់រំបំណិនជីវិតផ្នែកកសិកម្ម, ការដាំដំណាំបន្លែសរីរាង្គ, ឆ្នាំ២០១៣

### ១.៥.៤. កត្តាដី

បន្លែជាប្រភេទដំណាំដែលមានឫសខ្លី ដែលមិនអាចស្រូបយកជីវជាតិពីក្នុងដីបានជ្រៅឡើយ ដើម្បីឱ្យបន្លែទទួលបានសារធាតុចិញ្ចឹមគ្រាប់គ្រាន់យើងអាចបន្ថែមជីពីលើ។ ជីដែលមានសុវត្ថិភាពមិនធ្វើឲ្យប៉ះពាល់ដល់សុខភាព និងធ្វើឲ្យខូចគុណភាពដី មាន៣ប្រភេទ គឺ ជីលាមកសត្វ ជីកំប៉ុស្ដ និងជីស្រស់។

ចំពោះបន្លែយកស្លឹក ទាមទារត្រូវដាក់ជីដែលមានជាតិអាសូតច្រើន ឯបន្លែយកផ្លែទាមទារជីដែលមានជាតិផូស្វាតច្រើន និងបន្លែយកមើមទាមទារយកជាតិប៉ូតាស្យូមច្រើន ដើម្បីផ្ដល់ទិន្នផលខ្ពស់។

កម្រិតជី មានការប្រែប្រួលទៅតាមប្រភេទដីនិងប្រភេទបន្លែទៅតាមដំណាក់កាលនៃការលូតលាស់ លើសពីនេះទៀតដំណាំបន្លែគឺត្រូវការជីមួយចំនួនទៀតដូចជា Ca , S , Mg , Fe , Cu , Zn , Cl , Mn , B ។ល។

ការខ្វះនូវសារធាតុចិញ្ចឹមខាងលើណាមួយ អាចធ្វើអោយដំណាំខ្វះជីវជាតិ និងលូតលាស់មិនបានល្អ ទទួលបានទិន្នផលទាប។

## ១.៦. ស្ថានភាពទីផ្សារបន្លែនៅកម្ពុជា

ចំពោះការដាំដុះតាមរដូវ ផលិតភាពនៃការដាំដុះទាប អស្ថេរភាពទីផ្សារ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងកង្វះខាតការចូលទៅកាន់ទីផ្សារ បានក្លាយជាឧបសគ្គនៃការចរាចរបន្លែក្នុងស្រុក ខណៈដែលផ្សារដើមគរ និងផ្សារនាគមាស បានក្លាយជាតំបន់យ៉ាងសំខាន់នៃការចែកចាយបន្លែ ជាពិសេស បន្លែនាំចូល ទៅកាន់ខេត្ត ផ្សេងៗ ក្នុងអំឡុងចន្លោះពីខែមេសា ដល់ខែកញ្ញា។

តំបន់ផលិតបន្លែធំៗ ក្នុងប្រទេសកម្ពុជា រួមមាន ខេត្តកណ្ដាល កំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង សៀមរាប និងកំពត ដែលគ្រប់ដណ្ដប់ប្រមាណ ៥៧% នៃផ្ទៃដីដាំបន្លែសរុប។ ប៉ុន្តែ ដោយសារកត្តាអាកាសធាតុ កម្ពុជាអាចផលិតបន្លែត្រឹមតែរយៈពេលចន្លោះពីខែតុលា ដល់ខែមីនា តែប៉ុណ្ណោះ ដែលជាខែអំណោយផលខ្លាំងសម្រាប់ការដាំដុះ។ ការដាំដុះតាមរដូវកាលបណ្ដាលឲ្យការផ្គត់ផ្គង់មិនទៀងទាត់សម្រាប់ចង្វាក់ផលិតកម្ម ជាហេតុជម្រុញឲ្យកម្ពុជានាំចូលបន្លែពីបរទេសប្រមាណជាង ៥០ម៉ឺនតោនក្នុងមួយឆ្នាំដើម្បីបំពេញតម្រូវការក្នុងស្រុក។ ផ្ទៃដីដាំបន្លែរបស់កម្ពុជា មានទំហំសរុបប្រមាណត្រឹមតែ ១,៣% ឬប្រមាណត្រឹមតែជាង ៥ម៉ឺនហិចតា នៃផ្ទៃដីកសិកម្មសរុប ៣,៣លានហិចតា។ បន្លែមានតួនាទីយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជា បន្ទាប់ពីស្រូវ និងត្រី ដែលបានផ្ដល់សារធាតុចិញ្ចឹមដល់ការធំធាត់របស់មនុស្ស។[១៥]

### ១.៦.១. និយមន័យទីផ្សារ

ទីផ្សារ គឺជាកន្លែងដោះដូរផលិតផលរវាងអ្នកទិញនិងអ្នកលក់ ក្នុងក្របខ័ណ្ឌតំបន់ភូមិសាស្ត្រ ក្នុងរយៈពេល

[១៥] គេហទំព័រ Cambonomist.com , និយមន័យទីផ្សារ, ២០១៨

កំណាត់មួយ និងតាមតម្លៃសមស្របមួយ។ ផលិតផលដែលត្រូវដោះដូរលើទីផ្សារ អាចជាទំនិញ សេវាកម្ម ឬ អាចជាធនធាន។

ក្នុងន័យសេដ្ឋកិច្ច ទីផ្សារគឺជាការដោះដូររវាងអ្នកផ្គត់ផ្គង់ និងអ្នកមានតម្រូវការនូវរាល់ទំនិញនិងសេវាកម្ម ជាមួយនឹងបរិមាណផលិតផលនិងតម្លៃសមរម្យ ក្រោមការ ប្រកួតប្រជែង បើទោះបីជាអ្នកផ្គត់ផ្គង់និងអ្នកមានតម្រូវការពុំបានជួបមុខគ្នាក្នុងកន្លែងកំណាត់ណាមួយក៏ដោយ។[១៦]

### ១.៦.២. តម្រូវការ និងច្បាប់តម្រូវការ

តម្រូវការ បង្ហាញអំពីបំណងចង់បានទ្រព្យនិងសេវា និងលទ្ធភាពនៃការទូទាត់ដើម្បីបានវា។ សេដ្ឋវិទូនិយាយថាអ្នកគ្មានតម្រូវការជាក់ស្តែងទេ បើអ្នកចង់បានរបស់អ្វីម្យ៉ាងតែគ្មានលទ្ធភាពដើម្បីបានវា។ ផ្ទុយទៅវិញបើអ្នកចង់បានរបស់ម្យ៉ាង ហើយអ្នកមានលទ្ធភាពដើម្បីបានវានោះគេថាអ្នកមានតម្រូវការលើវា។[១៧]

ថ្លៃគឺជាកត្តាសំខាន់មួយ ដែលមានឥទ្ធិពលទៅលើតម្រូវការ។ នៅកម្រិតថ្លៃនីមួយៗបរិមាណតម្រូវការ គឺជាបរិមាណអតិបរមាដែលអ្នកទិញចង់ទិញនៅថ្លៃនោះ។

ច្បាប់តម្រូវការ អះអាងថាបើកត្តាឥទ្ធិពលផ្សេងៗទៀតមិនប្រែប្រួលនៅដំណាក់កាលជាក់លាក់មួយ ហើយបើថ្លៃមុខទំនិញមួយកាន់តែថោក នោះបរិមាណតម្រូវការទំនិញនោះកាន់តែកើនឡើង។ ផ្ទុយទៅវិញបើថ្លៃទំនិញកាន់តែកើនឡើងនោះបរិមាណតម្រូវការទំនិញកាន់តែតិច។

តម្រូវការ គឺជាទំនាក់ទំនងផ្ទុយគ្នារវាងថ្លៃទំនិញ X មួយទៅនិងបរិមាណទំនិញ X នោះដែលអ្នកទិញចង់និងមានលទ្ធភាពទិញក្នុងរយៈពេលមួយជាកំណត់ ដោយលក្ខខ័ណ្ឌដទៃទៀតមិនប្រែប្រួល។[១៨]

ច្បាប់តម្រូវការ បានចែងថាប្រសិនបើកត្តាផ្សេងទៀតនៅថេរដដែល ហើយថ្លៃទំនិញ X មួយកើនឡើងនាំឲ្យបរិមាណទំនិញ X ថយចុះ និងច្រាសមកវិញ។

### ១.៦.៣. ផ្គត់ផ្គង់ និងច្បាប់ផ្គត់ផ្គង់

ផ្គត់ផ្គង់ បង្ហាញពីបំណង និងលទ្ធភាពរបស់អ្នកផលិតក្នុងការផ្គត់ផ្គង់ទ្រព្យ និងសេវាលើទីផ្សារ។ អ្នកដែលផ្គត់ផ្គង់ទ្រព្យ និងសេវានៅលើទីផ្សារ គឺអ្នកផលិត(ផលិតករ)។[១៩]

ថ្លៃ គឺជាកត្តាសំខាន់ដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់។ ច្បាប់ផ្គត់ផ្គង់ បង្ហាញថាអ្នកផលិតមានបំណងលក់ទ្រព្យ និងសេវាកានតែច្រើននៅថ្លៃកាន់តែខ្ពស់ ហើយលក់កាន់តែតិចនៅថ្លៃទាប។

---

[១៦] Sarith Khem, និយមន័យទីផ្សារ,១៦ មិថុនា ២០១៨

[១៧] ម៉ម ចរិយាវុធ និង ងួន ហេង , សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣ , ឆ្នាំ ២០១២ ,ទំព័រ ៦៨

[១៨] ទួន ផល្លា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, មីក្រូសេដ្ឋកិច្ច, ឆ្នាំ ២០១៨, ទំព័រ ៧

[១៩] ម៉ម ចរិយាវុធ និង ងួន ហេង , សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣ , ឆ្នាំ ២០១២ ,ទំព័រ ៨១

ផ្គត់ផ្គង់ គឺជាទំនាក់ទំនងស្របគ្នារវាងថ្លៃទំនិញ X មួយទៅនិងបរិមាណទំនិញ X នោះដែលអ្នកលក់ ឬអ្នកផលិតមានបំណង និងមានលទ្ធភាពផ្គត់ផ្គង់វានៅលើទីផ្សារក្នុងកំឡុងពេល មួយ។[២០]

ច្បាប់ផ្គត់ផ្គង់ បានចែងថាប្រសិនបើកត្តាដទៃទៀតនៅថេរដដែល ហើយថ្លៃទំនិញ X មួយកើនឡើង នាំឲ្យអ្នកលក់ឬអ្នកផលិតផ្គត់ផ្គង់ទំនិញ X កាន់តែច្រើនថែមទៀត និងច្រាសមក)។

## ១.៧. ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងផលិតកម្មកសិកម្ម

ប្រសិទ្ធភាពសេដ្ឋកិច្ច គឺជារង្វាស់មួយដ៏សំខាន់ ដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយក្នុងផលិតកម្មកសិកម្ម។ គ្រប់កត្តាផលិតកម្មដែលត្រូវយកទៅវិនិយោគក្នុងផលិតកម្មដូចជា ដីធ្លី កម្លាំង ពលកម្ម ដើមទុន និងបច្ចេកវិទ្យា ត្រូវបានវាស់វែងដោយខ្នាតរង្វាស់ប្រសិទ្ធភាពសេដ្ឋកិច្ច ដោយឆ្លងកាត់អនុគមន៍ផលិតកម្មដូចខាងក្រោម៖[២១]

$$Y = f(A, L, C, T)$$

ដែលក្នុងនោះ៖ Y: ជាបរិមាណកសិផលដែលទទួលបានក្នុងមួយវដ្តកសិកម្ម

A: ជាផ្ទៃដីកសិកម្ម

L: ជាកម្លាំងពលកម្ម

C: ជាដើមទុនឬជាមូលធន ក្នុងផលិតកម្មកសិកម្ម

T: ជាបច្ចេកវិទ្យាដែលប្រើប្រាស់កផលិតកម្មកសិកម្ម

តាមរយៈអនុគមន៍ យើងឃើញថាបរិមាណកសិផលកសិកម្មមានការកើនឡើងជាអនុគមន៍ទៅនឹងកត្តាផលិតកម្មទាំងបួន ហើយបរិមាណកសិផលកើនឡើងក៏ធៀបទៅនឹងប្រសិទ្ធភាពនៃកត្តាផលិតកម្មនីមួយៗដែរ។

### ១.៧.១. តម្រូវការទុនផលិតកម្ម និងចំណាយ

ទុនផលិតកម្ម គឺជាដើមទុនទាំងឡាយណាដែលចូលរួមជាចាំបាច់ក្នុងផលិតកម្ម ដែលរួមមាន៖

- **អចលនទុន**
  - ជាតម្លៃរបស់អចលនទ្រព្យ
  - មានតម្លៃខ្ពស់
  - ប្រើប្រាស់បានរយៈពេលច្រើនឆ្នាំ

[២០] ទូន ផល្លា ,មីក្រូសេដ្ឋកិច្ច, ឆ្នាំ ២០១៨, ទំព័រ ១១

[២១] Timothy J, Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page12

- រក្សាបាននូវទ្រង់ទ្រាយដើម ក្រោយពេលចប់ការផលិត
- បញ្ចូលតម្លៃវាបន្តិចម្តងៗទៅក្នុងផលិតផលថ្មីដែលទើបតែផលិតបាន
- តម្លៃត្រូវបានបញ្ចូលតាមរយៈរំលោះ។

❖ **ចលនទុន**

- ជាតម្លៃរបស់ចលនទ្រព្យដែលចូលរួមវិនិយោគក្នុងផលិតកម្មកសិកម្ម
- មានតម្លៃទាប
- ឆាប់ខូច
- ប្រើប្រាស់រយៈពេលតិចជាង១ឆ្នាំ
- បាត់រូបភាពទាំងស្រុងក្រោយចប់ការផលិត
- បញ្ចូលតម្លៃខ្លួនវាតែម្តងគត់ទៅក្នុងផលិតកម្មថ្មីដែលទើបផលិតបាន។

### ១.៧.២. ចំណូលពីការលក់បន្លែ

ចំណូលក្នុងផលិតកម្មកសិកម្ម គឺជាចំណូលដែលទទួលបានពីការលក់បរិមាណកសិផលសរុបគិតក្នុងមួយវដ្តផលិតកម្ម (Q) គុណជាមួយនឹងថ្លៃកសិផលគិតក្នុងមួយឯកតា (P)[២២]គឺ៖

| |
|---|
| ចំណូល (TR) = ថ្លៃលក់ផលិតផលក្នុង១ឯកតា × បរិមាណកសិផលសរុប (Q) |

### ១.៧.៣. ប្រាក់ចំណេញពីការដាំដុះបន្លែ

ប្រាក់ចំណេញក្នុងផលិតកម្មកសិកម្ម ទទួលបានពីចំណូលសរុបក្នុងផលិតកម្មកសិកម្ម ដកនឹងចំណាយសរុបក្នុងផលិតកម្មកសិកម្ម[២៣] គឺ៖

| |
|---|
| ចំណេញសរុប = ចំណូលសរុប (TR) – ចំណាយសរុប(TC) |

### ១.៧.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចមួយឯកតាទុនផលិតកម្ម

ការវិភាគរកប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម គឺចង់ដឹងថា តើពេលម្ចាស់កសិដ្ឋានប្រើទុនមួយរៀលទៅ តើគាត់នឹងទទួលបានប្រាក់ចំណូលប៉ុន្មានរៀលត្រឡប់មកវិញក្នុងចំណូលរបស់គាត់ ហើយចំណេញបានប៉ុន្មានដែរ?

[២២] Hal R. Varain, 2010, Intermediate Microeconomics, 8th Edition, New York, W.W. Norton& Company,Page277

[២៣] Timothy J, Coeli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer,P12

រូបមន្តសម្រាប់គណនា ប្រសិទ្ធភាពសេដ្ឋកិច្ចកក្នុងមួយឯកតាទុនផលិតកម្មគឺ[២៤] ៖

$$\text{ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬក្នុងមួយវដ្តផលិតកម្ម}}{\text{ចំណាយសរុបប្រចាំឆ្នាំ ឬក្នុងមួយវដ្តផលិតកម្ម}}$$

### ១.៧.៥. ប្រសិទ្ធភាពកម្លាំងពលកម្ម

សម្រាប់ការគណនារកប្រសិទ្ធភាពកម្លាំងពលកម្ម យើងអាចរកឃើញថា តើកម្លាំងពលកម្ម១នាក់ អាចរកប្រាក់ចំណូលបានប៉ុន្មាន? យើងអាចប្រើរូបមន្តដូចខាងក្រោម[២៥] ៖

$$\text{ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{បរិមាណកសិផលក្នុង១ឯកតា} \times \text{ថ្លៃកសិផលក្នុងមួយឯកតា}}{\text{កម្លាំងពលកម្មសរុប}}$$

### ១.៧.៦.ប្រសិទ្ធភាពដីធ្លី

ប្រសិទ្ធភាពនៃដីធ្លីអាចឱ្យយើងដឹងថា តើដីកសិដ្ឋានមួយឯកតា អាចរកប្រាក់ចំណូលបានប៉ុន្មាន? យើងអាចប្រើរូបមន្តដូចខាងក្រោម[២៦] ៖

$$\text{ប្រសិទ្ធភាពដីធ្លី} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬមួយវដ្តផលិតកម្ម}}{\text{ផ្ទៃដីសរុបជាមធ្យម}}$$

## ១.៨. ការវិភាគចំណុចស្រង់ដើម

ចំណុចស្រង់ដើម គឺជាចំណុចមួយដែល ចំណូលសរុប ស្មើនឹងចំណាយសរុប មិនខាតហើយក៏មិនចំណេញ។ គោលដៅនៃការវិភាគទៅលើចំណុចស្រង់ដើមគឺ វិភាគលើខ្ទង់ចំណាយអថេរ ពីព្រោះចំណាយអថេរថាគឺចំណាយទៅលើចលនទ្រព ពោលគឺការចំណាយទៅលើខ្ទង់ចលនទុន ប្រសិនបើដំណើរការផលិតកម្មរបស់កសិដ្ឋានប្រែប្រួល នោះខ្ទង់ចំណាយចលនទុនក៏ប្រែប្រួលដែរ។

ការវិភាគរកចំណុចស្រង់ដើម ត្រូវបានប្រើរូបមន្តដូចខាងក្រោម៖

ដោយចំណុចស្រង់ដើមជាចំណុចដែល ចំណូលសរុប(TR) ស្មើនឹងចំណាយសរុប(TC)

[២៤] Timothy J, Coeli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 210

[២៥] David Besanko Ronald R. Braetigan, 2010, Microeconomics, 4th Edition, New York John Wiley & Sons, Page 206

[២៦] Timothy J, Coeli et all, A Introductory to Efficiency and Productivity Analysis, 2nd Edition, New York, Springer, Page 255

ដោយ TR= PQ

$\Rightarrow PQ = TC$

ដូចនេះ $$P = \frac{TC}{Q}$$

ដែល P: ជាថ្លៃលក់នៅចំណុចស្រង់ដើម

Q: ជាបរិមាណទិន្នផល

TC: ជាចំណាយក្នុង១វដ្តផលិតកម្ម

❖ **សេចក្តីសន្និដ្ឋាន**

តាមរយៈការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថាគ្រប់សម័យកាលទាំងអស់កសិកម្មគឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍសង្គមឱ្យមានការរីកចម្រើន។ ដោយសារសម័យកាលចេះតែវិវត្តន៍ធ្វើឱ្យការធ្វើកសិកម្មមានការប្រែប្រួល ដោយតាំងពីសម័យបុរាណ មនុស្សធ្វើកសិកម្មតាមបែបប្រពៃណី តាមទំនៀមទម្លាប់ លុះមកដល់បច្ចុប្បន្នមនុស្សចេះតែមានគំនិតច្នៃប្រឌិតបង្កើតថ្មី ដែលផ្លាស់ប្តូរពីការធ្វើកសិកម្មបែបប្រពៃណី ទៅជាកសិកម្មបែបទំនើប ដោយមានបច្ចេកទេសថ្មីៗធ្វើឱ្យទិន្នផលកើនឡើង លើសពីតម្រូវការផ្គត់ផ្គង់ក្នុងគ្រួសារ និងអាចឱ្យមានការផ្គត់ផ្គង់ទៅកាន់ទីផ្សារបានថែមទៀត។

ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ដែលពឹងផ្អែកលើវិស័យកសិកម្ម ដែលប្រជាជនប្រមាណជាង ៨០% ប្រកបរបរកសិកម្ម ដូចជាការដាំដុះ ចិញ្ចឹមសត្វ និងនេសាទ។ល។ ក្នុងនោះដែរ ដំណាំបន្លែគឺជាប្រភេទដំណាំដែលងាយស្រួលក្នុងការដាំដុះ ងាយស្រួលថែទាំ អាចដាំបានគ្រប់រដូវទាំងប្រាំង និងវស្សា ថែមទាំងផ្តល់ផលប្រយោជន៍ និងសារធាតុចិញ្ចឹមល្អៗជាច្រើនដែលជួយទ្រទ្រង់សុខភាពឱ្យកាន់តែរឹងមាំ។ លើសពីនេះទៅទៀត បន្លែបានចូលរួមផ្នែកសេដ្ឋកិច្ចជាច្រើន ដែលបានចូលរួមកាត់បន្ថយលើការចំណាយ និងអាចរកប្រាក់ចំណូលតាមរយៈការដាំបន្លែ ជួយឱ្យជីវភាពគ្រួសារកាន់តែល្អប្រសើរ និងធ្វើឱ្យសង្គមជាតិមានការរីកចម្រើន។

# ជំពូកទី២
# ស្ថានភាពទូទៅនៃការដាំ
# ដុះបន្លែសុវត្ថិភាពក្នុងឃុំ
# ស្វាយប្រទាល

# ជំពូកទី២

# ស្ថានភាពទូទៅនៃការដាំដុះបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល

## ២.១. ស្ថានភាពទូទៅនៃតំបន់សិក្សាស្រាវជ្រាវ

### ២.១.១. ស្ថានភាពទូទៅស្រុកស្អាង

#### ២.១.១.១. ទីតាំងភូមិសាស្ត្រស្រុកស្អាង

ស្រុកស្អាង គឺជាស្រុករបស់ខេត្តកណ្តាល ស្ថិតនៅតំបន់វាលទំនាប លាតសន្ធឹងតាមបណ្តោយដងទន្លេបាសាក់ ពុះស្រុកជាពីរផ្នែក គឺផ្នែកខាងលិចទន្លេ និងខាងកើតទន្លេមានដីកោះបួនកន្លែង រួមមានឃុំកោះអន្លង់ចិន ឃុំខ្សាច់ទន្លា កោះគរនៃឃុំស្វាយប្រទាល និងកោះថ្មីនៃឃុំខ្ពប ហើយមានព្រំប្រទល់៖

- ខាងកើតជាប់ស្រុកកៀនស្វាយ និងស្រុកលើកដែក
- ខាងលិចជាប់នឹងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងស្រុកព្រៃកប្បាស និងស្រុកបាទីខេត្តតាកែវ
- ខាងជើងជាប់នឹងក្រុងតាខ្មៅ
- ខាងត្បូងជាប់ និងស្រុកកោះធំ។

ស្រុកស្អាងមាន ១៦ឃុំ ១១៩ភូមិ និងមានប្រជាជនរស់នៅប្រមាណ១៩៧,៩០១នាក់(សាលាស្រុកស្អាង) ស្ថិតនៅក្នុងគ្រួស្រារភាគច្រើនសុទ្ធសឹងជាគ្រួសារកសិករប្រកបរបរកសិកម្ម៩៥ភាគរយនៃប្រជាជនសរុប (ដាំដំណាំគ្រប់រដូវ និងចិញ្ចឹមសត្វ)។

#### ២.១.១.២. ស្ថានភាពសេដ្ឋកិច្ច

ដោយយោងទៅលើតំបន់ភូមិសាស្ត្ររបស់ស្រុកស្អាង ប្រព័ន្ធក្សេត្របរិស្ថានត្រូវបានបែងចែកជា៣គឺ៖

- តំបន់ក្សេត្របរិស្ថានទី១៖ តំបន់នេះស្ថិតនៅភាគខាងលិចនៃស្រុកស្អាង ផ្ទៃដីដាំដុះភាគច្រើនជាដំណាំស្រូវដែលមានអាងទឹកធំមួយឈ្មោះ បឹង៥៥០ ឬបឹងជើងលាង ដែលអាចស្រោចស្រពទឹកស្រូវប្រាំងបានប្រមាណ ៣,២០០ ហ.ត របស់ប្រជាកសិករចំនួន៣ឃុំ គឺឃុំកោះខែល ព្រៃកអំបិល និងក្រាំងយ៉ូវ ហើយមានប្រព័ន្ធប្រឡាយគ្រាប់គ្រាន់សម្រាប់ស្រោចស្រព ដែលធ្វើឲ្យមានទឹកស្រោចស្រពគ្រប់រដូវ គម្របដីមានភាពជម្រាលល្មម មានដីទួលខ្លះៗជាមួយទំនាបបឹង អូរ ថ្លុកត្រពាំងហើយមានការហូរច្រោះល្មម។
- តំបន់ក្សេត្របរិស្ថានទី២៖ ការរស់នៅរបស់ប្រជាជនច្រើនកុះករ នៅអមសងខាងទន្លេបាសាក់ ហើយប្រើប្រាស់ទឹកទន្លេសម្រាប់ហូប និងប្រកបរបរកសិកម្ម។ ជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិ ដូចជាដីល្បាប់អាចដាំដំណាំបានគ្រប់រដូវ សម្បូរត្រីក្នុងបឹង និងទន្លេ។

- តំបន់ក្បែត្រប្រវិស្ថានទី៣៖ តំបន់នេះស្ថិតក្នុងភាគអាគ្នេយ៍ស្រុកស្អាង រយៈពេលទឹក៤ខែ គោក៨ខែ លើផ្ទៃដីមួយចំនួន។ ប្រជាជននៅតំបន់នេះរស់នៅច្រើនកុះករចំនួន៣កន្លែងដែលមាន៥ភូមិ និងមួយឃុំ គឺការសង់ផ្ទះផុតពីដីកម្ពស់ពី៦ទៅ៧ម៉ែត្រ ហើយនៅជុំវិញភូមិនិងផ្ទះគេដាំឬស្សីព្រៃ និងដើមឈើដូចជា ខ្ទុរ រាំង កុំឲ្យខ្យល់បោកបាក់។

**២.១.១.៣ ប្រភពទឹក**

ទឹកគឺជាកត្តាសំខាន់ដែលមិនអាចខ្វះបានក្នុងដំណើរការផលិតកម្ម។ ទឹក ជាប្រភពនៃការទ្រទ្រង់ដ៏សំខាន់ដែលជួយដល់ការលូតលាស់របស់រុក្ខជាតិ។ ជាក់ស្តែង នៅក្នុងស្រុកស្អាងដែលសម្បូរដោយប្រជាកសិករ ប្រកបរបរកសិកម្ម គឺត្រូវការជាចាំបាច់នូវប្រភពទឹកសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំគ្រប់រដូវកាល។ ប្រភពទឹកសំខាន់ៗសម្រាប់ស្រុកស្អាងមានដូចជា៖

- ទន្លេបាសាក់ដែលហូរកាត់ស្រុកស្អាង ហាក់បីដូចជាពុះស្រុកស្អាងជា២ ហើយហូរនាំដីល្បាប់ពីទន្លេមេគង្គ ទៅតាមព្រែកតូចធំនៅអមសងខាងទន្លេ ចាក់ទៅដីទំនាបដែលអំណោយផលដល់ការដាំដុះដំណាំគ្រប់ប្រភេទ និងធ្វើស្រូវឡើងទឹក។
- ស្ទឹងព្រែកត្នោតដែលហូរកាត់ស្រុកកណ្តាលស្ទឹងខេត្តកណ្តាលបានតម្រង់មកស្រុកស្អាងដែលអំណោយផលដល់ការដំដុះស្រូវវស្សានៅគ្រប់បណ្តាឃុំប៉ែកខាងលិច។ ពេលទឹកឡើងខ្លាំង ស្រុកស្អាងជាចំណុចជួបនៃទន្លេបាសាក់ និងទឹកស្ទឹងព្រែកត្នោត ហើយបង្កឲ្យមានការលិចលង់ផលដំណាំរបស់កសិករ ខ្លាំងក្លាណាស់ដែរ។
- ក្រៅអំពីប្រភពទឹកខាងលើនេះ មធ្យោបាយសម្រាប់បំពេញតម្រូវការទឹកស្រោចស្រពបានគ្រប់រដូវកាលកសិករនៅឃុំស្វាយប្រទាល បានជីកស្រះដើម្បីស្តុកទឹកទុកប្រើប្រាស់នៅរដូវប្រាំង និងជីកអណ្តូងក្បែរផ្ទះ ក៏ដូចក្បែរដីកសិកម្មរបស់គាត់ដើម្បីងាយស្រួលស្រោចស្រពដំណាំ។

## ២.១.២ ទីតាំងភូមិសាស្រ្តឃុំស្វាយប្រទាល

ឃុំស្វាយប្រទាល គឺជាឃុំមួយដែលស្ថិតនៅក្នុងស្រុកស្អាងខេត្តកណ្តាល ប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា។ ឃុំនេះមានព្រំប្រទល់ជាប់នឹងឃុំ៖

- ខាងជើងជាប់នឹងឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ
- ខាងកើតនិងខាងត្បូងជាប់នឹងឃុំត្រើយស្លា ស្រុកស្អាង
- ខាងលិចជាប់នឹងទន្លេបាសាក់ដែលជាប់បណ្តោយឃុំ៣គឺ ៖ ឃុំសិត្បូ ឃុំរកាខ្ពស់ និងឃុំព្រែកគយ។

### ២.១.៣. ស្ថានភាពទូទៅនៃឃុំស្វាយប្រទាល

❖ **ស្ថិតិផ្ទៃដី**

ស្វាយប្រទាល ជាឃុំមួយដែលស្ថិតនៅតាមបណ្តោយដងទន្លេបាសាក់ ហើយនៅភាគខាងជើងឆៀងខាងលិចនៃស្រុកកៀនស្វាយខេត្តកណ្តាល។ ឃុំស្វាយប្រទាលមានផ្ទៃដីសរុប ៣,៥២៤.១៥[២៧] ហ.ត ផ្ទៃដីលំនៅដ្ឋានមាន ១,០៤៩[២៨] ហ.ត ផ្ទៃដីធ្វើស្រែមាន ៣១២ ហ.ត (ផ្ទៃដីធ្វើស្រែប្រាំង ១៧១ ហ.ត និងស្រែវស្សាមាន ១៤១ ហ.ត) ផ្ទៃដីធ្វើចម្ការមាន ៩០០ ហ.ត (ផ្ទៃដីធ្វើចម្ការមានរយៈពេលខ្លីមាន ៦១៤ ហ.ត និងផ្ទៃដីធ្វើចម្ការរយៈពេលវែងមាន ២៨៦ ហ.ត) និងផ្ទៃដីផ្សេងៗ(ដីព្រៃ បឹងបួរ ។ល។) មាន ១,៦៦៥ ហ.ត។

តារាងទី២.១៖ ការបង្ហាញអំពីចំនួនភូមិ និងផ្ទៃដីគិតជា ហ.ត

| ល.រ | ឈ្មោះភូមិ | ផ្ទៃដី |
|---|---|---|
| ១ | ព្រែកតាតិន | ៤១៤ |
| ២ | ឫស្សីជ្រោយ | ៤៣៥ |
| ៣ | ព្រែកតាជ័រ | ៥២១ |
| ៤ | ព្រែកតាសៅ | ៣៧៤ |
| ៥ | ចុងកោះគរ | ៣២៦ |
| ៦ | បារ៉ែនលើ | ២៩៩ |
| ៧ | អូរាំចេក | ២២៣ |
| ៨ | បារ៉ែនក្រោម | ៤៨៦ |
| ៩ | ពោធិតាប៉ាង | ៤៤៧ |
| សរុប | | ៣,៥២៥ |

ប្រភព៖សាលាឃុំស្វាយប្រទាលឆ្នាំ២០១៩

❖ **ស្ថិតិប្រជាជន**

នៅឃុំស្វាយប្រទាលមានចំនួន៩[២៩] ភូមិ និងមានប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ចំនួន ៣,៦៣៩[៣០]

[២៧] ស្ថិតិផ្ទៃដីឃុំសរុបឆ្នាំ ២០១៩

[២៨] ទិន្នន័យសំណង់លំនៅដ្ឋានថ្នាក់ឃុំស្វាយប្រទាល ឆ្នាំ ២០១៩

[២៩] ទិន្នន័យស្ថិតិចំនួនភូមិក្នុងឃុំស្វាយប្រទាលឆ្នាំ២០១៩

[៣០] ទិន្នន័យស្ថិតិប្រជាពលរដ្ឋ ក្នុងឆ្នាំ ២០១៩

គ្រួសារ ប្រជាជនសរុប ១៦,៥៥២ នាក់ ដែលក្នុងនោះមានស្រីសរុបចំនួន ៨,៦៥៨នាក់។ ប្រជាពលរដ្ឋដែលមានអាយុ ចាប់ពី១៨ឆ្នាំ ឡើងមានចំនួន ៩,៧៥០ នាក់ ស្រីចំនួន ៥,៥២៣ នាក់ និងកម្លាំងពលកម្មសរុបដែលកំពុងប្រកបរបរដាំដំណាំមានប្រមាណ ១១,៤០៦ នាក់ ស្មើនឹងប្រមាណ ៦៩% នៃប្រជាជនសរុបនៅក្នុងឃុំ។

តារាងទី២.២. ការបង្ហាញអំពីស្ថិតិប្រជាពលរដ្ឋក្នុងឃុំ ប្រចាំឆ្នាំ២០១៩

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋ | | ចំនួនប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី |
| ១ | ព្រែកតាតិន | ៣៨៥ | ១,៩៨៣ | ៨៦៥ | ៨៦៥ | ៤៥០ |
| ២ | ឬស្សីជ្រោយ | ៤១៣ | ២,០០៥ | ១,១១១ | ១,២៦៧ | ៧៣៥ |
| ៣ | ព្រែកតាជ័រ | ៥៦៨ | ២,៦៧៦ | ១,៣៩៦ | ១,៤៥៥ | ៧២០ |
| ៤ | ព្រែកតាសៅ | ៣៧០ | ១,៧២៥ | ៨៩៧ | ១,១៨០ | ៦០៥ |
| ៥ | ចុងកោះគរ | ២០១ | ៨២៨ | ៤៣៧ | ៥៤២៤ | ២៩៨ |
| ៦ | បារ៉ែនលើ | ២៣០ | ១,០១០ | ៤៦៣ | ៧២៧ | ៧២៣ |
| ៧ | អូរំចេក | ២៤៦ | ១,០៥៧ | ៥៤១ | ៥០១ | ២៦០ |
| ៨ | បារ៉ែនក្រោម | ៦៨៧ | ៣,០៩៦ | ១,៦៣០ | ១,៩៧៥ | ១,០៥៥ |
| ៩ | ពោធិតាប៉ាង | ៥៣៩ | ២,៤៧២ | ១,៣១៨ | ១,២៣៨ | ៦៧៧ |
| សរុប | | ៣,៩៣៩ | ១៦,៥៥២ | ៨,៦៥៨ | ៩,៧៥០ | ៥,៥២៣ |

ប្រភព៖សាលាឃុំស្វាយប្រទាល ឆ្នាំ២០១៩

### ២.១.៤ ស្ថានភាពសេដ្ឋកិច្ច

#### ២.១.៤.១ ស្ថានភាពមុខរបរប្រជាជនក្នុងឃុំស្វាយប្រទាល

តាមរយៈទិន្នន័យដែលប្រមូលបានពីថ្នាក់សាលាឃុំ និងការសាកសួរផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំស្វាយប្រទាលភាគច្រើនជាកសិករដែលប្រកបរបរកសិកម្មសំខាន់ៗ៣គឺ ធ្វើស្រែ ធ្វើចម្ការ (ដាំស្ពៃគ្រប់ប្រភេទ ស្វាយ ល្ហុង...) ចិញ្ចឹមសត្វ និងនេសាទ ។ ប្រជាពលរដ្ឋខ្លះធ្វើជា កម្មករក្នុងវិស័យកសិកម្ម(ស៊ីឈ្នួលបោចស្មៅ ភ្ជួររាស់ ស្ទូង...) កម្មកររោងចក្រ ជាងកាត់ដេរ ជាងសំណង់ មន្ត្រីរាជការ និងជាអាជីវករលក់ដូរជាដើម។ ប្រជាពលសរុបប្រមាណជាង៧៥ភាគរយ ប្រកបរបរកសិកម្ម និង២៥ភាគរយទៀត ប្រកបរបរផ្សេងៗទៀតក៏ដូចជាចំណាកស្រុកជាដើម។

### ២.១.៤.២ ស្ថានភាពលំនៅដ្ឋានប្រជាជនក្នុងឃុំស្វាយប្រទាល

លំនៅដ្ឋាន ជាកន្លែងដ៏សំខាន់សម្រាប់មនុស្សគ្រប់ៗគ្នាស្នាក់អាស្រ័យរស់នៅ និងជាកន្លែងដែលការពារយើងពីគ្រោះនានា ដូចជា ភ្លៀង ខ្យល់ កម្តៅថ្ងៃ ក៏ដូចជាក្រុមចោរជាដើម។ ផ្ទះ គឺជាជម្រកដ៏កក់ក្តៅ ហើយសម្រាប់មនុស្ស ដែលមនុស្សគ្រប់គ្នា ព្យាយាមរកប្រាក់ដើម្បីសាងសង់វា។ ផ្ទះនីមួយៗត្រូវសាងសង់ឡើងដោយលក្ខណៈផ្សេងៗគ្នា ខ្លះធំ ខ្លះតូច ទៅតាមជីវភាពរបស់គ្រួសារនីមួយៗ។ តាមរយៈការចុះដល់មូលដ្ឋានជាក់ស្តែង យើងសង្កេតឃើញថាផ្ទះរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំស្វាយប្រទាល មានស្ថានភាពខុសៗគ្នាដូចជា តំបន់ដែលរស់នៅផ្លូវកៅស៊ូ ភាគច្រើនជាផ្ទះធំល្មមសង់ឡើងពីថ្ម ឈើប្រក់ក្បឿង សង់នៅលើផ្ទៃដីដែលមានទំហំធំគួរសម និងមានដាំដំណាំហូបផ្លែនៅជុំវិញផ្ទះដូចជា ស្វាយ ខ្នុរ មៀនជាដើម។ រីឯផ្ទះប្រជាជនដែលរស់នៅក្នុងភូមិនៅតាមផ្លូវតូចៗខ្លះជាផ្ទះឈើប្រក់ក្បឿង និងខ្លះសង់ពីស័ង្កសីមានមួយចំនួនតូច ហើយនៅជុំវិញផ្ទះមានដាំដំណាំ បន្លែបង្កា និងផ្លែឈើហូបផ្លែជាដើម។

### ២.១.៤.៣ វិស័យគមនាគមន៍

ឃុំស្វាយប្រទាល ជាឃុំមួយដែលមិនទាន់មានផ្លូវជាតិឆ្លងកាត់នៅឡើយទេ ប៉ុន្តែក្នុងឃុំនេះមានផ្លូវខេត្តរាជធានីឬក្រុងខណ្ឌដែលឆ្លងកាត់ឃុំសង្កាត់ (ផ្លូវស្ថិតក្រោមការគ្រប់គ្រងថ្នាក់ខេត្តរាជធានីឬស្រុកខណ្ឌ)។ ផ្លូវនេះមានប្រវែង ៧,៧៨៥ ម៉ែត្រ ដែលភ្ជាប់ពីខណ្ឌច្បារអំពៅ រាជធានីហូតដល់ព្រំប្រទល់ប្រទេសវៀតណាម។ រីឯផ្លូវនៅក្នុងឃុំស្វាយប្រទាលសរុបមានចំនួន ១០ខ្សែ ដែលមានប្រវែងសរុប ២៨,៣៣៣ ម៉ែត្រ រួមបញ្ចូលទាំងផ្លូវចាក់ប៉េតុងព្រែកតាយុតមានប្រវែង ១៤១៥ ម៉ែត្រ សម្រាប់ប្រជាពលរដ្ឋក្នុងឃុំធ្វើដំណើរ និងជួយសម្រួលដល់ការដឹកជញ្ជូនទំនិញ ដូចជាការដឹកជញ្ជូនផលិតផលកសិកម្មឬឧស្សាកម្មនានា។ តាមរយៈការចុះទៅដល់មូលដ្ឋានផ្ទាល់ យើងសង្កេតឃើញថា ស្ថានភាពមធ្យោបាយក្នុងការធ្វើដំណើរមានលក្ខណៈកាន់តែប្រសើរឡើង ក្រៅពីផ្លូវគោកដែលជាមធ្យោបាយធ្វើដំណើរហើយ ក៏នៅមានកំពង់ចម្លងមួយចំនួនដែរ (មានកំពង់ចម្លងអុងប៉ាង និងកំពង់ចម្លងព្រែកតូច) សម្រាប់ធ្វើដំណើរពីថ្នល់ជាតិលើ ទៅកាន់ឃុំស្វាយប្រទាលនេះ និងទៅឃុំផ្សេងៗទៀតដែលនៅជិតនោះ ដែលអាចចម្លង ឡាន ម៉ូតូ និងឈ្មួញដែលដឹកបន្លែទៅកាន់ទីផ្សារជាដើម។ ក្រៅពីនេះក៏មានការសាងសង់ឡើងបន្ថែមទៀតដូចជា ផ្លូវប៉េតុងព្រែកតាតិន ២០០០ម៉ែត្រ ផ្លូវចាក់ថ្មមិច ១៣៥០ ម៉ែត្រ និងផ្លូវចាក់ថ្មបំបែក២០០០ម៉ែត្រថែមទៀត[៣១]។

### ២.១.៤.៤ ស្ថានភាពវិស័យកសិកម្មនៅឃុំស្វាយប្រទាល

តាមរយៈការចុះអង្កេតផ្ទាល់យើងសង្កេតឃើញថា ប្រជាជននៅឃុំស្វាយប្រទាល ប្រកបរបរកសិកម្មដូចជា ធ្វើស្រែ ធ្វើចម្ការ ចិញ្ចឹមសត្វ និងនេសាទជាលក្ខណៈគ្រួសារ ដោយសារតែតំបន់នេះមានដីអំណោយផលពីធម្មជាតិ ក៏ដូចជាមានប្រភពទឹកគ្រប់គ្រាន់សម្រាប់ដាំដុះ។ បើតាមប្រសាសន៍របស់មេឃុំស្វាយប្រទាល ក៏ដូច

[៣១] មេឃុំស្វាយប្រទាល, ទិន្នន័យស្ថិតិ ឃុំស្វាយប្រទាលឆ្នាំ២០២០

ជាអ៊ំប្រុសម្នាក់ដែលជាអនុប្រធានសហគមន៍កសិកម្មដំណាំបន្លែសុវត្ថិភាពបានឱ្យដឹងថា ការប្រកបរបរកសិកម្ម គឺជាមុខរបរស្នូលរបស់ប្រជាជននៅឃុំនេះ ពោលគឺប្រជាជនសឹងតែទាំងអស់ប្រកបរបរនេះ។ មួយវិញទៀត ក្នុងចំណោមប្រភេទដំណាំ គឺប្រជាពលរដ្ឋសឹងតែទាំងស្រុងនិយមដាំបន្លែដែលភាគច្រើនគឺដំណាំស្ពៃគ្រប់ប្រភេទដែលមានដូចជា ស្ពៃចង្កឹះ ស្ពៃតឿ ស្ពៃក្រញាញ់ ស្ពៃខៀវ ស្ពៃក្តោប ខាត់ណា ។ល។

ដំណាំស្ពៃ ជាដំណាំស្ពៃដែលងាយស្រួលដាំ និងឆាប់បានប្រមូលផល (ភាគច្រើនត្រឹម ២៨ទៅ ១ខែ ១០ថ្ងៃអាចប្រមូលផលបាន)។ គាត់បានបន្ថែមទៀតថា៖ ដំណាំស្ពៃពួកគាត់អាចដាំបានគ្រប់រដូវ ហើយក្នុងមួយឆ្នាំគាត់អាចដាំដុះបាន ពី៦-៧ដង ក្នុងមួយឆ្នាំប្រសិនបើមិនលិចទឹក តែបើលិចទឹកពួកគាត់អាចដាំបានពី ៣-៤ដង។ ក្រៅពីនេះក៏មានការដាំដំណាំមួយចំនួនទៀតដូចជា ស្វាយ ម្ទេស ខ្ញី ពោតជាដើម។ ឯប្រជាពលរដ្ឋដែលមិនមានដីផ្ទាល់ខ្លួន ពួកគាត់ស៊ីឈ្នួលបោចស្មៅ ឬក៏បាញ់ថ្នាំឱ្យគេដើម្បីរកកម្រៃ។

## ២.២. ស្ថានភាពផលិតកម្មបន្លែសុវត្ថិភាព

### ២.២.១. បច្ចេកទេសដាំដុះ

#### ២.២.១.១. ការរៀបចំដី

ដើម្បីដាំបន្លែទទួលបានទិន្នផលល្អ កសិករគ្រប់រូបសុទ្ធតែធ្វើការរៀបចំដីយ៉ាងម៉ត់ចត់ជាទីបំផុត។ អត្ថប្រយោជន៍នៃការរៀបចំដីមានដូចជា បានកម្ចាត់សត្វល្អិតចង្រៃ បានសម្អាតស្មៅចោលព្រោះស្មៅជាភ្នាក់ងារស្រូបយកសារធាតុចិញ្ចឹម ធ្វើឱ្យដីធូរងាយស្រួលដាំដុះ និងងាយស្រួលមើលថែ។

ការដាំបន្លែសុវត្ថិភាពក៏មិនខុសពីការដាំបន្លែគីមីប៉ុន្មានដែរ។ សម្រាប់ដំណាក់កាលនៃការរៀបចំដីមានដូចជា៖

- សម្អាត និង pH ដី៖ សម្អាតកាកសំណល់ដែលមិនរលួយ ភាពកខ្វក់ដែលរំខានដល់ការលូតលាស់ និងសុវត្ថិភាពផលិតផលដំណាំ បន្ទាប់មកវាស់ pH ដី ដែលត្រូវស្ថិតនៅក្នុងចន្លោះ 5.5 ទៅ 6.5 ណឺត។ ដាក់ជីកំប៉ុសបន្ថែមពី ១ ទៅ ៣គីឡូក្រាម ក្នុងមួយម៉ែត្រការេ គឺអាចឱ្យ pH សមស្របសម្រាប់ដំណាំ។
- បំផុសជម្រៅ៖ ដើម្បីបំបែកដីឱ្យបានម៉ត់ល្អ ធូរ និងជ្រាបទឹកបានល្អ ត្រូវភ្ជួរជម្រៅយ៉ាងហោច 0.៣ម៉ែត្រ រាស់បំបែកហាលឱ្យស្ងួតដើម្បីសម្លាប់ពពួកកត្តាចង្រៃផ្សេងៗ។
- ការដាក់កំបោរ៖ ធ្វើឱ្យដីមានសារធាតុសរីរាង្គគ្រប់គ្រាន់ រក្សា ឬស្តុកទឹកនិងសារធាតុចិញ្ចឹមបានល្អ និងជាឃ្លាំងសម្រាប់ស្តុកអាហារសម្រាប់ដំណាំ។
- លើក និងគ្របរង៖ ប្រើកៅស៊ូឬប្លាស្ទិច ឬស្លឹករុក្ខជាតិ ឬចំបើង គ្របរងដើម្បីការពារការការហូរច្រោះ និងរក្សាសំណើមដី។ ចំណាំងផ្លាតរបស់កៅស៊ូអាចជួយបណ្តេញសត្វល្អិតចង្រៃបាន។

- គ្របការពារស្មៅ៖ ប្រើសារធាតុសរីរាង្គដែលស្ងួត ដូចជាចំបើង អង្កាម ស្មៅស្ងួត រឺកំប្លោក និងសារធាតុសរីរាង្គដទៃទៀតដែលសមស្រប។
- ប្រព័ន្ធរំដោះទឹក៖ ជីប្រឡាយជុំវិញតួចម្ការឱ្យបានធំ និងជ្រៅជាងចន្លោះរង ដើម្បីឱ្យទឹកដែលលើសពីតម្រូវការហូរចេញ។[៣២]

### ២.២.១.២. ការជ្រើសរើសពូជដំណាំ

ពូជ គឺជាកត្តាដ៏សំខាន់បំផុតនៅក្នុងការដាំដំណាំ។ ពូជដែលត្រូវការត្រូវតែជា ពូជដែលមានភាពធន់ (ធន់នឹងសត្វល្អិត ជម្ងឺ និងអាកាសធាតុ) ពូជដែលផ្តល់ទិន្នផល និងតម្រូវការទីផ្សារខ្ពស់។ រាល់ប្រជាកសិករនៅឃុំស្វាយប្រទាលភាគច្រើន ដាំពូជដូចជា ស្ពៃតឿ ស្ពៃចង្កឹះ ស្ពៃក្រញាញ់ ស្ពៃខ្មៅ សាឡាត់។ល។ ពួកគាត់ផ្លាស់ប្តូរពូជតាមការបញ្ជាទិញរបស់ភ្នាក់ងារកសិកម្មដែលជាអ្នកទទួលចុះកុងត្រាទិញបន្លែរបស់គាត់។ ឯពូជរបស់គាត់គឺទិញពីភ្នាក់ងារកសិកម្មតែម្តង។

### ២.២.១.៣. ការដាំដុះ

បន្លែសុវត្ថិភាពដែលក្រុមសហគមន៍នៅឃុំស្វាយប្រទាលបានដាំដុះ គឺជាបន្លែដែលត្រូវលើករងជាមុន និងព្រោះគ្រាប់តែម្តង។ ការព្រោះគ្រាប់គឺពួកគាត់ព្រោះរង្វើលៗ ព្រោះបើព្រោះច្រើន នុះនឹងធ្វើឱ្យកូនដែលដុះមកប្រញឹកគ្នា នោះនឹងធ្វើឱ្យកូនខ្លះងាប់ ឯខ្លះទៀតក្រិន។ នៅពេលដែលគាត់ព្រោះគ្រាប់ពូជរួចគាត់ប្រើប្រាស់ចំបើងឬក៏ជាងដូង ឬស្លឹកឈើងាប់ៗយកមកគ្របដើម្បីការពារកូនដំណាំ។

### ២.២.១.៤. ការថែទាំ[៣៣]

#### ក.ការកម្ចាត់ស្មៅចង្រៃ

ស្មៅគឺជាកត្តាមួយដ៏សំខាន់ដែលបំផ្លាញផលដំណាំ ព្រោះវាស្រូបយកសារធាតុចិញ្ចឹមពីដំណាំ។ ការដាំបន្លែអាចគ្រប់គ្រងស្មៅបានតាមរយៈ ការគ្របរងដោយប្រើកៅស៊ូប្លាស្ទិច ឬគ្របចំបើង ហើយនៅតាមចន្លោះរងអាចប្រើសំណល់រុក្ខជាតិមានដូចជា៖ អង្កាមឬផេះ ចំបើងស្ងួតឬស្មៅស្ងួត កំប្លោក ស្លឹកចេកឬប្រភេទរុក្ខជាតិផ្សេងទៀតដែលងាយរលួយនៅក្នុងដី។ កាប្រើប្រាស់ថ្នាំកម្ចាត់ស្មៅ មិនមែនជាជម្រើសអទិភាពដែលត្រូវបានណែនាំឱ្យអនុវត្តទេ។

#### ខ. ការកម្ចាត់សត្វល្អិតចង្រៃ

❖ ប្រើថ្នាំជីវសាស្ត្រ៖ ថ្នាំជីវសាស្ត្រមានដូចជា៖

- បាក់តេរី៖ មានប្រសិទ្ធភាពកម្ចាត់កូនដង្កូវ Lepidoptera ដែលទើបនឹងញាស់
- ផ្សិត Metarhizium anisopliae ប្រសិទ្ធភាកម្ចាត់ក្រុមសត្វល្អិតបឺតជញ្ជក់

[៣២] CHAIN, សៀវភៅណែនាំស្តីពីការដាំបន្លែសុវត្ថិភាព, ឆ្នាំ២០១៨, ទំព័រទី ៧

[៣៣] CHAIN, សៀវភៅណែនាំស្តីពីការដាំបន្លែសុវត្ថិភាព, ឆ្នាំ២០១៨, ទំព័រទី ២៧

- ផ្សិត Beauveria Bassiana មានប្រសិទ្ធភាពកម្ចាត់សត្វល្អិតចង្រៃដូចជា ចៃ រុយស ដង្កូវមេអំបៅ ទ្រីប ដង្កូវភ្លើង ពពួកខ្មុង គ្រឹង...។

❖ ប្រើថ្នាំគីមី៖ ប្រើសម្រាប់ការពារនិងកម្ចាត់ នៅពេលពិនិត្យឃើញមានវត្តមានសត្វល្អិតចង្រៃ។ ប៉ុន្តែការប្រើថ្នាំគីមីគឺមានពេលកំណត់ ពោលគឺអាចប្រើតែពេលដែលត្រូវការចាំបាច់ប៉ុណ្ណោះ។

**គ. ការប្រើប្រាស់ជីធម្មជាតិ និងជីគីមី**

ជីគឺជាសារធាតុចិញ្ចឹមម្យ៉ាងដែលជួយឱ្យដំណាំលូតលាស់ល្អនិងជួយការពារដំណាំពីការបំផ្លាញផ្សេងៗផងដែរ។ តាមរយៈការសាកសួរដោយផ្ទាល់ពីក្រុមកសិករដាំដំណាំបន្លែសុវត្ថិភាព ពួកគាត់បានបញ្ជាក់ប្រាប់ថា ដំណាំបន្លែសុវត្ថិភាពនេះ គឺពួកគាត់ប្រើប្រាស់ទាំងជីធម្មជាតិ និងជីគីមីដូចដំណាំបន្លែទូទៅដែរ តែគ្រាន់តែការប្រើប្រាស់ជីគីមីនេះ គឺបរិមាណខុសគ្នា។ ខុសពីបន្លែគីមី បន្លែសុវត្ថិភាព គឺប្រើប្រាស់ជីគីមីដោយក្នុងបរិមាណតិចបំផុត មិនធ្វើឱ្យប៉ះពាល់ដល់គុណភាពដំណាំទេ។

- ជីធម្មជាតិ៖ មានដូចជាជីកំប៉ុស ជីដែលបានមកពីលាមកសត្វ ដែលកសិករប្រើប្រាស់សម្រាប់ទ្រាប់បាតដី។ ជាទូទៅប្រជាកសិករប្រើប្រាស់វាតែម្ដងប៉ុណ្ណោះ គឺនៅពេលដែលរៀបចំដីរួចរាល់។ ជីទាំងនោះភាគខ្លះគាត់បានមកពីសត្វចិញ្ចឹមរបស់គាត់ដូចជាគោ ជ្រូក... ឯខ្លះទៀតគាត់ទិញពីគេក្នុងតម្លៃមួយគួរសម។
- ជីគីមី៖ ជាធម្មតា ជីធម្មជាតិវាមិនអាចជួយបានទាំងស្រុងនោះទេ ដូច្នេះពួកគាត់ក៏ប្រើប្រាស់ជីគីមីផងដែរ ប៉ុន្តែក្នុងកម្រិតមួយតិចតួចបំផុតគឺ យ៉ាងហោចណាស់តែ២ដងប៉ុណ្ណោះ។ រាល់ពេលមុនប្រមូលផល១០ថ្ងៃ គ្មានការប្រើប្រាស់ថ្នាំ ឬក៏ជីគីមីអ្វីឡើយ។

**ឃ. ការស្រោចទឹក**

ជាទូទៅការស្រោចទឹកគឺកសិករស្រោចតែពីរដងក្នុងមួយថ្ងៃតែប៉ុណ្ណោះ គឺពេលព្រឹក និងពេលល្ងាច។ របៀបស្រោចស្រពមានបួនប្រភេទគឺ ស្រោចដោយដៃ ប្រើស្រ្ពីងឃ្លៅ បង្ហូរតាមចន្លោះរង និងខ្មៅប។

### ២.២.២. រដូវកាលដាំដុះបន្លែសុវត្ថិភាព

ជាទូទៅរដូវកាលនៃការដាំបន្លែក៏ផ្តល់សារៈសំខាន់ដែរដល់ការដាំដុះ និងប្រមូលផល។ តាមប្រសាសន៍របស់អ៊ំប្រុសដែលជាអនុប្រធានសហគមន៍ដាំដុះបន្លែសុវត្ថិភាពបានឱ្យដឹងថា ជាទូទៅរដូវដែលពពួកគាត់ដាំដុះបានទិន្នផលល្អនោះគឺរដូវប្រាំង ព្រោះរដូវប្រាំងមានពន្លឺគ្រប់គ្រាន់ មិនសូវមានសត្វល្អិតបំផ្លាញឡើយ ថ្វីបើគ្មានភ្លៀង តែពួកគាត់មានទឹកទន្លេ ក៏ដូចជាការប្រើម៉ូទ័របូមពីអណ្តូង មិនជាបញ្ហាចោទដល់ពួកគាត់ឡើយ។ ឯរដូវវស្សាវិញ មានភ្លៀងធ្លាក់ច្រើន ធ្វើឱ្យដំណាំគាត់ខ្លះលិចទឹក មានជម្ងឺឆ្លង សម្បូរសត្វល្អិតបំផ្លាញ។ គាត់បានបញ្ជាក់ទៀតថា បើសិនគ្មានទឹកលិចទេ ពួកគាត់អាចដាំបាន ៦ទៅ៧ដង ឯណោះក្នុងមួយឆ្នាំ តែបើលិច

ទឹកវិញ គាត់អាចដាំបាន ៣ទៅ៤ដង ប៉ុណ្ណោះ ព្រោះដំណាំដែលពួកគាត់ដាំដុះមានដូចជា ស្ពៃចង្កឹះ ស្ពៃក្រញាញ់ ស្ពៃតឿ ស្ពៃខ្មៅ ចំណាយពេលតែ២៨ ទៅ ១ខែ១០ថ្ងៃ បានប្រមូលផលហើយ ឯប្រភេទដូចជាស្ពៃក្តោប ខាត់ណា ត្រូវចំណាយពេលដល់ទៅ ២ខែកន្លះ ទៅ៣ខែបានប្រមូលផល។ តែគាត់ដាំបន្លែសុវត្ថិភាពគឺមិនគិតរដូវឡើយ ព្រោះមានកុងត្រាជាមួយក្រុមហ៊ុន ដូច្នេះគឺពួកគាត់ដាំដុះពេញមួយឆ្នាំតែម្តង។

### ២.២.៣. ប្រភពទឹក

ទឹកគឺជាប្រភពមួយដ៏សំខាន់ក្នុងដំណើរការដាំដុះដែលប្រជាកសិករប្រើសម្រាប់ស្រោចស្រពដំណាំ។ ប្រសិនបើគ្មានទឹកគ្រប់គ្រាន់ទេ ពួកគាត់មិនអាចប្រកបរបរដាំដំណាំបានឡើយ។ តាមការចុះទៅដល់មូលដ្ឋាន យើងឃើញថានៅតាមផ្លូវគឺមានទន្លេដែលជាប្រភពទឹកសម្រាប់ប្រជាកសិករដែលស្ថិតនៅតំបន់ឃុំស្វាយប្រទាលនោះ តែពួកគាត់មិនប្រើប្រាស់ឡើយ។ តាមការសម្ភាសកសិករម្នាក់ដែលដាំដុះបន្លែសុវត្ថិភាពបានបញ្ជាក់ថា ពួកគាត់មានការលំបាកក្នុងការទាញយកទឹកពីទន្លេ ព្រោះត្រូវការទុយោវែងទើបគាត់មានការលំបាក ដូច្នេះទើបពួកគាត់ជីកអណ្តូងនៅក្បែរផ្ទះ ដើម្បីងាយស្រួលដល់ការស្រោចស្រពដំណាំរបស់គាត់។ ដំណាំប្រភេទនេះក៏រើសទឹកដែរ ដូច្នេះការជីកអណ្តូងដាក់ម៉ូទ័រនេះ គឺអាចជួយឱ្យគាត់ដាំដុះបានគ្រប់រដូវ។

### ២.២.៤. ការប្រមូលផល

រាល់ការប្រមូលផល គឺធ្វើឡើងនៅពេលដែលបន្លែនីមួយៗអាចប្រមូលផលបាន។ ការប្រមូលផលគឺស្ថិតទៅតាមប្រភេទបន្លែដូចជាៈ

- ស្ពៃក្រញាញ់ ស្ពៃចង្កឹះ ស្ពៃតឿ និងស្ពៃខ្មៅ រយៈពេល ២៨ ទៅ ៣៥ថ្ងៃ គឺអាចប្រមូលផលបាន
- ស្ពៃក្តោប រយៈពេលថេរ ៣ខែ ទើបអាចប្រមូលផលបាន
- ខាត់ណា រយៈពេលពី ២ខែ ១៥ថ្ងៃ ទៅ ខែ ទើបអាចប្រមូលផលបាន។[៣៤]

បើសិនជាដីមានជីវជាតិល្អ ការប្រមូលផលអាចនឹងបានធ្វើមុនរយៈពេលកំណត់ តែបើមិនសូវល្អទេអាចនឹងយូរជាង២ថ្ងៃ ទៅ៣ថ្ងៃ។

ការប្រមូលផល ភាគច្រើនពួកគាត់ជាអ្នកច្រូតកាត់ដោយខ្លួនឯង តែបើដីធំ ពួកគាត់ជួលគេក្នុងមួយថ្ងៃ ២ទៅ៣ម៉ឺនរៀល។ នៅក្រោយពេលច្រូតកាត់រួចគឺមានក្រុមហ៊ុនដែលបានចុះកុងត្រាជាមួយពួកគាត់នឹងទៅយកដល់ចម្ការតែម្តង ពួកគាត់មិនចាំបាច់លំបាកដឹកជញ្ជូនទៅលក់ ឬព្រួយបារម្ភរឿងថ្លៃចុះថោកឡើយ ព្រោះកុងត្រាថ្លៃនិងបរិមាណផលិតផលបានកំណត់រួចរាល់មុនការដាំដុះរួចហើយ។

### ២.២.៥. ដើមទុន

ដើមទុនគឺពិតជាមានសារៈសំខាន់ណាស់ក្នុងការប្រកបរបរអ្វីមួយ មិនថាអ្នកស្រែចម្ការ រឺក៏អ្នកលក់ដូរឡើយ។ ដូចគ្នានេះដែរ ក្នុងការដាំបន្លែសុវត្ថិភាពនេះក៏ដូចគ្នា ប្រសិនបើដើមទុនគាត់តិច ទិន្នផលដែលគាត់

[៣៤] ទិន្នន័យការសម្ភាសន៍ប្រជាកសិករដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល, ឆ្នាំ២០២០

ទទួលបានក៏តិចតាមហ្នឹងដែរ តែបើដើមទុនគាត់ច្រើន ទិន្នផលដែលគាត់ទទួលបានក៏ច្រើនតាមហ្នឹងដែរ។ ជារួមកសិករដាំបន្លែចំណាយដើមទុនទៅលើ ពូជ ជី ថ្នាំ ឈ្នួល... ដែលភាគច្រើនជារបស់ខ្លួនឯង តិចតួចណាស់ក្នុងការខ្ចីគេ។បើតាមបងស្រីម្នាក់ដែលកំពុងប្រកបរបរដាំបន្លែសុវត្ថិភាពនេះបានឱ្យដឹងថា គាត់ចំណាយទុនអស់តិចជា ដាំបន្លែគីមី ព្រោះគាត់មិនសូវចំណាយទៅលើការប្រើប្រាស់ថ្នាំ និងជីឡើយ។

## ២.២.៦. ស្ថានភាពទីផ្សារបន្លែសុវត្ថិភាព

### ២.២.៦.១.ទីផ្សារបន្លែសុវត្ថិភាព

ទីផ្សារ ជាកន្លែងដែលអ្នកលក់និងអ្នកទិញជួបគ្នាដើម្បីដោះដូរផលិតផល និងជាកន្លែងដែលបញ្ជាក់ពីប្រភេទទំនិញដែលអ្នកលក់បានដាក់តាំងលក់ដែលអ្នកទិញអាចដើររកទិញដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួនក្នុងតំបន់ភូមិសាស្ត្រណាមួយ និងនៅក្នុងរយះពេលកំណត់មួយ ក្នុងតម្លៃសមរម្យដែលព្រមព្រៀងរវាងអ្នកលក់ និងអ្នកទិញ។ តាមរយៈការចុះសិក្សាស្រាវជ្រាវ និងសាកសួរជាមួយប្រជាកសិករដោយផ្ទាល់នៅឃុំស្វាយប្រទាលនេះបានអោយដឹងថា បន្លែអំបូរស្ពៃជាប្រភេទស្លឹកដែលពួកគាត់បានដាំ គឺមានការចុះកុងត្រាជាមួយភ្នាក់ងារកសិកម្ម (ក្រុមហ៊ុនមាសបៃតង) ដែលមានការបញ្ជារទិញ និងក្នុងតម្លៃដែលសមរម្យបំផុតទៅតាមតម្លៃទីផ្សារដែលធ្វើអោយពួកគាត់មិនមានការព្រួយបារម្ភរឿងខ្វះទីផ្សារឡើយ គាត់បានបន្ថែមទៀតមុនពេលដាំដុះគឺខាងភ្នាក់ងារកសិកម្មជាអ្នកកំណត់ប្រភេទដំណាំអោយពួកគាត់ដាំដុះ រឿងដែលសំខាន់គឺពួកគាត់ត្រូវខិតខំក្នុងការដាំដុះអោយបានទិន្នផលខ្ពស់ ដល់ពេលប្រមូលផលគឺខាងភ្នាក់ងារចុះទៅដល់ចំការតែម្តង ដែលបង្ករភាពងាយស្រួល និងចំណេញពេលវេលាដល់ពួកគាត់ ក្នុងការសម្អាត និងរៀបចំដីដើម្បីដាំសារជាថ្មីម្តងទៀត។

តាមរយៈការសម្ភាសផ្ទាល់មួយកសិករ អំពីរដូវកាលដែលបន្លែស្ពៃមានតម្លៃខ្ពស់ និងទាបបំផុតនោះពួកគាត់បានមានប្រសាសន៍ថា នៅកំឡុងខែមីនា និងខែមេសា អាចលក់បានតម្លៃខ្ពស់ ព្រោះតំបន់មួយចំនួនក្នុងប្រទេសមានការខ្វះខាតទឹកសម្រាប់ស្រោចស្រព ជាហេតុដែលធ្វើអោយការផ្គត់ផ្គង់បន្លែនៅលើទីផ្សារមានការថយចុះនិងធ្វើអោយថ្លៃកើនឡើង។ រីឯនៅក្នុងរដូវវស្សាវិញ បន្លែអាចលក់បានតម្លៃថ្លៃភាគច្រើនក្នុងអំឡុងខែឧសភា និងខែមិថុនា ព្រោះរដូវប្រាំងទើបតែបញ្ចប់ ហើយពុំទាន់មានភ្លៀងធ្លាក់ច្រើននៅឡើយ តម្លៃដែលជាមធ្យមចន្លោះពី ២០០០រៀល ដល់ ៣០០០រៀល ពួកគាត់បានបន្តទៀតថាទោះបីនៅរដូវសម្បូរឬខ្វះ និងតម្លៃមានការប្រែប្រួលក៏ដោយ ពួកគាត់នៅតែបន្តដាំជាធម្មតាដោយមានណែនាំពីភ្នាក់ងារកសិកម្ម នៅរដូវខ្វះខាងភ្នាក់ងារនិងអោយពួកបង្កើនការដាំដុះ និងនៅសម្បូរពួកនិងកាត់បន្ថយបរិមាណដាំដុះ ។

### ២.២.៦.២. បណ្តាញបែងចែកផលិតផលដំណាំបន្លែ

ផលិតផលបន្លែដែលប្រជាកសិករដាំបាននៅឃុំស្វាយប្រទាល គឺត្រូវបានចែកចាយពីម្ចាស់ចម្ការ ផ្ទាល់ទៅអោយភ្នាក់ងារកសិកម្ម បន្ទាប់មកខាងភ្នាក់ងារកសិកម្មធ្វើការលាងសម្អាតនិងវេចខ្ចប់រួចទើបបញ្ជូនទៅកាន់ទីស្នាក់ការកណ្តាលនៅភ្នំពេញ (ក្រុមហ៊ុនមាសបៃតង) ក្រោយមកធ្វើការបែងចែកទៅសាខាដែលមានដូច

ជា សាខាផ្សារដើមគរ សាខាទួលគោក សាខាផ្សារថ្មី សាខាទួលទំពូង។ល។ ដើម្បីបញ្ជូនដល់អ្នកប្រើប្រាស់ចុងក្រោយ។

គំនូសបំព្រួញទី១៖ ការបង្ហាញអំពីការបែងចែកបន្លែសុវត្ថិភាពទៅទីផ្សារ




### ២.២.៦.៣. បញ្ហាទីផ្សារបន្លែរបស់កសិករក្នុងឃុំស្វាយប្រទាល

ការសិក្សាលើផ្នែកផលិតកម្មបន្លែ បានបង្ហាញថាទីផ្សារមានតួនាទីសំខាន់ក្នុងផលិតកម្មបន្លែ ។ តំបន់ផលិតកម្មបន្លែខុសគ្នា តម្លៃរបស់បន្លែក៏មានតម្លៃខុសគ្នាផងដែរ និងមានប្រែប្រួលពីមួយរដូវទៅមួយរដូវ។ ហើយការប្រែប្រួលកើនឡើងឬធ្លាក់ចុះថ្លៃនៅលើទីផ្សារអាស្រ័យលើតម្រូវការ និងផ្គត់ផ្គង់។ ម្យ៉ាងទៀតតាមប្រសាសន៍របស់លោកពូដែលជាអនុប្រធានសហគមន៍បានប្រាប់អោយដឹកថា ពេលខ្លះផលិតផលអាចផ្គត់ផ្គង់មិនគ្រប់គ្រាន់ និងពេលខ្លះអាចលើសជាក់ស្តែងនៅរដូវវស្សាផលដំណាំមួយចំនួនអាចនិងទទួលរងការខូចខាតដោយ សារទឹកភ្លៀង ដែលធ្វើអោយការផ្គត់ផ្គង់ខ្វះ ហើយពេលខ្លះការប្រមូលផលដំណាលគ្នាជាហេតុធ្វើបរិមាណផលិតផលលើសតម្រូវការ ។ លោកពូបានបន្ថែមទៀតថា នៅដើមឆ្នាំ២០២០ គឺចាប់តាំងពីខែមីនាមក ដោយសារជំងឺរាតត្បាតជាសកល កូវីត១៩ បញ្ហាទីផ្សារដែលជួបប្រទះ គឺបរិមាណត្រូវការនៅលើទីផ្សារកាត់បន្ថយប្រមាណ៤០% ដែលធ្វើអោយកសិករត្រូវបន្ថយបរិមាណផ្គត់ផ្គង់ ប៉ុន្តែតម្លៃទីផ្សារវិញគឺមិនថយចុះខ្លាំងដូចការដាំបន្លែគីមីដែលគាត់ធ្លាប់ធ្វើឡើយ។

### ២.២.៦.៤. ដំណោះស្រាយបញ្ហាទីផ្សារ

ជាធម្មតាថ្លៃបន្លែនៅលើទីផ្សារ មានការប្រែប្រួលខ្លាំង និងឆាប់រហ័ស ប៉ុន្តែសម្រាប់ពួកគាត់ គឺមានការចុះកុងត្រាជាមួយក្រុមហ៊ុនរួចជាសម្រេច ដូច្នេះតម្លៃផលិតផលរបស់ពួកគាត់មិនសូវប្រឈម និងការធ្លាក់ថ្លៃខ្លាំងនោះទេ គឺនៅតែស្ថិតក្នុងតម្លៃសមរម្យដែលអាចអោយពួកគាត់ចំណេញបានជានិច្ច ។ យ៉ាងណាមិញ

ចំពោះការដាំដុះ គឺខាងភ្នាក់ងារកសិកម្មជាអ្នកបែងចែក និងកំណត់ប្រភេទដំណាំសម្រាប់ដាំដុះកុំអោយជាន់គ្នា ជានិច្ចជាកាលនៅពេលដែលផលិតផលលើសពីការកំណត់របស់ក្រុនហ៊ុន គឺពួកគាត់អាចលក់នៅក្នុងភូមិរបស់ពួកគាត់។

## ២.៣. ផែនការអនាគត

ការដាំបន្លែសុវត្ថិភាព គឺជាផ្នែកមួយដែលបានជួយទ្រទ្រង់ជីវភាពគ្រួសារឱ្យកាន់តែប្រសើរឡើង ដែលប្រជាកសិករនៅក្នុងឃុំស្វាយប្រទាលបានចាប់យកជាមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ក្រោយពីទទួលបានភាពជោគជ័យក្នុងការដាំដុះបន្លែសុវត្ថិភាពតាមរយៈការអនុវត្តន៍កសិកម្មល្អ ពួកគាត់កាន់តែមានបំណងយ៉ាងមុតមាំក្នុងការអភិវឌ្ឍវិស័យនេះឱ្យកាន់តែរីកចម្រើន។ ដូច្នេះដើម្បីឱ្យការដាំដុះបន្លែសុវត្ថិភាពរបស់គាត់ទទួលបានជោគជ័យកាន់តែខ្លាំងថែមទៀត ពួកគាត់មានគម្រោងនៅថ្ងៃអនាគតដូចជា៖

- បង្កើនផ្ទៃដីដាំដុះបន្ថែមទៀត ដើម្បីទទួលបានប្រាក់ចំណូលកាន់តែច្រើនក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ
- សិក្សាពីបច្ចេកទេសដាំដុះថ្មីៗបន្ថែម ឱ្យកាន់តែទំនើប និងមានភាពងាយស្រួល ដើម្បីបង្កើនទិន្នផល
- បង្កើនទិន្នផលឱ្យកាន់តែច្រើន និងមានគុណភាពខ្ពស់
- បង្កើតទីផ្សារបន្ថែមទៀត (បណ្តាញចែកចាយ)
- បង្កើនចំនួនគ្រួសារក្នុងសហគមន៍ដាំបន្លែសុវត្ថិភាពរបស់ពួកគាត់
- ណែនាំកសិករដែលកំពុងដាំដុះបន្លែគីមីឱ្យងាកមកដាំបន្លែសុវត្ថិភាពវិញដើម្បីទទួលបានសុខភាពល្អទាំងអ្នកដាំដុះ និងអ្នកទទួលទាន
- កាត់បន្ថយចំណាយ ដើម្បីបង្កើនចំណូល និងសិក្សាពីទីផ្សារដើម្បីផ្គត់ផ្គង់តាមតម្រូវការទីផ្សារ
- ក្រោយពីទទួលបានជោគជ័យក្នុងការដាំដុះបន្លែសុវត្ថិភាព ពួកគាត់មានគម្រោងបង្កើតមុខរបរបន្ថែមទៀតដូចជា ចិញ្ចឹមសត្វ លក់ដូរតាមផ្ទះ និងបញ្ជូនកូនៗរបស់គាត់ឱ្យបានរៀនចប់គ្រប់ៗគ្នា
- សាងសង់ផ្ទះធំល្មមសម្រាប់គ្រួសារ។

❖ **សេចក្តីសន្និដ្ឋាន**

តាមរយៈការសិក្សាស្រាវជ្រាវបានបញ្ជាក់ឱ្យឃើញថា ឃុំស្វាយប្រទាលជាឃុំមួយដែលស្ថិតនៅស្រុកស្អាងខេត្តកណ្តាល ជាឃុំមួយដែលមានលក្ខណៈអំណោយផលពីធម្មជាតិសម្រាប់ការធ្វើកសិកម្ម ដោយមានប្រភពទឹកគ្រប់គ្រាន់ ដីមានជីវជាតិ និងមានផ្លូវគមនាគមន៍ខ្វាត់ខ្វែងងាយស្រួលក្នុងការធ្វើដំណើរទៅមក។ ម្យ៉ាងវិញទៀត បើក្រឡេកមើលលើជីវភាពប្រជាជនក្នុងឃុំនេះ ភាគច្រើនប្រមាណជាង៧០%សុទ្ធសឹងតែជាកសិករដែលមានជំនាញក្នុងការធ្វើកសិកម្ម ដែលជាទូទៅ មានដូចជាការធ្វើស្រែ ចម្ការ នឹងដាំបន្លែបង្កាដើម្បីចិញ្ចឹម ជីវិត។ ក្នុងនោះដែរ ដំណាំដែលប្រជាកសិករនិយមដាំដុះគឺដំណាំបន្លែអម្បូរស្លឹក ដែលជាដំណាំ

ឈានមុខគេ ងាយស្រួលដាំដុះ ប្រើរយៈពេលខ្លី អាចដាំដុះបានច្រើនដងក្នុងមួយឆ្នាំ អាចធ្វើឱ្យពួកគេអាចរកប្រាក់ចំណេញបានច្រើនក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។ ជាពិសេស បន្ទាប់ពីទទួលបានភាពជោគជ័យ ដំណាំបន្លែសុវត្ថិភាពកំពុងតែទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកប្រើប្រាស់ជម្រុញឱ្យតម្រូវការនៅក្នុងទីផ្សារមានការកើនឡើង ដែលជម្រុញឱ្យកសិករខិតខំប្រឹងប្រែងបង្កបង្កើនផល ដើម្បីផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ។

តាមរយៈការដាំដុះបន្លែសុវត្ថិភាពនេះធ្វើឱ្យប្រាក់ចំណូលក្នុងគ្រួសារមានការកើនឡើង ធ្វើឱ្យការរស់នៅរបស់ពួកគាត់ប្រសើរជាងមុន ដែលពុំចាំបាច់ទៅធ្វើការឆ្ងាយពីផ្ទះឡើយ។

# ជំពូកទី៣

# ការវិភាគទិន្នន័យ

# និងលទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

តាមរយៈការបកស្រាយនៅក្នុងជំពូកទី១ និងជំពូកទី២ អាចឱ្យយើងបានដឹងកាន់តែច្បាស់ អំពីទ្រឹស្តីមួយចំនួន និងស្ថានភាពទូទៅរបស់ប្រជាជន ស្ថានភាពតំបន់ភូមិសាស្ត្រ និងស្ថានភាពផលិតកម្មបន្លែសុវត្ថិភាពនៅក្នុងឃុំស្វាយប្រទាល ដែលជាឃុំសក្តានុពលនៃផលិតកម្មបន្លែនៃស្រុកស្អាង ខេត្តកណ្តាល។ ចូលមកដល់ជំពូកទី៣នេះ យើងនឹងសិក្សាបកស្រាយទៅលើ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃផលិតកម្មបន្លែសុវត្ថិភាពរបស់ប្រជាកសិករដែលស្ថិតនៅក្នុងឃុំស្វាយប្រទាលនោះផ្ទាល់តែម្តង ថាតើ ពួកគាត់ចំណាយដើមទុនជាមធ្យមប៉ុន្មាន ហើយអាចទទួលបានចំណូលមកវិញជាមធ្យមប៉ុន្មានក្នុងមួយវដ្តផលិតកម្មដំណាំបន្លែសុវត្ថិភាពរបស់ពួកគាត់?

ដើម្បីទទួលបាននូវព័តមាន ក៏ដូចជាទិន្នន័យសម្រាប់ស្រាវជ្រាវ ពួកយើងបានបង្កើតកម្រងសំណួរមួយចំនួន ដែលទាក់ទងទៅនឹងផលិតកម្មបន្លែសុវត្ថិភាព និងជីវភាពរបស់ពួកគាត់ ហើយព្រមទាំងធ្វើការសម្ភាសគ្រួសារចំនួន២០គ្រួសារដែលស្ថិតនៅក្នុងឃុំស្វាយប្រទាលនោះ។

ទិន្នន័យដែលទទួលបានពីការសម្ភាស មានដូចខាងក្រោមនេះ៖

## ៣.១. ទិន្នន័យប្រជាសាស្ត្រ

### ៣.១.១. មេគ្រួសារ

#### ៣.១.១.១. ភេទនៃមេគ្រួសារ

តារាងទី ៣.១៖ ការបង្ហាញអំពីភេទរបស់មេគ្រួសារដែលជាកសិករ

| ភេទ | ចំនួនគ្រួសារ | គិតជាភាគរយ |
|---|---|---|
| ប្រុស | ១៤ | ៧០% |
| ស្រី | ៦ | ៤០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិនន្ន័យឆ្នាំ២០២០

តាមរយៈទិន្នន័យនៃតារាងខាងលើ ក្នុងចំណោមមេគ្រួសារទាំង ២០គ្រួសារ ក្នុងនោះមានស្ត្រីដែលជាមេគ្រួសារតែ ៦នាក់ប៉ុណ្ណោះដែលស្មើនឹង ៤០% ដែលត្រូវបានសម្ភាសន៍ ឯក្រៅពីនេះសុទ្ធតែជាបុរស ដែលជាមេគ្រួសារ ជាអ្នករ៉ាប់រងការផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូលតែម្តង។

#### ៣.១.១.២. ក្រុមអាយុនៃមេគ្រួសារ

អាយុគឺជាការវិវត្តនៃវ័យ ដែលអាចបញ្ជាក់ថាអាយុបាននូវកំណត់បាននូវកម្លាំងកាយ និងកម្លាំងប្រាជ្ញា។

អាយុគឺជាការវិវត្តនៃវ័យ ដែលអាចបញ្ជាក់ថាអាយុបាននូវកំណត់បាននូវកម្លាំងកាយ និងកម្លាំងប្រាជ្ញា។ កាលណាដែលនូវវ័យក្មេងពេក កម្លាំងក៏មិនអាចប្រើប្រាស់បានខ្លាំង ឯភាពវាងវៃក៏ពុំសូវមានគ្រប់គ្រាន់ផង ដែរ។ កាលណាដែលពេញវ៉ៃ កម្លាំងក៏មានគ្រប់គ្រាន់ ឯភាពឈ្លាសវៃក៏សមស្រប ទើបអាចចូលរួមក្នុងកត្តាផលិតកម្មបាន។ ដូចគ្នានេះដែរ អាយុពិតជាដើរតួយ៉ាងសំខាន់ណាស់ក្នុងកត្តាផលិតកម្មកសិកម្ម។ កាលណាដែលអាយុក្មេងពេក និងចាស់ពេក មិនអាចចូលរួមក្នុងកត្តាផលិតកម្មបានពេញលេញ១០០%នោះទេ ដូច្នេះមិនអាចជួយឱ្យផលិតភាពកើនឡើងទេ ជួនកាលអាចនឹងធ្លាក់ចុះថែមទៀត។ កាលណាវ័យពេញកម្លាំង មានកម្លាំងគ្រប់ មានបទពិសោធន៍ច្រើនបូករួមជាមួយនឹងប្រាជ្ញាថែមទៀត នោះនឹងអាចឱ្យទិន្នផលបន្លែសុវត្ថិភាពរបស់ពួកគាត់មានការកើនឡើងតាមរយៈការចូលរួមក្នុងកត្តាផលិតកម្មបានពេញលេញរបស់គាត់។

តាមរយៈតារាងខាងក្រោម និងសិក្សាអំពីក្រុមអាយុនៃមេគ្រួសារដែលផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់ដែលប្រកបរបរដាំដុះបន្លែសុវត្ថិភាព៖

តារាងទី ៣.២៖ ការបង្ហាញអំពីក្រុមអាយុរបស់មេគ្រួសារដែលជាកសិករ

| ក្រុមអាយុ | ចំនួន | ចំនួនជាភាគរយ |
|---|---|---|
| ២០-២៩ ឆ្នាំ | ២ | ១០% |
| ៣០-៣៩ ឆ្នាំ | ២ | ១០% |
| ៤០-៤៩ ឆ្នាំ | ៥ | ២៥% |
| ៥០-៥៩ ឆ្នាំ | ៧ | ៣៥% |
| ៦០ឆ្នាំឡើងទៅ | ៤ | ២០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ ២០២០

តាមរយៈទិន្នន័យនៃតារាងខាងលើ ចង់បញ្ជាក់អំពីអាយុនៃមេគ្រួសារដែលចូលរួមក្នុងផលិតកម្មបន្លែសុវត្ថិភាព ដែលចែកជា៥ក្រុមអាយុដូចទៅ៖

- មេគ្រួសារដែលមានអាយុចាប់ពី ២០ឆ្នាំ ទៅ ២៩ឆ្នាំ មានចំនួន ២គ្រួសារ ដែលស្មើនឹង១០%
- មេគ្រួសារដែលមានអាយុចាប់ពី ៣០ឆ្នាំ ទៅ ៣៩ឆ្នាំ មានចំនួន ២គ្រួសារ ដែលស្មើនឹង ១០%
- មេគ្រួសារដែលមានអាយុចាប់ពី ៤០ឆ្នាំ ទៅ ៤៩ឆ្នាំ មានចំនួន ៥គ្រួសារ ដែលស្មើនឹង ២៥%
- មេគ្រួសារដែលមានអាយុចាប់ពី ៥០ឆ្នាំ ទៅ ៥៩ឆ្នាំ មានចំនួន ៧គ្រួសារ ដែលស្មើនឹង ៣៥%
- មេគ្រួសារដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ មានចំនួន ៤គ្រួសារ ដែលស្មើនឹង ២០%។

តាមរយៈទិន្នន័យជាតួរលេខដែលបានរៀបរាប់ខាងលើ យើងអាចបញ្ជាក់បានថា មេគ្រួសារដែលស្ថិតនៅចន្លោះអាយុ ៥០ទៅ៦០ឆ្នាំ មានចំនួនច្រើនជាងគេ ព្រោះពួកគាត់មានបទពិសោធន៍ច្រើនរួមជាមួយនឹងកម្លាំងគាត់ក៏នៅមានគ្រប់គ្រាន់ក្នុងការដាំដុះបន្លែសុវត្ថិភាពដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់។

### ៣.១.២. ចំនួនសមាជិកគ្រួសារ

ចំនួនសមាជិកក្នុងគ្រួសារ គឺជាកត្តាមួយដែលជួយជម្រុញដល់ការធ្វើកសិកម្មរបស់ប្រជាកសិករគ្រប់រូប ព្រោះកាលណាដែលចំនួនសមាជិកគ្រួសារមានច្រើន នោះនឹងជួយសម្រួលដល់កម្លាំងពលកម្មក្នុងដំណើរការផលិតកម្មកសិកម្ម ព្រមទាំងកាត់បន្ថយការចំណាយផងដែរ។ ប៉ុន្តែមិនប្រាកដថាអាចជួយបានទាំងស្រុងនោះទេ ទាល់តែសមាជិកនីមួយៗពេញវ័យ មានកម្លាំងពេញលេញជាមុនសិន។

នៅក្នុងផលិតកម្មបន្លែសុវត្ថិភាព គ្រួសារដែលមានសមាជិកច្រើន ហើយសុទ្ធតែពេញកម្លាំងទទួលបាននូវគុណប្រយោជន៍ដូចជា ជួយជម្រះស្មៅ ធ្វើដី លើករង ស្រោចទឹកដំណាំ ជួយមើលថែដំណាំបានយ៉ាងល្អ ជាពិសេសនៅពេលប្រមូលផលមិនចំបាច់ជួលគេផងដែរ ជារួមគឺវាបានជួយកាត់បន្ថយការចំណាយបានមួយភាគធំទៅលើការជួលកម្លាំងពលកម្ម។ មិនតែប៉ុណ្ណោះ ក្រៅពីការងារផ្ទះរបស់ខ្លួន ពេកគាត់អាច ស៊ីឈ្នួលជម្រាស្មៅ ច្រូតកាត់បន្លែ និងបាញ់ថ្នាំ ដើម្បីទទួលបានកម្រៃថែមទៀតផងដែរ។ ក្រៅពីនេះអាចប្រកបរបរនេសាទ ដឹកជញ្ជូនបន្លែឱ្យគេបានថែមទៀត។

ត្បិតតែចំនួនសមាជិកគ្រួសារច្រើនផ្តល់អត្ថប្រយោជន៍ច្រើនក៏ពិតមែន ប៉ុន្តែទន្ទឹមនឹងនោះក៏មានផលវិបាកច្រើនដែរ ដូចជា ការចំណាយទៅលើការចាយវាប្រចាំថ្ងៃច្រើន ហើយម្យ៉ាងវិញទៀតសមាជិកគ្រួសារមួយចំនួន នៅក្មេង និងចាស់ជរា មានជម្ងឺឈឺថ្កាត់ច្រើន មិនអាចចូលរួមក្នុងដំណើរការផលិតកម្មកសិកម្មបាន ហើយត្រូវចំណាយទៅលើការទិញថ្នាំសង្កូវថែមទៀតផង។ ដូច្នេះត្រូវចំណាយច្រើនទៅលើគ្រួសារផង និងទៅលើថ្លៃឈ្នួលផង ជាហេតុឱ្យពួកគាត់មានចំណាយច្រើនជាងចំណូល។

ដោយសារចំនួនសមាជិកក្នុងគ្រួសារ មានទាំងគុណសម្បត្តិ និងគុណវិបត្តិទើបធ្វើឱ្យជីវភាពរបស់កសិករនីមួយៗមិនដូចគ្នាឡើយ។ គ្រួសារខ្លះមានជីវភាពធូរធាដោយសារតែមានសមាជិកច្រើន ខ្លះក៏ធូរធាដោយសារមានចំនួនគ្រួសារសមល្មម តែមិនទាំងស្រុងនោះទេ អាចពឹងផ្អែកទៅលើបច្ចេកទេសដាំដុះរបស់ពួកគាត់ ក៏ដូចជាដីមានជីវជាតិស្រាប់ផងដែរ។ កសិករខ្លះមានចំនួនសមាជិកតិចតែគឺមានបច្ចេកទេសដាំដុះពូកែចេះសន្សំ ក៏ទទួលបានជីវភាពធូរធា ឯកសិករខ្លះមានសមាជិកច្រើនមែនប៉ុន្តែគ្មានបច្ចេកទេស បទពិសោធន៍នៅខ្វះ ដូច្នេះក៏ពុំសូវគាប់ប្រសើរ ក៏ខាតបង់ទៅ។

តារាងខាងក្រោម គឺជាតារាងដែលបង្ហាញពីចំនួនសមាជិកគ្រួសារ របស់ក្រុមកសិករដែលដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាលៈ

តារាងទី៣.៣៖ការបង្ហាញអំពីចំនួនសមាជិកគ្រួសាររបស់កសិករដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល

| ចំនួនសមាជិកគ្រួសារ | ចំនួនជាគ្រួសារ | ចំនួនជាភាគរយ(%) |
|---|---|---|
| ២ទៅ៣នាក់ | ២ | ១០% |
| ៤ទៅ៥នាក់ | ៩ | ៤៥% |
| ៦ទៅ៧នាក់ | ៥ | ២៥% |
| ចាប់ពី៨នាក់ឡើងទៅ | ៤ | ២០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើ បានបង្ហាញឱ្យដឹងថា៖

- គ្រួសារដែលមានសមាជិក ពី២ទៅ៣នាក់ មានចំនួន ២គ្រួសារ ដែលស្មើនឹង ១០%
- គ្រួសារដែលមានសមាជិក ពី៤ទៅ៥នាក់ មានចំនួន ៩គ្រួសារ ដែលស្មើនឹង ៤៥%
- គ្រួសារដែលមានសមាជិក ពី៦ទៅ៧នាក់ មានចំនួន ៥គ្រួសារ ដែលស្មើនឹង ២៥%
- គ្រួសារដែលមានសមាជិក ពី៨នាក់ឡើងទៅ មានចំនួន ៤គ្រួសារ ដែលស្មើនឹង ២០%។

តាមរយៈការបកស្រាយខាងលើបានបង្ហាញឱ្យឃើញថា កសិករភាគច្រើនមានចំនួនគ្រួសារមធ្យម ដែលមានស្ថិតនៅចន្លោះ ៤ទៅ៦នាក់ ដែលធ្វើឱ្យពួកគាត់មានចំណាយទៅលើជីវភាពប្រចាំថ្ងៃសមល្មម ហើយការមានកម្លាំងពលកម្មសម្រាប់ជួយក្នុងការដាំដុះបន្លែសុវត្ថិភាពផងដែរ។

### ៣.១.៣. ចំនួនកម្លាំងពលកម្មក្នុងគ្រួសារ

កម្លាំងពលកម្មក្នុងគ្រួសារ សំដៅលើសមាជិកដែលមានកម្លាំងពេញលេញ ដែលស្ថិតនៅក្នុងវ័យអាចជួយរកប្រាក់ផ្គត់ផ្គង់ក្នុងគ្រួសារតាមរយៈការចូលរួមក្នុងដំណើរផលិតកម្មកសិកម្មបានយ៉ាងពេញលេញ។

តារាងទី៣.៤៖ ការបង្ហាញអំពីចំនួនពលកម្មរបស់គ្រួសារនីមួយៗក្នុងការដាំបន្លែសុវត្ថិភាព

| កម្លាំងពលកម្មក្នុងគ្រួសារ | ចំនួនគ្រួសារ | ចំនួនជាភាគរយ(%) |
|---|---|---|
| ១ នាក់ | ១ | ៥% |
| ២ នាក់ | ៧ | ៣៥% |
| ៣ នាក់ | ៤ | ២០% |
| ៤ នាក់ | ២ | ១០% |

| | | |
|---|---|---|
| ៥ នាក់ | ៣ | ១៥% |
| ៦ នាក់ | ៣ | ១៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើ បានបង្ហាញឱ្យយើងដឹងបានថា៖

- គ្រួសារដែលមានកម្លាំងពលកម្ម ១នាក់ មានចំនួន ១គ្រួសារ ដែលស្មើនឹង ៥%
- គ្រួសារដែលមានកម្លាំងពលកម្ម ២នាក់ មានចំនួន ៧គ្រួសារ ដែលស្មើនឹង ៣៥%
- គ្រួសារដែលមានកម្លាំងពលកម្ម ៣នាក់ មានចំនួន ៤គ្រួសារ ដែលស្មើនឹង ២០%
- គ្រួសារដែលមានកម្លាំងពលកម្ម ៤នាក់ មានចំនួន ២គ្រួសារ ដែលស្មើនឹង ១០%
- គ្រួសារដែលមានកម្លាំងពលកម្ម ៥នាក់ មានចំនួន ៣គ្រួសារ ដែលស្មើនឹង ១៥%
- គ្រួសារដែលមានកម្លាំងពលកម្ម ៦នាក់ មានចំនួន ៣គ្រួសារ ដែលស្មើនឹង ១៥%។

## ៣.២. ប្រភេទបន្លែ

ជាទូទៅ ប្រភេទបន្លែត្រូវបានចុះកុងត្រាជាមួយភ្នាក់ងារទីផ្សារ (មាសបៃតង) ក្នុងការកំណត់ប្រភេទពូជដាំដុះ។

ក្រាបទី ៣.១៖ ការបង្ហាញអំពីប្រភេទបន្លែសុវត្ថិភាពដែលកសិករដាំដុះ




ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈក្រាបបានបង្ហាញឱ្យយើងឃើញថា ដំណាំបន្លែសុវត្ថិភាពដែលកសិករនៅក្នុងឃុំស្វាយប្រទាលដាំដុះគឺមាន៤ប្រភេទដូចជា៖ ស្ពៃខ្មៅ១០% ស្ពៃតឿ៣០% ស្ពៃចង្កឹះ២៥% និងស្ពៃក្រញាញ់៣៥%។

## ៣.៣. រយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព

ជាទូទៅកសិករនៅក្នុងឃុំស្វាយប្រទាល បានចំណាយពេលជាមួយការប្រកបរបរដាំបន្លែសុវត្ថិភាពក្នុងរយៈពេលផ្សេងៗគ្នា ខ្លះក៏ប្រកបរបរនេះជាយូរឆ្នាំមកហើយ ឯខ្លះទៀតរយៈពេលខ្លី តែយ៉ាងណាមិញទិន្នន័យនៃរយៈពេលនោះត្រូវបានលើកយកមកបង្ហាញតាមរយៈតារាងខាងក្រោមនេះ៖

តារាងទី៣.៥៖ ការបង្ហាញអំពីរយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| ៣ឆ្នាំ | ៥ | ២៥% |
| ៤ឆ្នាំ | ៥ | ២៥% |
| ៥ឆ្នាំ | ៣ | ១៥% |
| ៦ឆ្នាំ | ៤ | ២០% |
| ៧ឆ្នាំ | ១ | ៥% |
| ៩ឆ្នាំ | ១ | ៥% |
| ១០ឆ្នាំ | ១ | ៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា៖

- កសិករដែលដាំដុះបាន ៣ឆ្នាំមានចំនួន៥គ្រួសារ ស្មើនឹង២៥%
- កសិករដែលដាំដុះបាន ៤ឆ្នាំមានចំនួន៥គ្រួសារ ស្មើនឹង២៥%
- កសិករដែលដាំដុះបាន ៥ឆ្នាំមានចំនួន៣គ្រួសារ ស្មើនឹង១៥%
- កសិករដែលដាំដុះបាន ៦ឆ្នាំមានចំនួន៤គ្រួសារ ស្មើនឹង២០%
- កសិករដែលដាំដុះបាន ៧ឆ្នាំមានចំនួន១គ្រួសារ ស្មើនឹង៥%
- កសិករដែលដាំដុះបាន ៩ឆ្នាំមានចំនួន១គ្រួសារ ស្មើនឹង៥%
- កសិករដែលដាំដុះបាន ១០ឆ្នាំមានចំនួន១គ្រួសារ ស្មើនឹង៥%។

## ៣.៤. ផ្ទៃដីដាំដុះ

ផ្ទៃដី គឺជាទុនផលិតកម្មមួយដែលមានសារៈសំខាន់ណាស់ក្នុងដំណើរការកសិកម្មក៏ដូចជាការដាំដុះបន្លែសុវត្ថិភាព។ កាលណាផ្ទៃដីធំ ទិន្នផលដែលទទួលបានក៏មានចំនួនច្រើនដែរ។ ម្យ៉ាងវិញទៀត តាមរយៈការសម្ភាស បានបង្ហាញថា កសិករមានផ្ទៃដីខុសៗគ្នា និងមានទំហំសមល្មមគ្រប់គ្រាន់សម្រាប់ការដាំដុះបន្លែសុវត្ថភាពរបស់ពួកគាត់។

តារាងទី៣.៦៖ ការបង្ហាញអំពីផ្ទៃដីក្នុងការដាំដុះបន្លែសុវត្ថិភាព

| ល.រ. | ផ្ទៃដីកសិកម្ម គិតជាម៉ែត្រការេ(ម$^{២}$) | ចំនួនគ្រួសារ | ចំនួនភាគរយ(%) |
|---|---|---|---|
| ១ | ១,២០០ | ១ | ៥% |
| ២ | ១,៦០០ | ២ | ១០% |
| ៣ | ២,០០០ | ១ | ៥% |
| ៤ | ៤,០០០ | ២ | ១០% |
| ៥ | ៥,០០០ | ៣ | ១៥% |
| ៦ | ៥,៥០០ | ១ | ៥% |
| ៧ | ៦,០០០ | ១ | ៥% |
| ៨ | ៧,០០០ | ៣ | ១៥% |
| ៩ | ៨,០០០ | ១ | ៥% |
| ១០ | ៩,០០០ | ១ | ៥% |
| ១១ | ១០,០០០ | ២ | ១០% |
| ១២ | ១២,០០០ | ១ | ៥% |
| ១៤ | ១៣,០០០ | ១ | ៥% |
| សរុប | ១២៣,៩០០ | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញឱ្យឃើញដូចខាងក្រោមនេះ៖

- គ្រួសារដែលមានផ្ទៃដីចន្លោះពី ០.១២ ហ.ត ដល់ ០.៥០ ហ.ត មានចំនួន ៩គ្រួសារ ឬស្មើនឹង ៤៥% នៃចំនួនគ្រួសារសរុប

- គ្រួសារដែលមានផ្ទៃដីលើសពី ០.៥ ហិចតា ដល់ ១ ហ.ត មានចំនួន ៩គ្រួសារ ឬស្មើនឹង ៤៥%នៃចំនួនគ្រួសារសរុប
- ចំណែកឯគ្រួសារដែលមានផ្ទៃដីច្រើនជាងគេ គឺ ជាង១ហ.ត ទៅ ១.៣ ហ.ត មានតែ ២គ្រួសារប៉ុណ្ណោះក្នុងចំណោម២០គ្រួសារ ដែលស្មើនឹង ១០%នៃចំនួនគ្រួសារសរុប។

ផ្ទៃដីជាមធ្យមរបស់កសិករក្នុង១គ្រួសារដែលដាំបន្លែនៅក្នុងឃុំស្វាយប្រទាលមានទំហំជាមធ្យមគឺ ៦,១៩៥ ម២ ដែលពួកគាត់ដាំដុះរៀងរាល់ថ្ងៃដើម្បីស្វែងរកប្រាក់ចំណេញផ្គត់ផ្គង់ជីវភាពគ្រួសារ។

### ៣.៤.១. ភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ

តារាងទី៣.៧៖ ការបង្ហាញអំពីភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| គ្រប់គ្រាន់ | ៩ | ៤៥% |
| មិនគ្រប់គ្រាន់ | ១១ | ៥៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា គ្រួសារដែលមានផ្ទៃដីដាំដុះគ្រប់គ្រាន់មានចំនួន ៩គ្រួសារ ស្មើនឹង៤៥% និងគ្រួសារដែលមានផ្ទៃដីដាំដុះមិនគ្រប់គ្រាន់មានចំនួន ១១គ្រួសារ ស្មើនឹង៥៥%។ ដូចនេះយើងអាចសន្និដ្ឋានកសិករភាគច្រើនមិនមានផ្ទៃដីដាំដុះគ្រប់គ្រាន់ឡើយ ពោលគឺពួកគាត់មានបំណងចង់ពង្រីកផ្ទៃដីដាំដុះបន្ថែមទៀតដើម្បីបង្កើនប្រាក់ចំណូលឱ្យបានច្រើនក្នុងការផ្គត់ផ្គង់គ្រួសារ។

### ៣.៤.២. កម្មសិទ្ធិផ្ទៃដី

តារាងទី៣.៨៖ ការបង្ហាញអំពីកម្មសិទ្ធិផ្ទៃដីដាំដុះ

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| កម្មសិទ្ធិផ្ទាល់ខ្លួន | ១២ | ៦០% |
| ជួលគេ | ២ | ១០% |
| ផ្ទាល់ខ្លួន និងជួលគេ | ៦ | ៣០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា គ្រួសារដែលមានដីជាកម្មសិទ្ធិផ្ទាល់ខ្លួនមានចំនួន១២គ្រួសារ ស្មើនឹង៦០% គ្រួសារដែលជួលដីគេដាំដុះមានចំនួន២គ្រួសារ ស្មើនឹង១០% និងគ្រួសារដែលមានដីជាកម្មសិទ្ធិផ្ទាល់ខ្លួននិងជួលគេផងមានចំនួន៦គ្រួសារ ស្មើនឹង៣០%។

## ៣.៥. ស្ថិតិដំណើរការផលិតកម្ម

### ៣.៥.១. ប្រភពដើមទុន

តារាងទី៣.៩៖ ការបង្ហាញអំពីប្រភពដើមទុន

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| ខ្លួនឯង | ១៥ | ៧៥% |
| ខ្ចីបងប្អូន | ២ | ១០% |
| កម្ចីឥណទាន | ៣ | ១៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា គ្រួសារដែលមានដើមទុនជារបស់ខ្លួនឯងមានចំនួន១៥គ្រួសារ ស្មើនឹង៧៥% គ្រួសារដែលបានខ្ចីដើមទុនពីបងប្អូនមានចំនួន២គ្រួសារ ស្មើនឹង១០% និងគ្រួសារដែលខ្ចីឥណទានមកប្រើប្រាស់ក្នុងដំណើរការផលិតកម្មមានចំនួន៣គ្រួសារ ស្មើនឹង១៥%។

### ៣.៥.២. ប្រភពនៃបច្ចេកទេសដាំដុះ

តារាងទី៣.១០៖ ការបង្ហាញពីប្រភពនៃជំនាញបច្ចេកទេសដាំដុះ

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| តាមរយៈអ្នកជិតខាង | ១ | ៥% |
| ភ្នាក់ងារកសិកម្ម | ១៦ | ៨០% |
| មន្ទីរកសិកម្ម | ៣ | ១៥% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា កសិករដែលប្រើបច្ចេកទេសដាំដុះបន្លែសុវត្ថិភាពតាមរយៈអ្នកជិតខាងមានចំនួន១គ្រួសារ ស្មើនឹង៥% គ្រួសារដែលទទួលបានការបណ្តុះបណ្តាលបច្ចេកទេសដាំដុះពីភ្នាក់ងារកសិកម្មមានចំនួន១៦គ្រួសារ ស្មើនឹង៨០% និងគ្រួសារដែលទទួលបានការបណ្តុះបណ្តាលពីមន្ទីរកសិកម្មមានចំនួន ៣គ្រួសារ ស្មើនឹង១៥%។

### ៣.៥.៣. គ្រាប់ពូជដាំដុះ

តារាងទី៣.១១៖ ការបង្ហាញអំពីប្រភពគ្រាប់ពូជ

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| សល់ពីការដាំមុនៗ | 0 | 0% |
| ទិញគេ | ២0 | ១00% |
| ភ្នាក់ងារកសិកម្ម | 0 | 0% |
| សរុប | ២0 | ១00% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២0២0

តាមរយៈតារាងខាងលើបានបង្ហាញថា ក្នុងចំណោមកសិករទាំង២0គ្រួសារ ពូជដែលពួកគាត់ប្រើប្រាស់ដុះដាំសុទ្ធតែទិញគេទាំងអស់ ដែលស្មើនឹង១00%។

### ៣.៥.៤. ប្រភពទឹកស្រោចស្រព

តារាងទី៣.១២៖ ការបង្ហាញអំពីប្រភពទឹកស្រោចស្រព

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| ទន្លេ | ៣ | ១៥% |
| អណ្តូង | ១៥ | ៧៥% |
| ស្រះ | ២ | ១0% |
| សរុប | ២0 | ១00% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២0២0

តាមរយៈតារាងខាងលើបានបង្ហាញថា  កសិករដែលប្រើប្រាស់ទឹកទន្លេសម្រាប់ស្រោចស្រពផលដំណាំមានចំនួន៣គ្រួសារ ស្មើនឹង១៥% កសិករដែលប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពមានចំនួន១៥គ្រួសារ ស្មើនឹង៧៥% និងកសិករដែលប្រើប្រាស់ទឹកស្រះសម្រាប់ស្រោចស្រពមានចំនួន២គ្រួសារ ស្មើនឹង១0%។

### ៣.៥.៥. បរិមាណទឹកសម្រាប់ការដាំដុះ

តារាងទី៣.១៣៖ ការបង្ហាញអំពីបរិមាណទឹកសម្រាប់ប្រើប្រាស់

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| គ្រប់គ្រាន់ | ១៧ | ៨៥% |
| មិនគ្រប់គ្រាន់ | ៣ | ១៥% |

| | | |
|---|---|---|
| សរុប | ២០ | ១00% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា កសិករដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់សម្រាប់ស្រោចស្រពមានចំនួន១៧គ្រួសារ ស្មើនឹង ៨៥% ឯកសិករដែលមានប្រភពទឹកស្រោចស្រពមិនគ្រប់គ្រាន់មានចំនួន៣គ្រួសារ ស្មើនឹង១៥% ។

### ៣.៥.៦. ការប្រើប្រាស់ជី

តារាងទី៣.១៤៖ ការបង្ហាញអំពីប្រភេទជីដែលប្រើប្រាស់ក្នុងផលិតកម្មបន្លែសុវត្ថិភាព

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| ជីធម្មជាតិ | ១៤ | ៧0% |
| ជីធម្មជាតិនិងជីគីមី | ៦ | ៣0% |
| សរុប | ២០ | ១00% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញអំពីចំនួនគ្រួសារកសិករដែលបានប្រើប្រាស់ជីក្នុងការដាំដុះបន្លែសុវត្ថិភាពនៅឃុំស្វាយប្រទាល គ្រួសារដែលប្រើប្រាស់ជីធម្មជាតិសម្រាប់ការដាំដុះមានចំនួន១៤គ្រួសារ ស្មើនឹង៧០%និងចំនួនគ្រួសារកសិករដែលបានប្រើប្រាស់ជីធម្មជាតិរួមផ្សំនិងជីគីមីមានចំនួន៦គ្រួសារ ស្មើនឹង ៣0% ។

### ៣.៥.៧. បញ្ហាប្រឈម

កសិករនៅឃុំស្វាយប្រទាលតែងតែជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការដាំដុះបន្លែសុវត្ថិភាព។

តារាងទី៣.១៥៖ ការបង្ហាញអំពីបញ្ហាប្រឈមក្នុងការដាំដុះបន្លែសុវត្ថិភាព

| បរិយាយ | ចំនួនគ្រួសារ | គិតជាភាគរយ |
|---|---|---|
| អាកាសធាតុ | ៩ | ៤៥% |
| ពូជដំណាំ | ២ | ១0% |
| ជម្ងឺនិងសត្វល្អិតចង្រៃ | ៩ | ៤៥% |
| សរុប | ២០ | ១00% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា បញ្ហាប្រឈមដែលផ្តល់ការលំបាកក្នុងដំណើរការផលិតកម្ម ដែលកសិករជួបប្រទះមានដូចជា បញ្ហាពូជដំណាំ បញ្ហាអាកាសធាតុ ជម្ងឺ និងសត្វល្អិតចង្រៃ។ ក្នុងនោះដែរ គ្រួសារដែលជួបប្រទះបញ្ហាពូជដំណាំមានចំនួន២គ្រួសារ ស្មើនឹង១០% គ្រួសារដែលជួបប្រទះបញ្ហាអាកាសធាតុមានចំនួន៩គ្រួសារ ស្មើនឹង៤៥% និងគ្រួសារដែលជួបប្រទះបញ្ហាជម្ងឺនិងសត្វល្អិតចង្រៃមានចំនួន ៩គ្រួសារ ស្មើនឹង៤៥%ដូចគ្នា។

**៣.៥.៨. ដំណោះស្រាយ**

តាមរយៈប្រសាសន៍របស់កសិករ ពួកគាត់បានឱ្យដឹងថា នៅពេលដែលមានបញ្ហា ជម្ងឺនិងសត្វល្អិតចង្រៃរាតត្បាត ពួកគាត់បានប្រើប្រាស់ថ្នាំសម្រាប់សម្លាប់ល្អិត ដោយជាទូទៅប្រើរយៈពេល៧ទៅ១០ថ្ងៃបាញ់ម្តង និង បញ្ឈប់ការបាញ់ថ្នាំរយៈពេល១០ថ្ងៃមុនប្រមូលផល។ ម្យ៉ាងវិញទៀត នៅពេលដែលអាកាសធាតុប្រែប្រួលមានភ្លៀងធ្លាក់ជោគជាំ ពួកគាត់ប្រើកៅស៊ូដើម្បីការពារទឹកភ្លៀងកុំឱ្យជោគជាំលើបន្លែខ្លាំងពេក រីឯនៅពេលដែលអាកាសធាតុក្តៅខ្លាំង ពួកគាត់បានប្រើប្រាស់ស្បៃដើម្បីការពារកម្តៅថ្ងៃ ដើម្បីការពារបន្លែកុំឱ្យស្វិតស្រពោន។

**៣.៥.៩. កត្តាដែលធ្វើឱ្យទិន្នផលមានការកើនឡើង**

មានកត្តាផ្សេងៗជាច្រើនដែលជួយជម្រុញឱ្យទិន្នផលបន្លែសុវត្ថិភាពមានការកើនឡើង។ក្នុងនោះ អាកាសធាតុគឺជាផ្នែកមួយដែលសំខាន់ដែលជួយជម្រុញឱ្យទិន្នផលកើនឡើង កាលណាអាកាសធាតុមិនក្តៅពេក មិនមានភ្លៀងធ្លាក់ច្រើនពេក ធ្វើឱ្យបន្លែលូតលាស់បានល្អ និងមិនសូវមានជម្ងឺ។ ពិសេសជាងនេះទៅទៀត បច្ចេកទេសក្នុងការដាំដុះ បានជម្រុញឱ្យទិន្នផលកើនឡើងទ្វេដង។

តារាងទី៣.១៦៖ ការបង្ហាញអំពីកត្តាដែលធ្វើឱ្យទិន្នផលមានការកើនឡើង

| បរិយាយ | ករណី | គិតជាភាគរយ(%) |
|---|---|---|
| អាកាសធាតុ | ២ | ១០% |
| បច្ចេកទេស | ១៨ | ៩០% |
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញឱ្យឃើញថាកត្តាអាកាសធាតុដែលធ្វើឱ្យទិន្នផលមានការកើនឡើង មានចំនួន២ករណី ស្មើនឹង១០% និងកត្តាបច្ចេកទេសដាំដុះមានចំនួន១៨ករណី ស្មើនឹង៩០%។

**៣.៥.១០. រយៈពេលដាំដុះ**

តាមរយៈការសម្ភាសផ្ទាល់ជាមួយនឹងកសិករ ពួកគាត់បានឱ្យដឹងថាបន្លែនីមួយៗមានរយៈពេលដាំដុះខុសៗគ្នារហូតដល់ការប្រមូលផល ដែលបានបង្ហាញឱ្យឃើញដូចខាងក្រោម៖

- ស្ពៃក្រញាញ់ ស្ពៃចង្កឹះ ស្ពៃតឿ និងស្ពៃខ្មៅ រយៈពេល ២៨ ទៅ ៣៥ថ្ងៃ គឺអាចប្រមូលផលបាន
- ស្ពៃក្ដោប រយៈពេលថេរ ៣ខែ ទើបអាចប្រមូលផលបាន

ពួកគាត់បានបន្ថែមទៀតថា បើសិនជាដីមានជីវជាតិល្អ ការប្រមូលផលអាចនឹងបានធ្វើមុនរយៈពេលកំណត់ តែបើមិនសូវល្អទេអាចនឹងយូរជាង២ថ្ងៃ ទៅ៣ថ្ងៃ។

**៣.៥.១១. ការលក់ចេញនូវទិន្នផលដែលទទួលបាន**

តាមរយៈការសម្ភាសផ្ទាល់ជាមួយនឹងកសិករ ពួកគាត់បានឱ្យដឹងថា នៅក្រោយពេលប្រមូលផលទិន្នផលដែលទទួលបាន គឺខាងភ្នាក់ងារកសិកម្មបានចុះទៅទិញផ្ទាល់ដល់ចម្ការតែម្តង ដោយមិនចាំបាច់ខាតពេលវេលា និងថវិកាសម្រាប់ការធ្វើដំណើរយកទៅលក់នៅទីផ្សារឡើយ ដែលបង្កជាភាពងាយស្រួលដល់ពួកគាត់ដែលបានដាំដុះបន្លែសុវត្ថិភាព។

## ៣.៦. ការវិភាគប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំបន្លែសុវត្ថិភាព

**៣.៦.១. ចំណាយសរុបជាមធ្យមទៅលើការដាំដុះបន្លែសុវត្ថិភាព**

តារាងខាងក្រោមនេះ នឹងបង្ហាញអំពីចំណាយសរុបជាមធ្យមទៅលើការដាំដុះបន្លែសុវត្ថិភាពរបស់កសិករនៅក្នុងឃុំស្វាយប្រទាល ដែលគិតក្នុង១វដ្តផលិតកម្ម បូកបញ្ចូលទាំងចលនទុន និងអចលនទុន។

តារាងទី៣.១៧៖ ការបង្ហាញអំពីចំណាយសរុបជាមធ្យមរបស់កសិករទៅលើការដាំបន្លែសុវត្ថិភាព

| បរិយាយ | ចំណាយសរុបជាមធ្យម | កំហុសនៃការវាយតម្លៃចំណាយជាមធ្យម | គម្លាតគំរូ |
|---|---|---|---|
| ចំណាយសរុបគិតក្នុង១វដ្តផលិតកម្ម(រៀល) | ១,៩១២,៥០០ រៀល | ២៥៧,១០៦.២៤០រៀល | ១,១៤៩,៨១៤.០៥៨ រៀល |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា ការចំណាយសរុបជាមធ្យមរបស់កសិករដែលដាំបន្លែនៅក្នុងឃុំស្វាយប្រទាល ស្មើនឹង ១,៩១២,៥០០ រៀល ក្នុង១វដ្តផលិតកម្ម ហើយគម្លាតគំរូឬចំណាយជាមធ្យមដែលបានរំពឹងទុករបស់គ្រួសារនីមួយៗទាំង២០គ្រួសារក្នុង១វដ្តផលិតកម្មស្មើនឹង១,១៤៩,៨១៤.០៥៨រៀល និងកំហុសនៃការវាយតម្លៃលើចំណាយជាមធ្យមរបស់គ្រួសារនីមួយៗ ក្នុង១វដ្តផលិតកម្មស្មើនឹង ២៥៧,១០៦.២៤០ រៀល។

### ៣.៦.២. ចំណូលជាមធ្យមនៅពីការដាំបន្លែបន្លែសុវត្ថិភាព

ចំណូល គឺពិតជាជាមានសារៈសំខាន់ណាស់ក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាកសិករនៅក្នុងឃុំស្វាយប្រទាល ហើយក៏ជាកម្លាំងចិត្តក្នុងការប្រកបរបរដាំបន្លែសុវត្ថិភាពតទៅទៀត។ សម្រាប់គ្រួសារកសិករដែលដាំដុះបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ចំណូលសរុបជាមធ្យមក្នុង១ វដ្តផលិតកម្ម ស្មើនឹងផលគុណនៃប្រមាណទិន្នផលក្នុង១វដ្តផលិតកម្ម និង ថ្លៃជាមធ្យមក្នុង១ឯកតា។ តាមការចុះទៅដល់មូលដ្ឋានយើងសង្កេតឃើញថា ចំណូលរបស់គ្រួសារនីមួយៗ មានភាពខុសផ្លែកគ្នា អាស្រ័យទៅតាម ទំហំផ្ទៃដីដាំដុះ បច្ចេកទេសដាំដុះ គុណភាពបន្លែ និងបរិមាណទិន្នផលដែលទទួលបាន។

តារាងទី៣.១៨៖ ការបង្ហាញអំពីចំណូលជាមធ្យមក្នុង១វដ្តផលិតកម្មដំណាំបន្លែសុវត្ថិភាពរបស់កសិករ

| បរិមាណទិន្នផលដែលទទួលបានជាមធ្យមក្នុង១វដ្តផលិតកម្ម | ថ្លៃជាមធ្យមក្នុងមួយគីឡូក្រាម | ចំណូលសរុបជាមធ្យមក្នុង១វដ្តផលិតកម្ម |
|---|---|---|
| ២,១៨២ គីឡូក្រាម | ២,០២៧ រៀល | ៤,៤២៥,០០០ រៀល |

ប្រភព៖ ទិន្នន័យឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញថា បរិមាណបន្លែសុវត្ថិភាពរបស់កសិករនៅក្នុងឃុំស្វាយប្រទាលជាមធ្យមទទួលបាន ២,១៨២ គីឡូក្រាម ឯថ្លៃជាមធ្យមក្នុងមួយគីឡូក្រាមទទួលបាន ២,០២៧ រៀល។ ដូច្នេះ ចំណូលសរុបជាមធ្យមរបស់កសិករដែលដាំបន្លែសុវត្ថិភាពទទួលបានគឺ ៤,៤២៥,០០០ រៀល គិតក្នុង១វដ្តផលិតកម្ម។

### ៣.៦.៣. ប្រាក់ចំណេញ ឬខាតជាមធ្យមក្នុងការដាំដុះបន្លែសុវត្ថិភាព

ប្រាក់ចំណេញជាមធ្យមក្នុង១វដ្តផលិតកម្ម ដែលទទួលបានពីការដាំបន្លែសុវត្ថិភាពរបស់កសិករនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល គឺជាផលដករវាង ចំណូលសរុបជាមធ្យមគិតក្នុង១វដ្តផលិតកម្ម និង ចំណាយសរុបជាមធ្យមគិតក្នុង១វដ្តផលិតកម្ម។

តារាងទី៣.១៩៖ ការបង្ហាញអំពីចំណេញសរុបជាមធ្យមគិតក្នុង១វដ្តផលិតកម្មរបស់កសិករដាំបន្លែសុវត្ថិភាព

| ចំណូលជាមធ្យមក្នុង១វដ្តផលិតកម្ម | ចំណាយជាមធ្យមក្នុង១វដ្តផលិតកម្ម | ចំណេញឬខាតសរុបជាមធ្យមក្នុង១វដ្តផលិតកម្ម |
|---|---|---|
| ៤,៤២៥,០០០ រៀល | ១,៩១២,៥០០ រៀល | ២,៥១២,៥០០ រៀល |

ប្រភព៖ ទិន្នន័យឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបញ្ជាក់ថា ក្នុង១វដ្តផលិតកម្ម កសិករដែលដាំបន្លែសុវត្ថិភាពអាចចំណេញសរុបជាមធ្យមបាន ២,៥១២,៥០០ រៀល ។

តាមរយៈការសម្ភាសជាមួយកសិករដែលដាំបន្លែសុវត្ថិភាព ពួកគាត់បានប្រាប់ថាពួកគាត់អាចដាំដុះចំនួន៧ដង ក្នុង១ ឆ្នាំ ដូចនេះប្រាក់ចំណេញសរុបជាមធ្យមក្នុង១ឆ្នាំ ស្មើនឹង ចំណេញសរុបជាមធ្យមក្នុង ១ វដ្តផលិតកម្ម គុណនឹង ៧ដង។

យើងបាន៖ ប្រាក់ចំណេញសរុបជាមធ្យមក្នុង១ឆ្នាំ = ២,៥១២,៥០០ រៀល × ៧

= ១៧,៥៨៧,៥០០ រៀល

ដូចនេះ ប្រជាកសិករនៅក្នុងឃុំស្វាយប្រទាល ដែលដាំដុះបន្លែសុវត្ថិភាព អាចទទួលបានប្រាក់ចំណេញសរុបជាមធ្យមក្នុង១វដ្តផលិតកម្មស្មើនឹង ២,៥១២,៥០០ រៀល និងអាចទទួលបានប្រាក់ចំណេញសរុបជាមធ្យមក្នុង១ឆ្នាំ ស្មើនឹង ១៧,៥៨៧,៥០០ រៀល សម្រាប់ចំណាយលើការផ្គត់ផ្គង់ជីវភាពគ្រួសារ។

### ៣.៦.៤. ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការដាំដុះបន្លែសុវត្ថិភាព

#### ៣.៦.៤.១.ប្រសិទ្ធភាពក្នុងមួយឯកតាទុនផលិតកម្ម

ប្រសិទ្ធភាពក្នុង១ឯកតាទុនផលិតកម្ម បង្ហាញថា កសិករនៅក្នុងឃុំស្វាយប្រទាលចំណាយដើមទុន ១រៀល ទៅក្នុងផលិតកម្ម ហើយទទួលបានចំណូលមកវិញប៉ុន្មានរៀល និងចំណេញរឺក៏ខាតប៉ុន្មានរៀល?

$$\text{ប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬក្នុងមួយវដ្តផលិតកម្ម}}{\text{ចំណាយសរុបប្រចាំឆ្នាំ ឬក្នុងមួយវដ្តផលិតកម្ម}}$$

ដោយ ចំណូលសរុបក្នុង១វដ្តផលិតកម្ម ស្មើនឹង ៤,៤២៥,០០០ រៀល

ឯចំណាយសរុបក្នុង១វដ្តផលិតកម្ម ស្មើនឹង ១,៩១២,៥០០ រៀល

$$\text{នាំឱ្យប្រសិទ្ធភាពមួយឯកតាទុនផលិតកម្ម} = \frac{\text{៤,៤២៥,០០០ រៀល}}{\text{១,៩១២,៥០០ រៀល}} = \text{២.៣១ រៀល}$$

តាមរយៈលទ្ធផលបានបង្ហាញឱ្យឃើញថា នៅពេលដែលកសិករគាត់ចំណាយដើមទុន ១រៀលចូលក្នុងផលិតកម្ម គាត់ទទួលបានចំណូលមកវិញ ២.៣១ រៀល ដកនឹង ១រៀលដែលគាត់បានចំណាយ ស្មើនឹង ១.៣១ រៀល។ ដូចនេះយើងសង្កេតឃើញថា ការដាំដុះបន្លែសុវត្ថិភាពរបស់ប្រជាកសិករមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ព្រោះគាត់ចំណេញលើសដើមទុនផលិតកម្ម ១.៣១ រៀល ដែលប្រើរយៈពេលខ្លីប៉ុណ្ណោះក្នុងការដាំដុះរបស់ពួក គាត់។

#### ៣.៦.៤.២. ប្រសិទ្ធភាពកម្លាំងពលកម្ម

តាមរយៈការចុះមូលដ្ឋានផ្ទាល់ បានបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពកម្លាំងពលកម្ម ដែលអាចឱ្យយើងដឹងថា តើក្នុងកម្លាំងពលកម្មម្នាក់ អាចទទួលបានប្រាក់ចំណូលមកវិញចំនួនប៉ុន្មានរៀល?

$$\text{ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{បរិមាណកសិផលក្នុង១ឯកតា} \times \text{ថ្លៃកសិផលក្នុងមួយឯកតា}}{\text{កម្លាំងពលកម្មសរុប}}$$

ដោយ បរិមាណកសិផលក្នុង១ឯកតា × ថ្លៃកសិផលក្នុងមួយឯកតា = ៤,៤២៥,០០០ រៀល

កម្លាំងពលកម្មសរុបជាមធ្យម ស្មើនឹង ៣.៤ ≈ ៣នាក់

$$\text{យើងបាន ប្រសិទ្ធភាពកម្លាំងពលកម្ម} = \frac{\text{៤,៤២៥,០០០ រៀល}}{\text{៣នាក់}} = \text{១,៤៧៥,០០០ រៀល}$$

ដូចនេះ កម្លាំងពលកម្ម ១នាក់ ក្នុងគ្រួសារដែលបានចូលរួមក្នុងផលិតកម្មបន្លែសុវត្ថិភាព អាចទទួលបានប្រាក់ចំណូលមកវិញចំនួន ១,៤៧៥,០០០ រៀល ក្នុង១វដ្តផលិតកម្ម។ ម្យ៉ាងវិញទៀត១ឆ្នាំគាត់អាចដាំដុះបាន៧ដង នោះចំណូលក្នុង១ឆ្នាំ របស់កម្លាំងពលកម្មម្នាក់ស្មើនឹង ១០,៣២៥,០០០ រៀល។

**៣.៦.៤.៣. ប្រសិទ្ធភាពដីធ្លី**

តាមរយៈការចុះអង្កេតស្រាវជ្រាវដល់មូលដ្ឋាន ឃុំស្វាយប្រទាលផ្ទាល់ បានបង្ហាញអំពីប្រសិទ្ធភាពនៃដីកសិកម្មដូចខាងក្រោម៖

$$\text{ប្រសិទ្ធភាពដីធ្លីកសិកម្ម} = \frac{\text{ចំណូលសរុបប្រចាំឆ្នាំ ឬមួយវដ្តផលិតកម្ម}}{\text{ផ្ទៃដីសរុបជាមធ្យម}}$$

ដោយចំណូលសរុបជាមធ្យមក្នុង១វដ្តផលិតកម្ម ស្មើនឹង ៤,៤២៥,០០០ រៀល

និងផ្ទៃដីសរុបជាមធ្យមស្មើនឹង ៦,១៩៥ ម$^{២}$

$$\text{យើងបាន ប្រសិទ្ធភាពដីធ្លីកសិកម្ម} = \frac{\text{៤,៤២៥,០០០ រៀល}}{\text{៦,១៩៥ ម}^{២}} = \text{៤១៤.២៨ រៀលក្នុង១ម}^{២}$$

ដូចនេះក្នុងដី១ម៉ែត្រការ៉េ កសិករអាចរកចំណូលពីការដាំបន្លែសុវត្ថិភាពបានចំនួន ៤១៤.២៨ រៀល។

**៣.៦.៥. ការវិភាគចំណុចស្រង់ដើម**

ចំណុចស្រង់ដើម ជាចំណុចដែលរួចខ្លួន មានន័យថាចំណូល និងចំណាយមានចំនួនស្មើគ្នា។ ការវិភាគទៅលើចំណុចស្រង់ដើមអាចឱ្យយើងដឹងកម្រិតថ្លៃ និងបរិមាណដែលធ្វើឱ្យកសិករចំណេញឬក៏ខាត។នៅពេលដែលយើងដឹងពីចំណុចស្រង់ដើម អាចធ្វើឱ្យយើងបង្កើនផលិតភាពដើម្បីបានចំណេញ។

$$\text{ចំណុចស្រង់ដើម} = \frac{\text{ចំណាយសរុបជាមធ្យមក្នុងវដ្តផលិតកម្ម}}{\text{បរិមាណកសិផលជាមធ្យមក្នុងមួយវដ្តផលិតកម្ម}}$$

ដោយ ចំណាយជាមធ្យមក្នុង១វដ្តផលិតកម្មស្មើនឹង ១,៩១២,៥០០ រៀល

បរិមាណកសិផលក្នុងជាមធ្យមក្នុង១វដ្តផលិកម្មស្មើនឹង ២,១៨២ គីឡូក្រាម

$$\text{យើងបានចំណុចស្រង់ដើម} = \frac{\text{១,៩១២,៥០០ រៀល}}{\text{២,១៨២ គីឡូក្រាម}} = \text{៨៧៦.៥០ រៀល/ គ.ក}$$

ដូចនេះចំណុចស្រង់ដើមរបស់ផលិតកម្មបន្លែសុវត្ថិភាពរបស់កសិករក្នុងឃុំស្វាយប្រទាលគឺ ត្រង់ថ្លៃ ៨៧៦.៥០ រៀល ក្នុងបរិមាណទិន្នផល ២,១៨២ គីឡូក្រាម។ មានន័យថាបើគាត់លក់បានក្នុងក្រោមតម្លៃ ៨៧៦.៥០ រៀល ក្នុងបរិមាណទិន្នផល ២,១៨២គីឡូក្រាម ពួកគាត់នឹងខាត។ តែគាត់បើគាត់លក់បានត្រង់ថ្លៃ ៨៧៦.៥០ រៀលដដែល តែក្នុងបរិមាណទិន្នផលលើសពី ២,១៨២គីឡូក្រាម ពួកគាត់នឹងចំណេញ។បើលក់បានថ្លៃលើសពី ៨៧៦.៥០រៀល ក្នុងបរិមាណលើសពី ២,១៨២គីឡូក្រាមទៀត ពួកគាត់នឹងរិតតែចំណេញ។ តាមការសម្ភាសផ្ទាល់ជាមួយកសិករម្នាក់ដែលស្ថិតក្នុងសហគមន៍ដាំបន្លែសុវត្ថិភាពបានឱ្យដឹងថាថ្លៃជាមធ្យមដែលគាត់លក់បានក្នុង១វដ្តផលិតកម្មគឺ ២០០០រៀល ដូច្នេះអាចសន្និដ្ឋានបានថា កសិករពិតជាទទួលបានប្រាក់ចំណេញពីការដាំបន្លែសុវត្ថិភាពនេះជាពុំខានឡើយ។

## ៣.៧. មូលហេតុនៃការដាំដុះបន្លែសុវត្ថិភាព

តាមរយៈការសម្ភាសផ្ទាល់ជាមួយកសិករដែលដាំបន្លែសុវត្ថិភាពនៅក្នុងឃុំស្វាយប្រទាលបានឱ្យដឹងថាមូលហេតុដែលពួកគាត់ដាំដុះបន្លែសុវត្ថិភាពនេះគឺ៖

- ហានិភ័យនៃការប៉ះពាល់ដល់សុខភាពតិចជាងការដាំបន្លែគីមី
- មានការធានាទីផ្សារជាក់លាក់ក្នុងការដាំដុះ
- ពួកគាត់មានជំនាញក្នុងការដាំដុះស្រាប់
- អាចធ្វើការនៅផ្ទះ ជួបជុំជាមួយគ្រួសារ
- ចំណាយទុនតិចទៅលើការដាំដុះ និងទទួលប្រាក់ចំណេញមកវិញបានច្រើន
- ដើម្បីសុខភាពគ្រួសារ កូនចៅជំនាន់ក្រោយ និងបរិស្ថានល្អ។

## ៣.៨. ការប្រៀបធៀបទិន្នផល និងជីវភាពកសិករក្រោយពីការដាំបន្លែសុវត្ថិភាព

តាមរយៈការសាកសួរជាមួយកសិករនៅក្នុងឃុំស្វាយប្រទាល ពួកគាត់បានឱ្យដឹងថាក្រោយពីការអនុវត្តការដាំដុះបន្លែសុវត្ថិភាព ទិន្នផលដែលពួកគាត់ទទួលបានមានចំនួនច្រើនជាងមុនព្រមទាំងចំណាយដើមទុនតិចក្នុងដំណើរការផលិតកម្ម ធ្វើឱ្យពួកគាត់ទទួលបានចំណូលច្រើនជាងមុន បានការលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់ឱ្យកាន់តែប្រសើរជាងមុន។

តារាងទី៣.២០៖ ការបង្ហាញអំពីជីវភាពគ្រួសាររបស់កសិករ

| បរិយាយ | គ្រួសារ | គិតជាភាគរយ(%) |
|---|---|---|
| ប្រសើរឡើង | ២០ | ១០០% |
| នៅថេរ | 0 | 0% |
| ធ្លាក់ចុះ | 0 | 0% |

| | | |
|---|---|---|
| សរុប | ២០ | ១០០% |

ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០២០

តាមរយៈតារាងខាងលើបានបង្ហាញឱ្យឃើញថា នៅក្នុងឃុំស្វាយប្រទាលកសិករដែលដាំដុះបន្លែសុវត្ថិភាព គ្រួសារទាំង២០ ដែលស្មើនឹង១០០% សុទ្ធតែមានជីវភាពប្រសើរឡើង មិនមានការធ្លាក់ចុះឬក៏នៅថេរឡើយ។ ដូច្នេះការដាំដុះបន្លែសុវត្ថិភាពពិតជាបានជួយលើកកម្ពស់ជីវភាពគ្រួសាររបស់ប្រជាកសិករយ៉ាងពិតប្រាកដមែន។

## ៣.៩. ការវិភាគ SWOT នៃដំណាំបន្លែសុវត្ថិភាព

ការវិភាគ SWOT គឺជាវិធីសាស្ត្រមួយដ៏មានសារៈសំខាន់ក្នុងការវិភាគលទ្ធផលស្រាវជ្រាវ ដែល ឱ្យយើងដឹងអំពី ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងនានា ចំពោះប្រធានបទដែលត្រូវលើកយកមកសិក្សា។ ជាក់ស្តែង ការដាំបន្លែសុវត្ថិភាពជាសហគមន៍របស់កសិករនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ត្រូវបានលើកយកមកវិភាគ SWOT។ តាមរយៈការចុះសម្ភាស៍ផ្ទាល់ជាមួយក្រុមកសិករ និងដំណើរការផលិតកម្មដាំបន្លែសុវត្ថិភាពបានបង្ហាញឱ្យឃើញអំពី ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងដូចខាងក្រោម៖

- **ភាពខ្លាំង**
  - ដីកសិកម្មរបស់កសិករ ជាតំបន់ដែលអំណោយផលពីធម្មជាតិ ទាំងប្រភពទឹកក៏មានគ្រប់គ្រាន់ ឯដីក៏មានជីជាតិ
  - ដីសម្រាប់ធ្វើកសិកម្ម គឺជាកម្មសិទ្ធិផ្ទាល់ខ្លួន មិនចាំបាច់ជួលគេធ្វើឱ្យអស់ចំណាយច្រើនទៅលើដំណើរកសិកម្ម
  - មានការបង្រៀនពីបច្ចេកទេសដាំដុះ តាមរយៈភ្នាក់ងារកសិកម្ម
  - ចំពោះគ្រាប់ពូជដំណាំ សម្ភារហូរហៀរ មានលក់នៅលើទីផ្សារគ្រប់គ្រាន់ និងធូរថ្លៃ
  - កសិករសឹងតែទាំងអស់ សុទ្ធសឹងតែមានដើមទុនដោយខ្លួនឯង ក្នុងការប្រកបរបរដាំដុះដើម្បីជីវភាពគ្រួសារ មិនមានការខ្ចីពីបងប្អូន រឺក៏កម្ចីឥណទានអ្វីឡើយ
  - កសិករអាចមានបន្លែសម្រាប់ហូបខ្លួនឯង ដែលធ្វើឱ្យចំណាយប្រចាំថ្ងៃទាប
  - មានការចុងកុងត្រាជាមួយភ្នាក់ងារទីផ្សារមុនការដាំដុះ
  - បន្លែលក់ចេញទទួលបានតម្លៃថ្លៃជាងបន្លែគីមី
  - បន្លែសុវត្ថិភាព ជួយដល់សុខភាព ទាំងអ្នកដាំ និងអ្នកប្រើប្រាស់ចុងក្រោយផងដែរ
  - ធ្វើឱ្យជីវភាពរបស់ពួកគាត់ប្រសើរជាងមុន បើធៀបនឹងការដាំបន្លែគីមី។

❖ **ភាពខ្សោយ**

- កសិករមិនអាចដាំដំណាំតាមតែចិត្តឯងបានឡើយ ដោយសារតែមានការចុះកុងត្រាជាមួយក្រុមហ៊ុន
- កសិករមិនអាច លក់ចេញទៅកាន់ទីផ្សារដោយខ្លួនឯងបានឡើយ
- ទិន្នផលដែលទទួលបានជួនកាលអាចលើសពីបរិមាណដែលបានចុះកុងត្រារួច ជួនកាលអាចខ្វះផងដែរ
- រដ្ឋាភិបាល និងប្រជាជនមិនសូវយកចិត្តទុកដាក់ច្រើន ជាហេតុនាំឱ្យមិនសូវមានកសិករដាំដុះច្រើន។

❖ **ឱកាស ឬកាលានុវត្តភាព**

- កសិករអាចដាំដុះបន្លែសុវត្ថិភាពនេះបានគ្រប់រដូវ ទាំងប្រាំងនិងវស្សា ហើយអាចដាំដុះបានច្រើនដងក្នុងមួយឆ្នាំ
- មានការចុះបង្រៀនពីបច្ចេកទេសដាំដុះដល់សហគមន៍កសិកម្មតែម្តង
- ការប្រើប្រាស់ដី និងកម្លាំងពលកម្មអស់ពីសមត្ថភាព មិនទុកឱ្យទំនេរចោល
- ចំពោះផ្នែកទីផ្សារ កសិករមានភាពងាយស្រួលនិងទុកចិត្ត ព្រោះមានកុងត្រាតម្លៃមុនការដាំដុះ ជាហេតុធ្វើឱ្យមានហានិភ័យទាប
- មានផ្លូវគមនាគមន៍ខ្វាត់ខ្វែងល្អ ទាំងផ្លូវទឹក និងផ្លូវគោកដែលមានទាំងការចាក់បេតុងនិងកៅស៊ូ ផ្តល់ភាពងាយស្រួលក្នុងការដឹកជញ្ជូនយកទៅកាន់ទីផ្សារ
- ខេត្តកណ្តាលត្រូវបានចាត់ទុកជាខេត្តមួយ ដែលមានផ្ទៃដីដាំដុះបន្លែសុវត្ថិភាពច្រើន និងការផ្គត់ផ្គង់បន្លែនៅលើទីផ្សារច្រើន
- ប្រជាកសិករដែលដាំបន្លែនានានៅក្នុងឃុំស្វាយប្រទាលដែលកំពុងតែដាំបន្លែគីមី កំពុងតែបំណងងាកមករកការដាំបន្លែសុវត្ថិភាពវិញផងដែរ
- មានការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនានា ដូចជា ហ្វេសប៊ុក តាមគេហទំព័រមួយចំនួន និងតាមរយៈទូរទស្សន៍។ល។

❖ **ការគំរាមកំហែងនានា**

- រដូវវស្សាជារដូវមួយ ដែលធ្វើឱ្យទិន្នផលមានការថយចុះ ជាងទិន្នផលនៅរដូវប្រាំង
- កាលណាដែលភ្លៀងច្រើនបណ្តាលឱ្យមានការលិចទឹក បណ្តាលឱ្យការធ្វើកសិកម្មបានតិចដងក្នុងមួយឆ្នាំ
- ការបំផ្លិចបំផ្លាញពីសំណាក់ក្រុមសត្វល្អិតចង្រៃ ក៏ដូចជាអាកាសធាតុ ព្រោះការដាំបន្លែសុវត្ថិភាពតម្រូវឱ្យមានការប្រើប្រាស់ថ្នាំគីមីតិចមែនទែន

- ការដាំបន្លែគីមីនៅមានចំនួនច្រើននៅឡើយ ជាហេតុនាំឱ្យមានឧបសគ្គដល់ការដាំបន្លែសុវត្ថិភាព
- ការនាំចូលបន្លែពីក្រៅស្រុកគឺជាបញ្ហាចម្បង ព្រោះធ្វើឱ្យការដាំបន្លែក្នុងស្រុកធ្លាក់ចុះ និងតម្លៃបន្លែសុវត្ថិភាពរបស់កសិរនៅក្នុងឃុំស្វាយប្រទាលក៏ដូចជា កសិករដទៃមានការធ្លាក់ចុះផងដែរ
- ការនិយមទទួលទានបន្លែគីមី ធ្វើឱ្យការដាំបន្លែសុវត្ថិភាព មិនសូវស្ទុះឡើងខ្លាំង។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

យោងទៅតាមការស្រាវជ្រាវ ការអង្កេត និងវិភាគលទ្ធផលស្រាវជ្រាវ ដែលទទួលបានពីការដាំដុះបន្លែសុវត្ថិភាពរបស់ប្រជាកសិករនៅក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល យើងអាចធ្វើការសន្និដ្ឋានបានថា ពួកគាត់ពិតជាទទួលបានចំណូលច្រើនមែន ហើយអាចលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់បានល្អប្រសើរថែមទៀត ដោយស្ដែងចេញតាមរយៈ លំនៅដ្ឋានរបស់ពួកគាត់មានភាពធំល្មម អាចរបស់បានយ៉ាងប្រសើរ។ កត្តាដែលធ្វើឱ្យការដាំដុះបន្លែសុវត្ថិភាពរបស់ពួកគាត់បានជោគជ័យ និងទទួលបានប្រាក់ចំណូលច្រើនគឺ ដំណាំបន្លែត្រូវការតែរយៈពេលខ្លីប៉ុណ្ណោះដើម្បីឈានដល់ការប្រមូលផល ហើយគាត់អាចដាំដុះបានច្រើនដងរហូតដល់ ៧ដងក្នុង១ឆ្នាំ តំបន់ភូមិសាស្រ្តដាំដុះ មានលក្ខណៈអំណោយផលពីធម្មជាតិ មានប្រភពទឹកគ្រប់គ្រាន់ មានផ្លូវគមនាគមន៍ខ្វាត់ខ្វែង ឯចំណាយក្នុងការដាំដុះតិច ពោលគឺតិចជាការដាំបន្លែគីមីដែលគាត់ធ្លាប់ធ្វើកន្លងមក ហើយចំណូលក៏បានច្រើនជាងដែរ ព្រោះតម្លៃទទួលបានខ្ពស់ជាង។

ដំណាំបន្លែសុវត្ថិភាព កសិករអាចដាំបានគ្រប់រដូវទាំងប្រាំង និងវស្សា ព្រោះកសិករមានប្រភពទឹកគ្រប់គ្រាន់សម្រាប់ការដាំដុះដូចជា ទន្លេ និងអណ្ដូង។ នៅរដូវប្រាំង ពួកគាត់ប្រើប្រាស់ទឹកអណ្ដូងដែលពួកគាត់ជីកនៅក្បែរផ្ទះរបស់គាត់ ដែលបង្កភាពងាយស្រួល។ ចំណែកឯដើមទុន ដែលចំណាយក្នុងការដាំដុះបន្លែសុវត្ថិភាព សុទ្ធសឹងតែជារបស់ខ្លួនឯង មិនមានការខ្ចីពីបងប្អូន ឬឥណទានណាមួយឡើយ។ បន្ទាប់ពីប្រមូលផលពួកគាត់មានភាពងាយស្រួល ព្រោះមានភ្នាក់ងារទីផ្សារ ចុះទៅទិញដល់កន្លែង ដែលមានការចុះកុងត្រាថ្លៃ និងបរិមាណរួចរាល់អស់ហើយ ។ ចំណែកឯបច្ចេកទេសដាំដុះវិញ គឺមានការចុះបង្រៀនដោយផ្ទាល់ពីសំណាក់ភ្នាក់ងារកសិកម្ម ធ្វើឲ្យពួកគាត់មានបទពិសោធន៍កាន់តែច្រើនបូករួមជាមួយនឹងបច្ចេកទេសដាំដុះរបស់គាត់ពីបុរាណ មក។ រីឯកម្លាំងពលកម្មជាមធ្យមក្នុងគ្រួសារ មានចំនួន៣នាក់ផងដែរ។

តាមរយៈលទ្ធផលនៃការវិភាគសេដ្ឋកិច្ចបានបង្ហាញឲ្យឃើញថា ចំណាយសរុបជាមធ្យមរបស់កសិករក្នុង១វដ្តផលិតកម្មស្មើនឹង ១,៩១២,៥០០ រៀល ដោយទទួលបានចំណូលសរុបជាមធ្យមក្នុង១វដ្តផលិតកម្មត្រឡប់មកវិញស្មើនឹង ៤,៤២៥,000 រៀល ។ តាមផលដក បានបង្ហាញឲ្យឃើញថាប្រាក់ចំណេញសរុបជាមធ្យមក្នុង១វដ្តផលិតកម្មស្មើនឹង ២,៥១២,៥០០ រៀល សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ នៅពេលដែលកសិករគាត់ចំណាយដើមទុន ១រៀលចូលក្នុងផលិតកម្ម គាត់ទទួលបានចំណូលមកវិញ ២.៣១ រៀល ដកនឹង ១រៀលដែលគាត់បានចំណាយ ស្មើនឹង ១.៣១ រៀល។ ដូចនេះ ការដាំដុះបន្លែសុវត្ថិភាពរបស់ប្រជាកសិករមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ព្រោះគាត់ចំណេញលើសដើមទុនផលិតកម្ម ១.៣១ រៀល ដែលប្រើរយៈពេលខ្លីប៉ុណ្ណោះក្នុងការដាំដុះរបស់ពួកគាត់។ លើសពីនេះទៅទៀត កម្លាំងពលកម្ម ១នាក់ ក្នុងគ្រួសារ

ដែលបានចូលរួមក្នុងផលិតកម្មបន្លែសុវត្ថិភាព អាចទទួលបានប្រាក់ចំណូលមកវិញចំនួន ១,៤៧៥,០០០ រៀល ក្នុង ១វដ្តផលិតកម្ម និងចំណូលក្នុង១ឆ្នាំ របស់កម្លាំងពលកម្មម្នាក់ស្មើនឹង ១០,៣២៥,០០០ រៀល។ ឯក្នុងដី១ម៉ែត្រការ៉េ កសិករអាចរកចំណូលពីការដាំបន្លែសុវត្ថិភាពបានចំនួន ៤១៤.២៨ រៀល។ ចំណែកឯចំណុចស្រង់ដើមរបស់ផលិតកម្មបន្លែសុវត្ថិភាពរបស់កសិករក្នុងឃុំស្វាយប្រទាលគឺ ត្រង់ថ្លៃ ៨៧៦.៥០ រៀល/គ.ក ក្នុងបរិមាណ ទិន្នផល ២,១៨២ គីឡូក្រាម។ មានន័យថាបើគាត់លក់បានក្នុងក្រោមតម្លៃ ៨៧៦.៥០ រៀល/គ.ក ក្នុងបរិមាណ ទិន្ននផល ២,១៨២គីឡូក្រាម ពួកគាត់នឹងខាត។ តែគាត់បើគាត់លក់បានត្រង់ថ្លៃ ៨៧៦.៥០ រៀល/គ.ក ដដែល តែក្នុងបរិមាណទិន្នផលលើសពី ២,១៨២គីឡូក្រាម ពួកគាត់នឹងចំណេញ។ បើលក់បានថ្លៃលើសពី ៨៧៦.៥០រៀល/គ.ក ក្នុងបរិមាណលើសពី ២,១៨២គីឡូក្រាមទៀត ពួកគាត់នឹងរិតតែចំណេញ។ ដូច្នេះការដាំដុះបន្លែសុវត្ថិភាព ពិតជាបានជួយលើកកម្ពស់ជីវភាពគ្រួសារបានយ៉ាងពិតប្រាកដមែន។

## ២. អនុសាសន៍

តាមរយៈការវិភាគលទ្ធផលស្រាវជ្រាវ ការដូចជាការសម្ភាសន៍ យើងខ្ញុំមានសំណូមពរ ក៏ដូចជាមតិមួយចំនួនដូចខាងក្រោម៖

- កសិករគួរតែ ព្យាយាមបង្កើនទិន្នផល និងផ្ទៃដីដាំដុះបន្ថែមទៀត ដើម្បីរកប្រាក់ចំណេញឱ្យបានច្រើន
- កសិករដែលដាំបន្លែគីមី គួរតែងាកមករកការដាំបន្លែសុវត្ថិភាពវិញ ព្រោះល្អដល់សុខភាព ទាំងអ្នកដាំ និងអ្នកប្រើប្រាស់ចុងក្រោយ បូករួមទាំងចំណាយតិច និងចំណេញច្រើន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្មខេត្តកណ្តាល ព្រមទាំងក្រសួងពាក់ព័ន្ធនានា គួរតែចុះផ្សព្វផ្សាយបន្ថែមទៀតដើម្បីឈានដល់ការដាំដុះតែបន្លែសុវត្ថិភាពទាំងស្រុងនិងបានទូលំទូលាយ
- ក្រសួងសាធារណការ និងដឹកជញ្ជូន គួរតែសាងសង់ស្ពានបន្ថែម ដើម្បីសម្រួលដល់ការដឹកជញ្ជូនបន្លែទៅកាន់ត្រើយម្ខាង (ថ្នល់ជាតិ) និងងាយស្រួលដឹកទៅកាន់ទីផ្សារឱ្យទាន់ពេលវេលា
- ក្រសួងពាណិជ្ជកម្មគួរតែបង្កើតទីផ្សារបន្លែសុវត្ថិភាពឱ្យកាន់តែទូលាយ ដើម្បីផ្តល់ទំនុកចិត្តដល់កសិករក្នុងការដាំដុះបន្លែសុវត្ថិភាពតទៅទៀត
- រដ្ឋាភិបាលគួរតែកាត់បន្ថយការនាំចូលបន្លែ ដើម្បីជម្រុញដល់ផលិតកម្មបន្លែសុវត្ថិភាពក្នុងស្រុក។ កាលណាដែលបន្លែសុវត្ថិភាពទទួលបានតម្លៃថ្លៃ នោះប្រជាកសិករនឹងដាំដុះច្រើន ទទួលបានប្រាក់ចំណូលខ្ពស់ និងកាត់បន្ថយការចំណាកស្រុកផងដែរ ព្រោះបានបង្កើតការងារឱ្យកសិករធ្វើ

- ប្រជាជន ឬអ្នកទិញគ្រប់រូប គួរតែទិញបន្លែសុវត្ថិភាពយកទៅបរិភោគ ត្បិតថាវៀងថ្លៃបន្តិចមែន ប៉ុន្តែល្អដល់សុខភាព រស់នៅបានយូរអង្វែង ជាជាងយកលុយទៅចំណាយលើរបស់ឥតប្រយោជន៍
- ភោជនីយដ្ឋាន និងសណ្ឋាគារនានា គួរតែផ្សារភ្ជាប់ទំនាក់ទំនងជាមួយកសិករដើម្បីធានាទិញផលិតផលបន្លែសុវត្ថិភាពដែលពួកគាត់បានដាំដុះក្នុងតម្លៃសមស្របមួយ។

# ឯកសារយោង

# ឯកសារយោង

១. ទិន្នន័យឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ឆ្នាំ២០១៩

២. ឆាយ សុផល, ព័តមានសុខភាព, ២៥ ឧសភា ២០១១

៣. បណ្ឌិត ឈុន ពហុ, សេដ្ឋកិច្ចកសិកម្ម, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

៤. ម៉ម ចរិយាវុធ និង ងួន ហេង , សេដ្ឋកិច្ចនយោបាយ, បោះពុម្ពលើកទី៣ , ឆ្នាំ ២០១២

៥. ទូន ផល្លា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, មីក្រូសេដ្ឋកិច្ច, ឆ្នាំ ២០១៨

៦. បណ្ឌិត ប្រិន រ៉ូវែល និង តាក់អេងឡាយ, ឆ្នាំ ១៩៩២,ដំណាំបន្លែនៅកម្ពុជា

៧. អិន សុគា និងឡាញ់ ស្រីនាថ, ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈការដាំបន្លែ, ឆ្នាំ២០១៧

៨. Timothy J, Coelli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer

៩. Hal R. Varain, 2010, Intermediate Microeconomics, 8th Edition, New York, W.W. Norton& Company

១០. Timothy J, Coeli et all, An Introduction to Efficiency and Productivity Analysis, 2nd Edition, New York, Springer

១១. David Besanko Ronald R. Braetigan, 2010, Microeconomics, 4th Edition, New York John Wiley & Sons, Page 206

១២. Taro Yamane, An Introductory Analysis, 1967

១៣. http://www.healthcambodia.org

១៤. Merriam-Webster Dictionary, The Definition of Agriculture

១៥. https://www.aia.com.kh/kh

១៦. https://khemsaritheducation.wordpress.com/2018-05-6

១៧. https://cambonomist.com/news

១៨. https://wikipedia.com

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## កម្រងសំណួរសម្រាប់សម្ភាសន៍កសិករ

ការស្ទង់មតិនេះត្រូវបានរៀបចំឡើងដោយនិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងគោលបំណងក្នុងការប្រើប្រាស់សម្រាប់ការសរសេរសារណាបញ្ចប់ការសិក្សា។ រាល់ការផ្តល់ព័តមានរបស់លោកអ្នកត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តពុំមានការបង្ខិតបង្ខំឡើយ ហើយព័តមានរបស់លោកអ្នកត្រូវបានរក្សាជាការសម្ងាត់ផងដែរ។សូមអរគុណសម្រាប់ការចូលរួមសហការ។

១.ឈ្មោះមេគ្រួសារ.................. ភេទ....... អាយុ.......ឆ្នាំ មុខរបរ......

២. ចំនួនសមាជិកគ្រួសារ...............នាក់ ប្រុស...... ស្រី......

៣. ចំនួនកម្លាំងពលកម្ម..................នាក់ ប្រុស....... ស្រី......

៤. តើដំណាំប្រភេទអ្វីដែលអ្នកដាំ?

ក. ស្ពៃតឿ ☐ ខ.ស្ពៃចង្កឹះ ☐ គ.ស្ពៃក្រញាញ់ ☐

ឃ. ស្ពៃខ្មៅ ☐ ង. ផ្សេងៗ ☐

៥. តើមូលហេតុអ្វីបានជាអ្នកដាំប្រភេទបន្លែសុវត្ថិភាពនេះ?

.........................................................................................................................................

៦.តើអ្នកមានផ្ទៃដីដាំដុះប៉ុន្មានម៉ែតការដែរ? ...........................ម៉ែត្រការេ

៧.តើទំហំផ្ទៃដីនេះគ្រប់គ្រាន់សម្រាប់ការដាំសម្រាប់ផ្គត់ផ្គង់គ្រួសារដែរឬទេ?

ក.គ្រប់គ្រាន់ ☐ ខ.មិនគ្រប់គ្រាន់ ☐

៨.តើផ្ទៃដីដែលអ្នកកំពុងប្រកបរបរ បានមកពីណាដែរ?

ក.ជាកម្មសិទ្ធិផ្ទាល់ខ្លួន ☐ ខ.ជួលគេ ☐ គ. ទាំងពីរ ☐

៩. តើអ្នកបានពូជមកពីណាដែរសម្រាប់ដាំដុះ?

ក.សល់ពីការដាំមុនៗ ☐ ខ. ទិញគេ ☐ គ. ផ្សេងៗ ☐

១០. តើក្នុងពេលដាំ តើលោកអ្នកត្រូវការកម្លាំងពលកម្មប៉ុន្មាននាក់? ....................នាក់

១១. តើត្រូវចំណាយដើមទុនក្នុងមួយវដ្តផលិតកម្មប៉ុន្មានរៀល?..........................រៀល

១២.តើអ្នកទទួលបានដើមទុនមកពីណាដែរ?

ក.ខ្លួនឯង ☐ ខ.ខ្ចីគេ ☐ គ.កម្ចីឥណទាន ☐

ឃ.ជំនួយពីភ្នាក់ងារកសិកម្ម ☐ ង.ផ្សេងៗ ☐

១៣. តើអ្នកបានប្រភពទឹកដើម្បីស្រោចស្រពមកពីណាដែរ?

ក.ទន្លេ ☐ ខ.អណ្តូង ☐ គ.ទឹកស្រះ ☐ ឃ.ទឹកភ្លៀង ☐

១៤.តើប្រភពទឹកទាំងនេះគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ដែរឬទេ?

ក.គ្រប់គ្រាន់ ☐ ខ.មិនគ្រប់គ្រាន់ ☐

១៥.តើអ្នកប្រកបរបរដាំបន្លែសុវត្ថិភាពនេះប៉ុន្មានឆ្នាំហើយ?..................ឆ្នាំ

១៦. តើអ្នកមានបច្ចេកទេសដាំដំណាំបន្លែសុវត្ថិភាពនេះមកពីណាដែរ?

ក. តាំងពីបុរាណ ☐ ខ.តាមអ្នកជិតខាង ☐ គ.ភ្នាក់ងារកសិកម្ម ☐

ឃ.មន្ទីរកសិកម្ម ☐ ង.ផ្សេងៗ ☐

១៧.តើការអនុវត្តកសិកម្មសុវត្ថិភាពនេះ ទិន្នផលមានការកើនឡើងដែរឬទេ?

..........................................................................................................................

១៨. តើមុននិងក្រោយពេលដាំ ជីវភាពរបស់អ្នកប្រែប្រួលយ៉ាងដូចម្តេច?

ក.ប្រសើរជាងមុន ☐ ខ.នៅថេរ ☐ គ.លំបាកជាងមុន ☐

១៩.តើកត្តាអ្វីខ្លះដែលធ្វើឱ្យទិន្នផលកើនឡើង?

ក.អាកាសធាតុ ☐ ខ.ពូជដំណាំ ☐ គ.បច្ចេកទេសដាំ ☐ ឃ.ផ្សេងៗ ☐

២០. តើបញ្ហាប្រឈមអ្វីខ្លះដែលធ្វើឱ្យទិន្នផលធ្លាក់ចុះ?

ក.អាកាសធាតុ ☐ ខ.ពូជដំណាំ ☐ គ.ជម្ងឺ និងសត្វល្អិត ☐ ឃ.ផ្សេងៗ ☐

២១. តើអ្នកប្រើជីអ្វីដែរសម្រាប់ប្រើប្រាស់?

ក.ជីធម្មជាតិ ☐ ខ.ជីគីមី ☐ គ.ជីធម្មជាតិរួមផ្សំនិងជីគីមី ☐

២២. តើរយៈពេលប៉ុន្មានទើបលោកអ្នកទទួលបានផលដំណាំ?..............

២៣. នៅក្រោយពេលប្រមូលផល តើអ្នកលក់ផលិតផលចេញដោយរបៀបណា?

..........................................................................................................................

២៤. តើក្រោយពេលប្រមូលផលអ្នកជួបបញ្ហាប្រឈមអ្វីខ្លះ?

..........................................................................................................................

២៥. តើអ្នកមានដំណាំស្រាយយ៉ាងដូចម្តេច?

..........................................................................................................................

២៦.តើក្នុងមួយវដ្តផលិតកម្ម អ្នកទទួលបានទិន្នផលបន្លែប៉ុន្មានគីឡូក្រាម?........គីឡូក្រាម

# ឧបសម្ព័ន្ធទី២
# លទ្ធផលនៃការវិភាគ

ភេទរបស់មេគ្រួសារ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.30 |
| Std. Error of Mean | | .105 |
| Std. Deviation | | .470 |
| Minimum | | 1 |
| Maximum | | 2 |
| Sum | | 26 |

ភេទរបស់មេគ្រួសារ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 14 | 70.0 | 70.0 | 70.0 |
| | Female | 6 | 30.0 | 30.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

អាយុរបស់កសិករ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 3.45 |
| Std. Error of Mean | | .276 |
| Std. Deviation | | 1.234 |
| Minimum | | 1 |
| Maximum | | 5 |

### អាយុរបស់កសិករ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 20-29 | 2 | 10.0 | 10.0 | 10.0 |
| | 30-39 | 2 | 10.0 | 10.0 | 20.0 |
| | 40-49 | 5 | 25.0 | 25.0 | 45.0 |
| | 50-59 | 7 | 35.0 | 35.0 | 80.0 |
| | 60+ | 4 | 20.0 | 20.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

### ចំនួនសមាជិកនីមួយៗ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.55 |
| Std. Error of Mean | | .211 |
| Std. Deviation | | .945 |
| Minimum | | 1 |
| Maximum | | 4 |

### សមាជិកគ្រួសារនីមួយៗ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 2-3 | 2 | 10.0 | 10.0 | 10.0 |
| | 4-5 | 9 | 45.0 | 45.0 | 55.0 |
| | 6-7 | 5 | 25.0 | 25.0 | 80.0 |
| | 8+ | 4 | 20.0 | 20.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំនួនសមាជិកគ្រួសារជាប្រុស

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.50 |
| Std. Error of Mean | | .212 |
| Std. Deviation | | .946 |
| Minimum | | 1 |
| Maximum | | 4 |
| Sum | | 50 |

ចំនួនសមាជិកគ្រួសារជាប្រុស

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 3 | 15.0 | 15.0 | 15.0 |
| | 2 | 7 | 35.0 | 35.0 | 50.0 |
| | 3 | 7 | 35.0 | 35.0 | 85.0 |
| | 4 | 3 | 15.0 | 15.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំនួនពលកម្មក្នុងគ្រួសារ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 3.40 |
| Std. Error of Mean | | .358 |
| Std. Deviation | | 1.603 |
| Minimum | | 1 |
| Maximum | | 6 |
| Sum | | 68 |

ចំនួនពលកម្មក្នុងគ្រួសារ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 1 | 5.0 | 5.0 | 5.0 |
| | 2 | 7 | 35.0 | 35.0 | 40.0 |
| | 3 | 4 | 20.0 | 20.0 | 60.0 |
| | 4 | 2 | 10.0 | 10.0 | 70.0 |
| | 5 | 3 | 15.0 | 15.0 | 85.0 |
| | 6 | 3 | 15.0 | 15.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំនួនពលកម្មក្នុងគ្រួសារជាបុរស

| | | |
|---|---|---|
| N | Valid | 19 |
| | Missing | 1 |
| Mean | | 2.00 |
| Std. Error of Mean | | .254 |
| Std. Deviation | | 1.106 |
| Minimum | | 1 |
| Maximum | | 5 |
| Sum | | 38 |

ចំនួនពលកម្មក្នុងគ្រួសារជាបុរស

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1 | 7 | 35.0 | 36.8 | 36.8 |
| | 2 | 8 | 40.0 | 42.1 | 78.9 |
| | 3 | 2 | 10.0 | 10.5 | 89.5 |
| | 4 | 1 | 5.0 | 5.3 | 94.7 |
| | 5 | 1 | 5.0 | 5.3 | 100.0 |
| | Total | 19 | 95.0 | 100.0 | |
| Missing | System | 1 | 5.0 | | |
| Total | | 20 | 100.0 | | |

រយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 5.00 |
| Std. Error of Mean | | .441 |
| Std. Deviation | | 1.974 |
| Variance | | 3.895 |
| Minimum | | 3 |
| Maximum | | 10 |

រយៈពេលដែលកសិករប្រកបរបរដាំបន្លែសុវត្ថិភាព

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ៣ឆ្នាំ | 5 | 25.0 | 25.0 | 25.0 |
| | ៤ឆ្នាំ | 5 | 25.0 | 25.0 | 50.0 |
| | ៥ឆ្នាំ | 3 | 15.0 | 15.0 | 65.0 |
| | ៦ឆ្នាំ | 4 | 20.0 | 20.0 | 85.0 |
| | ៧ឆ្នាំ | 1 | 5.0 | 5.0 | 90.0 |
| | ៩ឆ្នាំ | 1 | 5.0 | 5.0 | 95.0 |
| | ១០ឆ្នាំ | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រភេទបន្លែដែលកសិករដាំ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.35 |
| Std. Error of Mean | | .274 |
| Std. Deviation | | 1.226 |
| Minimum | | 1 |
| Maximum | | 5 |
| Sum | | 47 |

ប្រភេទបន្លែដែលកសិករដាំ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ស្ពៃចង្កឹះ | 6 | 30.0 | 30.0 | 30.0 |
| | ស្ពៃតឿ | 5 | 25.0 | 25.0 | 55.0 |
| | ស្ពៃក្រញាញ់ | 7 | 35.0 | 35.0 | 90.0 |
| | ស្ពៃខ្មៅ | 2 | 10.0 | 10.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ទំហំដីកសិកម្មរបស់កសិករ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 6195.00 |
| Std. Error of Mean | | 763.044 |
| Std. Deviation | | 3412.435 |
| Sum | | 123900 |

ទំហំដីកសិកម្មរបស់កសិករ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 1200 | 1 | 5.0 | 5.0 | 5.0 |
| | 1600 | 2 | 10.0 | 10.0 | 15.0 |
| | 2000 | 1 | 5.0 | 5.0 | 20.0 |
| | 4000 | 2 | 10.0 | 10.0 | 30.0 |
| | 5000 | 3 | 15.0 | 15.0 | 45.0 |
| | 5500 | 1 | 5.0 | 5.0 | 50.0 |
| | 6000 | 1 | 5.0 | 5.0 | 55.0 |
| | 7000 | 3 | 15.0 | 15.0 | 70.0 |
| | 8000 | 1 | 5.0 | 5.0 | 75.0 |
| | 9000 | 1 | 5.0 | 5.0 | 80.0 |
| | 10000 | 2 | 10.0 | 10.0 | 90.0 |
| | 12000 | 1 | 5.0 | 5.0 | 95.0 |
| | 13000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.55 |
| Std. Error of Mean | | .114 |
| Std. Deviation | | .510 |
| Variance | | .261 |
| Minimum | | 1 |
| Maximum | | 2 |

ភាពគ្រប់គ្រាន់នៃផ្ទៃដីដាំដុះ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | គ្រប់គ្រាន់ | 9 | 45.0 | 45.0 | 45.0 |
| | មិនគ្រប់គ្រាន់ | 11 | 55.0 | 55.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

កម្មសិទ្ធិនៃផ្ទៃដី

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.70 |
| Std. Error of Mean | | .206 |
| Std. Deviation | | .923 |
| Variance | | .853 |
| Minimum | | 1 |
| Maximum | | 3 |

កម្មសិទ្ធិនៃផ្ទៃដី

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ផ្ទាល់ខ្លួន | 12 | 60.0 | 60.0 | 60.0 |
| | ជួលគេ | 2 | 10.0 | 10.0 | 70.0 |
| | ផ្ទាល់ខ្លួន និងជួលគេ | 6 | 30.0 | 30.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រភពដើមទុន

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.40 |
| Std. Error of Mean | | .169 |
| Std. Deviation | | .754 |
| Variance | | .568 |
| Minimum | | 1 |
| Maximum | | 3 |

ប្រភពដើមទុន

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ខ្លួនឯង | 15 | 75.0 | 75.0 | 75.0 |
| | ខ្ចីបងប្អូន | 2 | 10.0 | 10.0 | 85.0 |
| | កម្ចីឥណទាន | 3 | 15.0 | 15.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រភពបច្ចេកទេសដាំដុះ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 3.10 |
| Std. Error of Mean | | .100 |
| Std. Deviation | | .447 |
| Variance | | .200 |
| Minimum | | 2 |
| Maximum | | 4 |

ប្រភពបច្ចេកទេសដាំដុះ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | តាមរយៈអ្នកជិតខាង | 1 | 5.0 | 5.0 | 5.0 |
| | ភ្នាក់ងារកសិកម្ម | 16 | 80.0 | 80.0 | 85.0 |
| | មន្ទីរកសិកម្ម | 3 | 15.0 | 15.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រភពគ្រាប់ពូជ

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.00 |
| Std. Error of Mean | | .000 |
| Std. Deviation | | .000 |
| Variance | | .000 |
| Minimum | | 2 |
| Maximum | | 2 |

ប្រភពគ្រាប់ពូជ

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ទិញគេ | 20 | 100.0 | 100.0 | 100.0 |

ប្រភពទឹកស្រោចស្រព

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.95 |
| Std. Error of Mean | | .114 |
| Std. Deviation | | .510 |
| Variance | | .261 |
| Minimum | | 1 |
| Maximum | | 3 |

ប្រភពទឹកស្រោចស្រព

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ទន្លេ | 3 | 15.0 | 15.0 | 15.0 |
| | អណ្តូង | 15 | 75.0 | 75.0 | 90.0 |
| | ស្រះ | 2 | 10.0 | 10.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ប្រភេទដី

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.60 |
| Std. Error of Mean | | .210 |
| Std. Deviation | | .940 |
| Variance | | .884 |
| Minimum | | 1 |
| Maximum | | 3 |

## ប្រភេទដី

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ដីធម្មជាតិ | 14 | 70.0 | 70.0 | 70.0 |
| | ដីធម្មជាតិនិងគីមី | 6 | 30.0 | 30.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

## បញ្ហាប្រឈម

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.00 |
| Std. Error of Mean | | .218 |
| Std. Deviation | | .973 |
| Variance | | .947 |
| Minimum | | 1 |
| Maximum | | 3 |

## បញ្ហាប្រឈម

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | អាកាសធាតុ | 9 | 45.0 | 45.0 | 45.0 |
| | ពូជដំណាំ | 2 | 10.0 | 10.0 | 55.0 |
| | ជម្ងឺនិងសត្វល្អិតចង្រៃ | 9 | 45.0 | 45.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

### កត្តាដែលធ្វើឱ្យទិន្នផលកើនឡើង

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2.90 |
| Std. Error of Mean | | .069 |
| Std. Deviation | | .308 |
| Variance | | .095 |
| Minimum | | 2 |
| Maximum | | 3 |

### កត្តាដែលធ្វើឱ្យទិន្នផលកើនឡើង

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | កត្តាពូជ | 2 | 10.0 | 10.0 | 10.0 |
| | បច្ចេកទេសដាំដុះ | 18 | 90.0 | 90.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

### ជីវភាពរបស់កសិករក្រោយពេលដាំដុះបន្លែសុវត្ថិភាព

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1.00 |
| Std. Error of Mean | | .000 |
| Std. Deviation | | .000 |
| Variance | | .000 |
| Minimum | | 1 |
| Maximum | | 1 |

### ជីវភាពរបស់កសិករក្រោយពេលដាំដុះបន្លែសុវត្ថិភាព

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | ប្រសើរជាងមុន | 20 | 100.0 | 100.0 | 100.0 |

## កម្លាំងពលកម្មក្នុងការដាំបន្លែសុវត្ថិភាព

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 3 | 3 | 15.0 | 15.0 | 15.0 |
| | 4 | 3 | 15.0 | 15.0 | 30.0 |
| | 5 | 4 | 20.0 | 20.0 | 50.0 |
| | 6 | 3 | 15.0 | 15.0 | 65.0 |
| | 7 | 3 | 15.0 | 15.0 | 80.0 |
| | 8 | 2 | 10.0 | 10.0 | 90.0 |
| | 10 | 2 | 10.0 | 10.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

## កម្លាំងពលកម្មក្នុងការដាំបន្លែសុវត្ថិភាព

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 5.80 |
| Std. Error of Mean | | .474 |
| Std. Deviation | | 2.118 |
| Minimum | | 3 |
| Maximum | | 10 |
| Sum | | 116 |

ចំណាយក្នុងការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 1912500.00 |
| Std. Error of Mean | | 257106.240 |
| Std. Deviation | | 1149814.058 |
| Sum | | 38250000 |

ចំណាយក្នុងការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 350000 | 1 | 5.0 | 5.0 | 5.0 |
| | 400000 | 1 | 5.0 | 5.0 | 10.0 |
| | 600000 | 2 | 10.0 | 10.0 | 20.0 |
| | 700000 | 1 | 5.0 | 5.0 | 25.0 |
| | 1300000 | 1 | 5.0 | 5.0 | 30.0 |
| | 1500000 | 2 | 10.0 | 10.0 | 40.0 |
| | 1600000 | 1 | 5.0 | 5.0 | 45.0 |
| | 1700000 | 2 | 10.0 | 10.0 | 55.0 |
| | 2000000 | 1 | 5.0 | 5.0 | 60.0 |
| | 2100000 | 1 | 5.0 | 5.0 | 65.0 |
| | 2200000 | 1 | 5.0 | 5.0 | 70.0 |
| | 2500000 | 1 | 5.0 | 5.0 | 75.0 |
| | 3000000 | 2 | 10.0 | 10.0 | 85.0 |
| | 3500000 | 2 | 10.0 | 10.0 | 95.0 |
| | 4500000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំណូលបានពីការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 4425000.00 |
| Std. Error of Mean | | 581790.566 |
| Std. Deviation | | 2601846.510 |
| Minimum | | 750000 |
| Maximum | | 10000000 |

ចំណូលបានពីការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 750000 | 1 | 5.0 | 5.0 | 5.0 |
| | 1000000 | 1 | 5.0 | 5.0 | 10.0 |
| | 1200000 | 1 | 5.0 | 5.0 | 15.0 |
| | 1300000 | 1 | 5.0 | 5.0 | 20.0 |
| | 1600000 | 1 | 5.0 | 5.0 | 25.0 |
| | 2600000 | 1 | 5.0 | 5.0 | 30.0 |
| | 3900000 | 1 | 5.0 | 5.0 | 35.0 |
| | 4000000 | 2 | 10.0 | 10.0 | 45.0 |
| | 4200000 | 2 | 10.0 | 10.0 | 55.0 |
| | 4400000 | 1 | 5.0 | 5.0 | 60.0 |
| | 5000000 | 1 | 5.0 | 5.0 | 65.0 |
| | 5250000 | 1 | 5.0 | 5.0 | 70.0 |
| | 5400000 | 1 | 5.0 | 5.0 | 75.0 |
| | 6500000 | 1 | 5.0 | 5.0 | 80.0 |
| | 7000000 | 1 | 5.0 | 5.0 | 85.0 |
| | 7800000 | 1 | 5.0 | 5.0 | 90.0 |
| | 8400000 | 1 | 5.0 | 5.0 | 95.0 |
| | 10000000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

ចំណេញបានពីការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2532500.00 |
| Std. Error of Mean | | 322781.395 |
| Std. Deviation | | 1443522.282 |
| Minimum | | 400000 |
| Maximum | | 5500000 |

ចំណេញបានពីការដាំបន្លែសុវត្ថិភាពក្នុង១វដ្តផលិតកម្ម

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 400000 | 1 | 5.0 | 5.0 | 5.0 |
| | 600000 | 1 | 5.0 | 5.0 | 10.0 |
| | 700000 | 1 | 5.0 | 5.0 | 15.0 |
| | 900000 | 1 | 5.0 | 5.0 | 20.0 |
| | 1000000 | 1 | 5.0 | 5.0 | 25.0 |
| | 1300000 | 1 | 5.0 | 5.0 | 30.0 |
| | 2200000 | 1 | 5.0 | 5.0 | 35.0 |
| | 2300000 | 1 | 5.0 | 5.0 | 40.0 |
| | 2400000 | 2 | 10.0 | 10.0 | 50.0 |
| | 2700000 | 2 | 10.0 | 10.0 | 60.0 |
| | 2900000 | 2 | 10.0 | 10.0 | 70.0 |
| | 3050000 | 1 | 5.0 | 5.0 | 75.0 |
| | 3500000 | 1 | 5.0 | 5.0 | 80.0 |
| | 4000000 | 1 | 5.0 | 5.0 | 85.0 |
| | 4300000 | 1 | 5.0 | 5.0 | 90.0 |
| | 4900000 | 1 | 5.0 | 5.0 | 95.0 |
| | 5500000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

### បរិមាណបន្លែដែលទទួលបានក្នុង១វដ្តផលិតកម្ម

| | | |
|---|---|---|
| N | Valid | 20 |
| | Missing | 0 |
| Mean | | 2182.00 |
| Std. Error of Mean | | 299.746 |
| Std. Deviation | | 1340.505 |
| Minimum | | 300 |
| Maximum | | 5000 |
| Sum | | 43640 |

### បរិមាណបន្លែដែលទទួលបានក្នុង១វដ្តផលិតកម្ម

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 300 | 1 | 5.0 | 5.0 | 5.0 |
| | 400 | 1 | 5.0 | 5.0 | 10.0 |
| | 450 | 1 | 5.0 | 5.0 | 15.0 |
| | 640 | 1 | 5.0 | 5.0 | 20.0 |
| | 650 | 1 | 5.0 | 5.0 | 25.0 |
| | 1300 | 1 | 5.0 | 5.0 | 30.0 |
| | 2000 | 3 | 15.0 | 15.0 | 45.0 |
| | 2100 | 2 | 10.0 | 10.0 | 55.0 |
| | 2200 | 2 | 10.0 | 10.0 | 65.0 |
| | 2500 | 1 | 5.0 | 5.0 | 70.0 |
| | 2700 | 1 | 5.0 | 5.0 | 75.0 |
| | 3500 | 2 | 10.0 | 10.0 | 85.0 |
| | 3900 | 1 | 5.0 | 5.0 | 90.0 |
| | 4200 | 1 | 5.0 | 5.0 | 95.0 |
| | 5000 | 1 | 5.0 | 5.0 | 100.0 |
| | Total | 20 | 100.0 | 100.0 | |

# ឧបសម្ព័ន្ធទី៣

ផែនទីឃុំស្វាយប្រទាល

\



ប្រភព៖ សាលាឃុំស្វាយប្រទាល

ផែនទីព្រំប្រទល់រដ្ឋបាលស្រុកស្អាង




ប្រភព៖ សាលាឃុំស្វាយប្រទាល

ផែនទីស្រុកស្អាង




N
W
E
S
ស្រុកកៀនស្វាយ
500000
501000
502000
503000
504000
505000
506000
507000
508000
509000
510000
1256000
1257000
1258000
1259000
1260000
1261000
1262000
Legend

ប្រភព៖ សាលាឃុំស្វាយប្រទាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក ស្លាគ
ឃុំ ស្វាយប្រទាល

## ស្ថិតិប្រជាពលរដ្ឋប្រចាំ ឆ្នាំ ២០១៩

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋ | | | | | | ចំនួនប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើង | | | | | | គ្មានអត្តសញ្ញាណប័ណ្ណ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | អចិន្ត្រៃយ៍ | បណ្ដោះអាសន្ន | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ចំណាកស្រុក | | |
| | | | | | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
| 1 | ព្រៃ កតាតិន | 385 | 385 | | 1683 | 865 | 1683 | 865 | | | 865 | 450 | 865 | 450 | | | |
| 2 | ឫស្សីជ្រោយ | 413 | 413 | | 2005 | 1111 | 2005 | 1111 | | | 1267 | 735 | 1267 | 735 | | | |
| 3 | ព្រៃកតាជ័រ | 568 | 568 | | 2676 | 1396 | 2676 | 1396 | | | 1455 | 720 | 1455 | 720 | | | |
| 4 | ព្រៃកតាសៅ | 370 | 370 | | 1725 | 897 | 1725 | 897 | | | 1180 | 605 | 1180 | 605 | | | |
| 5 | ចុងកោះគរ | 201 | 201 | | 828 | 437 | 828 | 437 | | | 542 | 298 | 542 | 298 | | | |
| 6 | បារែនលើ | 230 | 230 | | 1010 | 463 | 1010 | 463 | | | 727 | 723 | 727 | 723 | | | |
| 7 | អូរចេក | 246 | 246 | | 1057 | 541 | 1057 | 541 | | | 501 | 260 | 501 | 260 | | | |
| 8 | បារែនក្រោម | 687 | 687 | | 3096 | 1630 | 3096 | 1630 | | | 1975 | 1055 | 1975 | 1055 | | | |
| 9 | ពោធិតាប៉ាង | 539 | 539 | | 2472 | 1318 | 2472 | 1318 | | | 1238 | 677 | 1238 | 677 | | | |
| | សរុប | 3639 | 3639 | | 16552 | 8658 | 16552 | 8658 | | | 9750 | 5523 | 9750 | 5523 | | | |

បញ្ជាក់៖ ចំពោះភូមិដែលមិនមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ប្រជាពលរដ្ឋនៅក្នុងភូមិនោះ ត្រូវស្រង់បូកបញ្ចូលទៅក្នុងភូមិដែលមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ។

បានឃើញ និង ឯកភាព
ថ្ងៃ សុក្រ១៤កើត ខែមិគសិរឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២
ថ្ងៃទី ២១ ខែ ធ្នូ គ.ស ២០១៨
មេឃុំស្វាយប្រទាល

ថ្ងៃ សុក្រ១៤កើត ខែមិគសិរឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២
ស្វាយប្រទាល ថ្ងៃទី ២១ ខែ ធ្នូ គ.ស ២០១៨
ស្មៀន

ប្រភព៖ សាលាឃុំស្វាយប្រទាល

[illegible]

| [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| [illegible] | 413,76 | 89 | - | - | | 122 | 10 | 10 | - | 80 | 10,50 | 2 [illegible] | 12628 [illegible] 3024 | |
| [illegible] | 435 | 118 | - | - | | 188 | 15 | 20 | - | 74 | 12,50 | - | - | |
| [illegible] | 521 | 144 | - | - | | 139 | 20 | 30 | - | 82 | 16 | 1 | - | |
| [illegible] | 374,22 | 120 | 3 | - | | 68 | 10 | 21 | - | 72 | 9 | - | 0,22 | |
| [illegible] | 326 | 71 | - | - | | 81 | 10 | - | 6 | 81 | 8 | - | - | |
| [illegible] | 299,13 | 91 | - | - | | 57 | 8 | - | 14 | 42 | 12 | 1,50 | 0,63 | |
| [illegible] | 223 | 73 | - | - | | 43 | 5 | - | 12 | - | 7 | - | - | |
| [illegible] | 485,43 | 163 | - | - | | 101 | 11 | 9 | 27 | 91 | 12,60 | 0,50 [illegible] | 0,33 | |
| [illegible] | 446,61 | 180 | 4 | - | | 103 | 11 | 5 | 23 | - | 11,15 | - | 0,46 | |
| [illegible] | 3524,15 | 1049 | 7 | 0 | 0 | 832 | 100 | 95 | 112 | 522 | 98,75 | 5 | 3,40 | |

- [illegible] 24 [illegible]
- [illegible] 30 [illegible] 60 [illegible]

ប្រភព៖ សាលាឃុំស្វាយប្រទាល

# ឧបសម្ព័ន្ធទី៤

ការគោយចំបើងដើម្បីការពារកូនដំណាំ



ការរៀបចំដី និងដាក់សំណាញ់ការពារ



កសិករកំពុងមើលថែទាំដំណាំ



ដំណាំបន្លែសុវត្ថិភាពរបស់កសិករនៅឃុំស្វាយប្រទាល



កសិករកំពុងប្រមូលផលដំណាំ



ប្រព័ន្ធស្រោចស្រពបន្លែ



ការសម្ភាសផ្ទាល់ជាមួយកសិករដាំបន្លែសុវត្ថិភាពក្នុងឃុំស្វាយប្រទាល





ដំណាំបន្លែសុវត្ថិភាពដែលកសិករដាំក្បែរផ្ទះ



